គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
Pour le Cambodge

Australian Aid

# គោលការណ៍ណែនាំស្ដីពីការប្រតិបត្តិល្អ
# របស់
# អង្គការសហគមន៍មូលដ្ឋាន



បោះពុម្ពដោយ
គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)

ខែ មេសា ឆ្នាំ២០១៧

ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា

Accountability
GPP
25/08/2015
24/08/2018
Symbol of Trust

**បោះពុម្ពផ្សាយដោយ៖ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)**

ជាភាសាអង់គ្លេស **Cooperation Committee for Cambodia (CCC)**

**សម្របសម្រួល និងបោះពុម្ពលើកទី១៖ ខែមេសា ឆ្នាំ ២០១៧**

រក្សាសិទ្ធិគ្រប់យ៉ាង។ រាល់ខ្លឹមសារ ឬឯកសារដែលមាននៅទីនេះ ត្រូវបានរក្សាសិទ្ធិដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)។ រាល់ការបោះពុម្ពឡើងវិញ និងការកែសម្រួលផ្នែកណាមួយនៃគោលការណ៍នេះ ត្រូវសុំអនុញ្ញាតពីគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា(គ.ស.ក)។

**ទំនាក់ទំនងមកកាន់ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)**

អសយដ្ឋាន៖ ផ្ទះលេខ៩ - ១១ ផ្លូវលេខ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានី ភ្នំពេញ
ប្រអប់សំបុត្រលេខ ៨៨៥ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរសព្ទលេខ៖ (៨៥៥-២៣) ២១៤ ១៥២

ទូរសារ៖ (៨៥៥-២៣) ២១៦ ០០៩

សារអេឡិចត្រូនិច៖ info@ccc-cambodia.org ឬ ngogpp@ccc-cambodia.org

# អារម្ភកថា

## មិត្ត និងសហការីជាទីរាប់អាន!

ជិតបីទសវត្សរ៍មកហើយ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសកម្ពុជា និងសម្រេចបាននូវសមិទ្ធផល ដ៏ជាទីមោទនៈសម្រាប់អភិវឌ្ឍ និងពង្រឹងអង្គការសង្គមស៊ីវិល ជាពិសេសលើកកម្ពស់នូវអភិបាលកិច្ចល្អ និងគណនេយ្យភាព ក៏ដូចជាការកសាងសមត្ថភាពដល់ សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្នុងការចូលរួមអភិវឌ្ឍប្រទេសកម្ពុជា សង្គមស៊ីវិលរួមមាន សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ព្រមទាំងក្រុមសហគមន៍ ឬសហគមន៍មូលដ្ឋាន ត្រូវបានចាត់ទុកជាកម្លាំងចលករមួយយ៉ាងសំខាន់ ដែលជំរុញឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងប្រកបដោយនិរន្តរភាព។

តាមទស្សនៈនៃការសិក្សា និងការវាយតម្លៃនៃការអភិវឌ្ឍប្រទេសកម្ពុជា អង្គការសហគមន៍មូលដ្ឋានគឺជាតួអង្គដ៏សំខាន់ក្នុងការជួយស្តារ និងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចប្រទេសជាតិ។ ក្នុងទស្សនៈ និងជំនឿ ក៏ដូចជាអនុសាសន៍ពីការវាយតម្លៃផ្សេងៗបានបង្ហាញថា៖ សេដ្ឋកិច្ចប្រទេសកម្ពុជា ជាពិសេសជីវភាពប្រជាពលរដ្ឋមូលដ្ឋាននឹងមានភាពល្អប្រសើរ ប្រសិនបើសហគមន៍ទាំងនោះមានការប្រតិបត្តិល្អ និងនិរន្តរភាព។ ទោះជាយ៉ាងនេះក៏ដោយ យោងតាមការសិក្សាស្រាវជ្រាវ និងការពិគ្រោះយោបល់ជាច្រើនជាមួយសហគមន៍ផ្ទាល់បានបង្ហាញថា៖ អង្គការសហគមន៍មូលដ្ឋានបច្ចុប្បន្នកំពុងជួបប្រទះនូវបញ្ហា និងកត្តាប្រឈមជាច្រើនដែលរារាំងដល់ការប្រតិបត្តិល្អ និងនិរន្តរភាពរបស់ពួកគេ។ បញ្ហាប្រឈមទាំងនោះរួមមាន៖ ***កង្វះខាតគោលការណ៍ គោលនយោបាយ ប្រព័ន្ធគ្រប់គ្រង ការចាត់ចែងទូទៅ ផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងចំណូលចំណាយប្រកបដោយតម្លាភាព និងគណនេយ្យភាព កង្វះខាតធនធានមនុស្សក្នុងជួរគណៈកម្មការដឹកនាំ ការចូលរួមបែបសកម្មពីសមាជិក ការតាមដាននិងត្រួតពិនិត្យ កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ អង្គការម្ចាស់ជំនួយ វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ។***

ដើម្បីចូលរួមចំណែកក្នុងការគាំទ្រ និងរកដំណោះស្រាយជូនអង្គការសហគមន៍មូលដ្ឋាន គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា បានទទួលការចូលរួម និងគាំទ្រពីអង្គការជាសមាជិក ម្ចាស់ជំនួយ ក៏ដូចជា អង្គការដៃគូពាក់ព័ន្ធ ជាពិសេសសអង្គការសហគមន៍មូលដ្ឋាន បានផ្តួចផ្តើមគំនិតបង្កើត និងចងក្រង **គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន។** គោលការណ៍នេះ គឺជាមគ្គុទ្ទេសក៍ជំនួយស្មារតីដ៏សំខាន់សម្រាប់អង្គការ

សហគមន៍មូលដ្ឋាន ឲ្យធ្វើប្រតិបត្តិការនៅក្នុងសហគមន៍ប្រកបដោយអភិបាលកិច្ចល្អ វិជ្ជាជីវៈ និងនិរន្តរភាព ព្រោះថាខ្លឹមសារនៃគោលការណ៍នេះ បានជួយតម្រង់ទិសទៅលើរបៀបដែលអង្គការសហគមន៍មូលដ្ឋាន គួរបង្កើតលក្ខន្តិកៈ អនុវត្តសកម្មភាពតាមគោលការណ៍ច្បាប់នានា ពិសេសពន្យល់អំពីរបៀបដែលអង្គការសហគមន៍មូលដ្ឋានធ្វើផែនការ ចាត់ចែង គ្រប់គ្រងលើធនធាន (មនុស្ស សំភារៈ និងហិរញ្ញវត្ថុ) និងការតាមដានត្រួតពិនិត្យលើការងារប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ យ៉ាងណាមិញ គោលការណ៍ណែនាំនេះ អាចមានប្រសិទ្ធភាពទៅបាន លុះត្រាតែមានការប្តេជ្ញាចិត្តខ្ពស់ពីអង្គការសហគមន៍មូលដ្ឋានក្នុងការអនុវត្តន៍តាមគោលការណ៍ និងមានការចូលរួមគាំទ្រពីភាគីពាក់ព័ន្ធផងដែរ។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ទទួលស្គាល់ថាឯកសារនេះជាការផ្តួចផ្តើមថ្មីមួយ ហើយវាអាចមានចំនុចខ្វះខាតមួយចំនួនដែលត្រូវកែលម្អ ដូច្នេះសូមស្វាគមន៍ជានិច្ចនូវមតិកែលម្អនានាពីសាធារណជន ដើម្បីឲ្យឯកសារនេះកាន់តែអាចឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់អង្គការសហគមន៍មូលដ្ឋាន។ ទន្ទឹមនឹងនេះ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា អង្គការសហគមន៍មូលដ្ឋាន នឹងយកគោលការណ៍ណែនាំនេះ ធ្វើជាមគ្គុទេសក៍ជំនួយស្មារតីសម្រាប់ការប្រតិបត្តិរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដោយមានការជួយគាំទ្រពីអង្គការជាសមាជិក ដៃគូផ្តល់ជំនួយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល នឹងបន្តខិតខំថែរក្សា និងបង្កើនកិត្តិនាមរបស់វិស័យអង្គការសង្គមស៊ីវិល ដោយពង្រឹងជាបន្តបន្ទាប់នូវបរិយាកាសអំណោយផលសមត្ថភាព និងការប្រតិបត្តិការជាគម្រូ ប្រកបដោយអភិបាលកិច្ចល្អ គណនេយ្យភាព និងនិរន្តរភាពសម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ យើងមានការជឿជាក់ថា លក្ខណៈសម្បត្តិទាំងអស់នេះនឹងជម្រុញសង្គមស៊ីវិលឲ្យធ្វើការយ៉ាងសកម្មជាមួយសហគមន៍ រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសកម្ពុជាឲ្យកាន់តែចំរើនរុងរឿង។

**សៀង សារឿន**

នាយកប្រតិបត្តិ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

**គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគន៍មូលដ្ឋាន** ត្រូវបានបង្កើតឡើងដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ភាគីពាក់ព័ន្ធនានា។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា សូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការលះបង់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងពេលវេលា របស់លោក លោកស្រី ដើម្បីតាក់តែងនូវគោលការណ៍ណែនាំសម្រាប់អង្គការសហគមន៍មូលដ្ឋាននេះឡើង។ សូមថ្លែងអំណរគុណជាពិសេសចំពោះ ក្រុមការងារបច្ចេកទេស (Technical Working Group) ដែលមានតំណាងមកពីសមាគម អង្គការសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិផងដែរ។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា សូមអរគុណជាពិសេសចំពោះ ដៃគូផ្តល់ជំនួយរបស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ជាពិសេសស្ថានទូតអូស្ត្រាលី ដែលបានជួយគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់ដំណើរការ រៀបចំតាក់តែងគោលការណ៍នេះឡើង។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ក៏សូមថ្លែងអំណរគុណដល់សហគមន៍មូលដ្ឋានទាំងឡាយដែលបានចូលរួមវិភាគទានជាយោបល់ បទពិសោធន៍ល្អៗ និងឯកសារផ្សេងៗទាំងក្នុងអំឡុងពេលធ្វើសេចក្តីព្រាងគោលការណ៍ ក៏ដូចជាសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនលើក។ ពិសេសយើងខ្ញុំក៏សូមកោតសរសើរនូវស្មារតី និងឆន្ទៈរួបរួមគ្នាចូលរួមបង្កើត និងយកគោលការណ៍ដែលជាឯកសារមគ្គុទ្ទេសក៏នេះទៅរៀនសូត្រ អនុវត្ត និងឆ្លុះបញ្ចាំងសម្រាប់ជាប្រយោជន៍ដល់អង្គការសហគមន៍មូលដ្ឋានរបស់ខ្លួន។

# មាតិកា

ដំណើរការនៃការបង្កើតគោលការណ៍ណែនាំស្ដីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ...៩
គោលការណ៍ណែនាំស្ដីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ............................... ១២
១. សេចក្ដីផ្ដើម ........................................................................................................ ១២
២. គោលបំណងនៃគោលការណ៍ណែនាំស្ដីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន. ១៣
៣. តើគោលការណ៍ណែនាំនេះមានអ្វីខ្លះ និងប្រើប្រាស់យ៉ាងដូចម្ដេច? .................................. ១៤
៤. ប្រតិបត្តិការ នៃអង្គការសហគមន៍មូលដ្ឋាននាពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា .................... ១៤

## បទដ្ឋាន គោលការណ៍ និងសេចក្ដីណែនាំ

**ជំពូកទី១៖ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន** ............................. ១៨
**ជំពូកទី២៖ ទំនាក់ទំនង កិច្ចសហការ និងការចងបណ្ដាញ** ................................................... ២៣
**ជំពូកទី៣៖ សមាជិកភាព និងការគ្រប់គ្រងសមាជិក** ......................................................... ២៦
**ជំពូកទី៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ** ................................................................................ ២៧
**ជំពូកទី៥៖ គណនេយ្យភាព និងតម្លាភាព** ........................................................................ ២៩
**ជំពូកទី៦៖ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ** .................................................... ៣១
**ជំពូកទី៧៖ យុទ្ធសាស្រ្ត និងការធានានិរន្តរភាព** ............................................................... ៣២
**ជំពូកទី៨៖ ការពង្រឹងសមត្ថភាព និងការយល់ដឹង** ............................................................ ៣៤

# សន្ទានុក្រម និងបញ្ជីឧបសម្ព័ន្ធគម្រូ

សន្ទានុក្រម ........ ៣៥

# បញ្ជីឧបសម្ព័ន្ធគម្រូ

ឧបសម្ព័ន្ធគម្រូ១៖ លក្ខន្តិកៈនៃអង្គការសហគមន៍មូលដ្ឋាន ........ ៤១

ឧបសម្ព័ន្ធគម្រូ២៖ ការសម្របសម្រួលកិច្ចប្រជុំប្រកបដោយប្រសិទ្ធភាពសម្រាប់អង្គការ ........ ៦៧

ឧបសម្ព័ន្ធគម្រូ៣៖ គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ ........ ៧៧

គម្រូ១៖ ទម្រង់សៀវភៅ ឬបញ្ជី កត់ត្រាចំណូល និងចំណាយប្រចាំថ្ងៃ ........ ៨៤

គម្រូ២៖ គោលការណ៍ សន្សំ ខ្ចី និងសងប្រាក់ ........ ៨៦

គម្រូ៣៖ គោលការណ៍បែងចែកភាគលាភ និងការប្រាក់ ........ ៨៩

គម្រូ៤៖ គោលការណ៍ប្រើប្រាស់ថវិកាសមាជិកភាព ........ ៩០

គម្រូ៥៖ ទម្រង់ស្នើសុំចំណាយ ........ ៩២

ឧបសម្ព័ន្ធគម្រូ៤៖ គោលការណ៍បង្ការទំនាស់ផលប្រយោជន៍ ........ ៩៣

ឧបសម្ព័ន្ធគម្រូ៥៖ ទម្រង់ផ្តល់ព័ត៌មានត្រលប់ ឬបណ្តឹងតវ៉ា ........ ៩៩

ឧបសម្ព័ន្ធគម្រូ៦៖ ទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យ ផែនការសកម្មភាព ........ ១០៣

ឧបសម្ព័ន្ធគម្រូ៧៖ ករណីសិក្សាពីជោគជ័យរបស់អង្គការសហគមន៍មូលដ្ឋាន ........ ១០៥

ឧបសម្ព័ន្ធគម្រូ៨៖ ករណីសិក្សាអង្គការសហគមន៍មូលដ្ឋានដែលមិនសូវមានដំណើរការល្អ ........ ១១៥

ឧបសម្ព័ន្ធគម្រូ៩៖ បញ្ជីអ្នកចូលរួមពាក់ព័ន្ធ បង្កើតគោលការណ៍ណែនាំ ........ ១១៩

# ដំណើរការនៃការបង្កើតគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

**គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**នេះ បានចាប់ផ្តើមឡើងចាប់តាំងពីឆ្នាំ២០១៤ ដោយមានការគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេសពីដៃគូពាក់ព័ន្ធនានា។ គោលការណ៍នេះបង្កើតឡើងដោយមានការគាំទ្រ និងចូលរួមយោបល់ពីគ្រប់ភាគីពាក់ព័ន្ធក៏ដូចជាការសិក្សាពីឯកសារគម្រូផ្សេងៗផងដែរ។

មានវិធីសាស្រ្ត និងដំណើរការជាច្រើនដែលត្រូវបានប្រើប្រាស់ក្នុងការប្រមូលធាតុចូល និងផ្ទៀងផ្ទាត់ព័ត៌មាននានា ចាប់តាំងពីដំណាក់កាលចាប់ផ្តើម រហូតដល់ពេលដែលគោលការណ៍ណែនាំនេះត្រូវបានអនុម័ត។ ដំណើរការទាំងនេះមានដូចខាងក្រោម៖

១. កិច្ចប្រជុំពិគ្រោះយោបល់ នៅថ្ងៃទី១៤ តុលា ឆ្នាំ ២០១៤ ដែលមានអ្នកចូលរួម និងគាំទ្រពីអង្គការក្នុងស្រុក ១៩នាក់ និងអង្គការអន្តរជាតិ២នាក់ រួមទាំងការប្រើប្រាស់ឯកសារយោងនានាផងដែរ។

២. ការសិក្សាពីឯកសារយោងដែលមានស្រាប់ពីអង្គការ ឬស្ថាប័នក្នុងប្រទេស និងក្រៅប្រទេសដែលពាក់ព័ន្ធរួមមាន៖

## ក. ឯកសារក្នុងប្រទេស៖

- ក្រម និងបទដ្ឋានស្តីពីអភិបាលកិច្ចល្អ និងប្រតិបត្តិប្រកបដោយវិជ្ជាជីវៈរបស់អង្គការសង្គមស៊ីវិល (Standards of Good Governance and Professional Practices for NGOs in Cambodia) ឆ្នាំ២០១៤
- ជម្រើសសម្រាប់ការគាំទ្រនាពេលអនាគតក្នុងការពង្រឹងសិទ្ធិជាម្ចាស់ដល់អង្គការសហគមន៍មូលដ្ឋាន នៅកម្ពុជា (អង្គការហ្វូរ៉ុមស៊ីដ ForumSyd) ឆ្នាំ២០០៦
- ដំណើរការបង្កើតអង្គការសហគមន៍មូលដ្ឋាន (អង្គការទ្រទ្រង់កសិករជនបទ) ឆ្នាំ ២០០៩
- សៀវភៅណែនាំពីអង្គការសហគមន៍មូលដ្ឋាន (អង្គការបន្ទាយស្រី) (គ្មានកាលបរិច្ឆេទ)
- គោលការណ៍ណែនាំស្តីពីការបង្កើតអង្គការជនជាតិដើមភាគតិច របស់អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) ឆ្នាំ២០០៨

- ជំហានក្នុងដំណើរការបង្កើតក្រុមជួយខ្លួនឯង របស់អង្គការ អតីតយុទ្ធជនអន្តរជាតិកម្ពុជា (VIC) (គ្មានកាលបរិច្ឆេទ)
- ការគាំទ្រយុទ្ធសាស្ត្រ និងបច្ចេកទេសចំពោះគម្រោងអភិវឌ្ឍន៍អង្គការសហគមន៍មូលដ្ឋាន (អង្គការហ្វូរ៉ុមស៊ីដ ForumSyd) ឆ្នាំ២០១៦
- ការគ្រប់គ្រងគម្រោង៖ សៀវភៅណែនាំសម្រាប់អង្គការសហគមន៍មូលដ្ឋាន (អង្គការផែក PACT) ឆ្នាំ២០០៥
- គោលការណ៍ណែនាំស្តីពីអង្គការជនពិការ (អង្គការជនពិការកម្ពុជា) ឆ្នាំ២០១៥
- គោលគំនិតនៃការបង្កើតអង្គការសហគមន៍មូលដ្ឋាន (អង្គការ Ockenden International Cambodia ) (គ្មានកាលបរិច្ឆេទ)

## ខ. ឯកសារពីក្រៅប្រទេស៖

- បណ្តាញឆ្លើយតប និងរៀបចំអង្គការសហគមន៍មូលដ្ឋាន (មន្ទីរសុខាភិបាលសាធារណៈរដ្ឋអាឡាំម៉េដា ខោនទី នៅសហរដ្ឋអាមេរិក) (គ្មានកាលបរិច្ឆេទ)
- ការកសាងសមត្ថភាពសម្រាប់អង្គការក្នុងស្រុក (CIIR/ICD) ឆ្នាំ២០០៥
- ការពិនិត្យឡើងវិញទៅលើសុខុមាលភាព៖ ការពង្រឹងសិទ្ធិជាម្ចាស់ដល់អង្គការកម្រិតសហគមន៍ (Open Society Foundations) ឆ្នាំ២០១២
- គោលការណ៍ណែនាំ សម្រាប់បង្កើតអង្គការសហគមន៍គ្រប់គ្រងនេសាទ នៅតាន់ហ្សានៀ (WWF) ឆ្នាំ២០០៩
- សៀវភៅណែនាំពីអង្គការសហគមន៍មូលដ្ឋាន (San Francisco Unified School District-SFUSD) (គ្មានកាលបរិច្ឆេទ)
- គោលការណ៍ទីក្រុងអ៊ីស្តានប៊ុល និងកិច្ចព្រមព្រៀងទីក្រុងសៀមរាបស្តីពី ប្រសិទ្ធភាពនៃការអភិវឌ្ឍអង្គការសង្គមស៊ីវិល ឆ្នាំ២០១១
- សេចក្តីព្រាងបទដ្ឋានសកលសម្រាប់គណនេយ្យភាពអង្គការសង្គមស៊ីវិល ឆ្នាំ២០១៦

៣. កិច្ចប្រជុំក្រុមការងារបច្ចេកទេសជាបន្តបន្ទាប់ ដែលមានសមាជិកចូលរួមចំនួន ២០នាក់ ជាតំណាងពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការអន្តរជាតិ និងអង្គការសហគមន៍មូលដ្ឋាន (៣០% នៃសមាជិកសរុប) ។ សមាជិកក្រុមការងារបច្ចេកទេសនេះមានបទពិសោធន៍ច្រើនឆ្នាំ ធ្វើការជាមួយអង្គការសហគមន៍មូលដ្ឋាន និងធ្វើការដឹកនាំអង្គការសហគមន៍មូលដ្ឋានរបស់ខ្លួនឯងផ្ទាល់។ សមាជិកក្រុមការងារបច្ចេកទេសបានចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ប្តូរយោបល់ក្នុង

ការតាក់តែងខ្លឹមសារ និងកែលម្អ **គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**នេះ។

៤. សិក្ខាសាលាថ្នាក់ខេត្ត ដើម្បីពិគ្រោះយោបល់ និងរៀនសូត្រជាមួយតំណាងអង្គការសហគមន៍មូលដ្ឋានផ្ទាល់ទូទាំងប្រទេសចំនួនជាង១០០អង្គការសហគមន៍មូលដ្ឋាន ដែលបានស្ម័គ្រចិត្តចូលរួម និងផ្តល់យោបល់ ពិភាក្សា ចែករំលែកបទពិសោធន៍ផ្ទាល់ និងវិភាគទានជាឯកសារផ្សេងៗ សម្រាប់ជាគម្រូ និងគំនិតក្នុងការតាក់តែង **គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**។

៥. សិក្ខាសាលាពិគ្រោះយោបល់ រៀនសូត្រថ្នាក់ជាតិ ដែលមានអ្នកចូលរួមមកពីគ្រប់ភាគីពាក់ព័ន្ធ ដូចជាៈ អង្គការសហគមន៍មូលដ្ឋានជាង៧០មកពីគ្រប់ខេត្ត ក្រុង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការអន្តរជាតិ ម្ចាស់ជំនួយ និងមន្ត្រីជំនាញដែលអញ្ជើញមកពីស្ថាប័ននានារបស់ក្រសួងពាក់ព័ន្ធ។ សិក្ខាសាលាថ្នាក់ជាតិនេះ បានផ្តល់ឱកាសយ៉ាងទូលំទូលាយដល់ភាគីពាក់ព័ន្ធក្នុងការផ្តល់យោបល់ត្រលប់ ការពិនិត្យ និងឯកភាពជារួមលើសេចក្តីព្រាងនៃគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន សម្រាប់ជាមគ្គុទ្ទេសក៍ជំនួយស្មារតី និងជាធនធានសម្រាប់អង្គការសហគមន៍មូលដ្ឋាន។

# គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អ
# របស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជា

## ១. សេចក្តីផ្តើម

ក្នុងការចូលរួមអភិវឌ្ឍប្រទេសកម្ពុជា អង្គការសង្គមស៊ីវិល ត្រូវបានចាត់ទុកជាកម្លាំងចលករជម្រុញឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងនិរន្តរភាព។ កិច្ចអន្តរាគមន៍ទាំងឡាយរបស់អង្គការសង្គមស៊ីវិលបានជ្រាបទៅដល់គ្រប់កម្រិត ទាំងថ្នាក់ជាតិ និងសហគមន៍មូលដ្ឋាន។ អង្គការសង្គមស៊ីវិលមានភាពចម្រុះគ្នាជាច្រើន កំពុងធ្វើការនៅកម្ពុជា ដែលរួមមាន សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ អង្គការសហគមន៍មូលដ្ឋាន និងស្ថាប័នផ្សេងៗទៀត។ យោងតាមរបាយការណ៍សិក្សាស្រាវជ្រាវដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក្នុងឆ្នាំ២០១២ និងរបាយការណ៍សិក្សាស្រាវជ្រាវរបស់អង្គការអុកស្វាម ក្នុងឆ្នាំ២០១៤ បានបង្ហាញថា នៅកម្ពុជាមានអង្គការសហគមន៍មូលដ្ឋាន ប្រមាណជាង ២៥,០០០ (ពីរម៉ឺនប្រាំពាន់) ដែលកំពុងបំពេញការងារតាមវិស័យនានានៅតាមមូលដ្ឋានរបស់ខ្លួន។ ភាគច្រើននៃអង្គការសហគមន៍មូលដ្ឋានទាំងអស់នោះមានវត្តមាន និងប្រតិបត្តិការតាមរយៈការជួយគាំទ្រ និងសកម្មភាពអភិវឌ្ឍន៍របស់សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ។ យ៉ាងណាមិញ គេកម្រនឹងជួបប្រទះនូវអង្គការសហគមន៍មូលដ្ឋានឆ្នើម ដែលមានការទទួលស្គាល់ពីសាធារណជន អំពីការអនុវត្តការងារប្រកបដោយ អភិបាលកិច្ចល្អ វិជ្ជាជីវៈ សមត្ថភាពរឹងមាំ ធនធានគ្រប់គ្រាន់ និងនិរន្តរភាពណាស់។ ដូច្នេះហើយកិច្ចអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព និងជាក់ស្តែងពីសំណាក់អង្គការដៃគូពិតជាមានសារៈសំខាន់ណាស់ ដើម្បីគាំទ្រពួកគាត់ឲ្យមានការប្រតិបត្តិបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ទន្ទឹមគ្នានោះដែរ ក៏មានអនុសាសន៍សំខាន់ៗ ពីរបាយការណ៍វាយតម្លៃឯករាជ្យ ពីផលប៉ះពាល់របស់ប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្តនៃអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើឡើងដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ក្នុងឆ្នាំ២០១៣ បានលើកឡើងថា គួរមានកិច្ចអន្តរាគមន៍ និងការចូលរួមគាំទ្រពីអង្គការសង្គមស៊ីវិល ក្នុងការបង្កើតឲ្យមានធនធាន នៃ**គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន** ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹង ក្រម និងបទដ្ឋានស្តីពីអភិបាលកិច្ចល្អ និងប្រតិបត្តិប្រកបដោយវិជ្ជាជីវៈរបស់អង្គការសង្គមស៊ីវិល (Standards of Good Governance and Professional Practices for NGOs in Cambodia)។ គោលការណ៍នេះ នឹងក្លាយជាធនធាន និងឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការលើកកម្ពស់គាំទ្រ និងពង្រឹងសមត្ថភាពអង្គការសហគមន៍មូលដ្ឋានដើម្បីឲ្យការប្រតិបត្តិមានអភិបាលកិច្ចល្អ វិជ្ជាជីវៈ គុណភាព ប្រសិទ្ធភាព និងនិរន្តរភាព។

ចាប់តាំងពីឆ្នាំ២០១៨មក មានកិច្ចប្រជុំជាច្រើនត្រូវបានធ្វើឡើង និងពិភាក្សាពីបញ្ហាផ្សេងៗ រួមមាន ការចូលរួមរបស់ អង្គការសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ និងដៃគូផ្តល់ជំនួយដែលបានគាំទ្រ និងផ្តល់គំនិតផ្តួចផ្តើម ក្នុងការបង្កើត **គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា គឺជាអង្គការសមាជិកភាពដែលមានវ័យចំណាស់ជាងគេមួយនៅកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួល និងពង្រឹងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ លើដំណើរការអភិវឌ្ឍនៅកម្ពុជា។ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ចាប់តាំងពីឆ្នាំ១៩៩០មក ក្នុងការពង្រឹងវិជ្ជាជីវៈ គណនេយ្យភាព កិច្ចសហប្រតិបត្តិការ អភិបាលកិច្ច និងប្រសិទ្ធភាពអភិវឌ្ឍន៍សម្រាប់អង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការងារក្នុងវិស័យផ្សេងៗនៅប្រទេសកម្ពុជា។ ក្នុងដំណើរការតាក់តែងគោលការណ៍ណែនាំនេះ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ និងទទួលបានការគាំទ្រ ហើយត្រូវបានជ្រើសរើសធ្វើជាអ្នកសម្របសម្រួលក្នុងការបង្កើតនូវ **គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**នេះឡើង។ គំនិតផ្តួចផ្តើមប្រកបដោយសារៈប្រយោជន៍នេះ បានទទួលការគាំទ្រពី កម្មវិធីជំនួយអភិវឌ្ឍន៍ផ្ទាល់របស់រដ្ឋាភិបាលអូស្ត្រាលី (Direct Aid Program of the Australian Government) តាមរយៈគម្រោងមួយហៅថា *ការបណ្តុះវប្បធម៌នៃការប្រតិបត្តិល្អ និងនិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន*។

**គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**នេះ មានប្រសិទ្ធភាព និងសារៈប្រយោជន៍ លុះត្រាតែអង្គការសហគមន៍មូលដ្ឋានមានការតាំងចិត្តខ្ពស់ និងយកគោលការណ៍នេះជាមគ្គុទ្ទេសក៍ ទៅប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនក្នុងបរិបទរបស់ខ្លួន ជាពិសេសមានការគាំទ្រយ៉ាងសកម្ម ទាំងស្មារតី បច្ចេកទេស និងហិរញ្ញវត្ថុពីគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា អង្គការជាតិ និងអន្តរជាតិ ដៃគូពាក់ព័ន្ធនានា និងជាពិសេសអាជ្ញាធរមូលដ្ឋាន។

## ២. គោលបំណងនៃគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

គោលការណ៍ណែនាំនេះ បង្កើតឡើងក្នុងគោលបំណងផ្តល់ជាឯកសារមគ្គុទ្ទេសក៍ជំនួយស្មារតីដ៏មានសារៈសំខាន់ដល់អង្គការសហគមន៍មូលដ្ឋានដូចជា ជំនួយក្នុងការពង្រឹងសមត្ថភាពស្ថាប័ន គុណភាពសេវាកម្ម ប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយសមាជិក ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរមូលដ្ឋានជាដើម។ លើសពីនេះទៅទៀត តាមរយៈការប្រើប្រាស់ និងអនុវត្តន៍តាមឯកសារមគ្គុទ្ទេសក៍ជំនួយស្មារតីនេះ វានឹងជួយជម្រុញឲ្យមានការលើកកម្ពស់អភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព និងនិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន ដែលជាការចូលរួមចំណែកលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋសហគមន៍ខ្លួនឯងផ្ទាល់ ក៏ដូចជាការចូលរួមអភិវឌ្ឍសង្គម និងកាត់បន្ថយភាពក្រីក្រ។

## ៣. តើគោលការណ៍ណែនាំនេះមានអ្វីខ្លះ និង ប្រើប្រាស់យ៉ាងដូចម្តេច?

ខ្លឹមសារសំខាន់ៗនៅក្នុង គោលការណ៍នេះចែកចេញជា ៨ ជំពូក រួមមាន៖

**ជំពូកទី១៖ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន**

**ជំពូកទី២៖ ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ**

**ជំពូកទី៣៖ សមាជិកភាព និងការគ្រប់គ្រងសមាជិក**

**ជំពូកទី៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ**

**ជំពូកទី៥៖ គណនេយ្យភាព និងតម្លាភាព**

**ជំពូកទី៦៖ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ**

**ជំពូកទី៧៖ យុទ្ធសាស្រ្ត និងការធានានិរន្តរភាព**

**ជំពូកទី៨៖ ការពង្រឹងសមត្ថភាព និងការយល់ដឹង**

គោលការណ៍ណែនាំទាំង ៨ ជំពូកនេះ គ្របដណ្តប់លើសេចក្តីណែនាំមួយចំនួន ដែលត្រូវបានបង្កើតឡើងជាជំហានៗដើម្បីពិពណ៌នា ថាតើអង្គការសហគមន៍មូលដ្ឋាន គួរអនុវត្តប្រកបដោយគណនេយ្យភាព តម្លាភាព អភិបាលកិច្ចល្អ និងឆ្ពោះទៅរកនិរន្តរភាព យ៉ាងដូចម្តេច នៅក្នុងអង្គការសហគមន៍របស់ពួកគាត់។ ក្នុងជំពូកនីមួយៗមានបែងចែកជាគោលការណ៍ និងសេចក្តីណែនាំលម្អិត តាមគោលការណ៍នីមួយៗ។ លើសពីនេះទៅទៀត គោលការណ៍ខ្លះក៏មានភ្ជាប់នូវឧបសម្ព័ន្ធ (ឯកសារភ្ជាប់ជាមួយ) ដែលជាគម្រូផ្សេងៗ ដើម្បីជំនួយស្មារតីបន្ថែមនៅទំព័រក្រោយៗ (សូមមើលបញ្ជីឧបសម្ព័ន្ធ) ហើយឧបសម្ព័ន្ធគម្រូទាំងនោះ បង្កើតឡើងដោយមិនតំណាងឲ្យអង្គការសហគមន៍មូលដ្ឋានណាមួយទេ។

ដោយសារគោលការណ៍នេះត្រូវបានចាត់ទុកថាជាឯកសារមគ្គុទ្ទេសក៍ ដូច្នេះវាគួរត្រូវបានប្រើប្រាស់ជាការណែនាំសម្រាប់ជំនួយស្មារតី។ វាមិនមែនជាឯកសារតម្រូវដែលអង្គការសហគមន៍មូលដ្ឋានចាំបាច់ត្រូវតែអនុវត្តតាមទាំងស្រុងនោះទេ ប៉ុន្តែយើងទាំងអស់គ្នាមានជំនឿជឿជាក់យ៉ាងមុតមាំថា បើអង្គការសហគមន៍មូលដ្ឋានអនុវត្តតាមគោលការណ៍ណែនាំនេះបានកាន់តែច្រើន នោះប្រសិទ្ធភាព គុណភាព សមត្ថភាព គណនេយ្យភាព និងតម្លាភាពក្នុងស្ថាប័ននោះមានកាន់តែប្រសើរឡើង ព្រមទាំងអាចមាននិរន្តរភាពយូរអង្វែង។

## ៤. ប្រតិបត្តិការ នៃអង្គការសហគមន៍មូលដ្ឋាននាពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា

### ក. នរណាខ្លះត្រូវបានចាត់ទុកជាអង្គការសហគមន៍មូលដ្ឋាន?

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ និងដំណើរក្នុងការបង្កើតគោលការណ៍ណែនាំនេះ យើងឃើញថា អង្គការសហគមន៍មូលដ្ឋានមានច្រើនបែបច្រើនសណ្ឋាន។ ខាងក្រោមនេះជារបកគំហើញនូវសណ្ឋានមួយចំនួននៃអង្គការសហគមន៍មូលដ្ឋាន៖

- ធនាគារស្រូវ
- ធនាគារគោ
- ក្រុមសន្សំប្រាក់ និងឥណទាន
- ក្រុមមិត្តជួយមិត្ត ឬសមាគមមូលដ្ឋាន
- សមាគមប្រើប្រាស់ទឹក
- សហគមន៍នេសាទ
- សហគមន៍ព្រៃឈើ
- សហគមន៍ជនជាតិដើមភាគតិច ជាដើម

## ខ .ចរិកលក្ខណៈរបស់ អង្គការសហគមន៍មូលដ្ឋាន

ជារួមអង្គការសហគមន៍មូលដ្ឋានមានចរិកលក្ខណៈនិងគោលការណ៍ដូចខាងក្រោម៖

- ប្រតិបត្តិការនៅកម្រិតមូលដ្ឋានផ្ទាល់
- ផ្តោតលើសេវាកម្ម និងផលប្រយោជន៍របស់សហគមន៍ខ្លួន និងចូលរួមអភិវឌ្ឍ និងដោះស្រាយបញ្ហាសហគមន៍
- ស្វែងរកមូលនិធិជំនួយពីដៃគូអភិវឌ្ឍន៍ និងកៀរគរធនធានពីសមាជិករបស់ខ្លួន
- ចូលរួមចំណែកអភិវឌ្ឍស្ថាប័ន និងសមាជិកភាព ដោយមានការព្រមព្រៀងស្ម័គ្រចិត្ត
- ការប្រតិបត្តិ និងអនុវត្តការងារ ធ្វើឡើងតាមរយៈគោលការណ៍ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន
- មានរចនាសម្ព័ន្ធ បទបញ្ញាផ្ទៃក្នុង ផែនការជាក់លាក់ (ផែនការប្រចាំឆ្នាំជាដើម)

# បទដ្ឋាន គោលការណ៍ និង
# សេចក្តីណែនាំ

# ជំពូកទី ១

# លក្ខណៈផ្លូវច្បាប់ និងការអភិបាលអង្គការសហគមន៍មូលដ្ឋាន

## គោលការណ៍ណែនាំ ១.១៖ អង្គការសហគមន៍មូលដ្ឋាន មានទស្សនវិស័យ សេចក្តីថ្លែងបេសកកម្ម និងគុណតម្លៃ

### សេចក្តីណែនាំ ១.១.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានសេចក្តីថ្លែងអំពីទស្សនវិស័យ ដែលបង្ហាញអំពី៖

ក) គោលបំណងរបស់ស្ថាប័ន ដែលមានលក្ខណៈទូលំទូលាយ និងអាចធ្វើឲ្យស្ថាប័នរក្សាវត្តមានក្នុងរយៈពេលយូរ។

ខ) ស្ថានភាពនាពេលអនាគត (ក្តីស្រម៉ៃ ឬលទ្ធផលនៃកម្មវិធី ដែលពួកគាត់កំពុងធ្វើការងារទៅលើ)។

### សេចក្តីណែនាំ ១.១.២៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានសេចក្តីថ្លែងអំពីបេសកកម្មដែលបង្ហាញអំពី

ក) គោលដៅ កម្មវិធីស្នូល អ្នកដែលត្រូវបម្រើសេវាកម្ម និងក្រុមគោលដៅ។

ខ) សេចក្តីថ្លែងអំពីបេសកកម្មគួរតែធ្វើឲ្យខ្លី និងមានខ្លឹមសារឆ្លើយតបទៅនឹងទស្សនវិស័យ។

### សេចក្តីណែនាំ ១.១.៣៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានសេចក្តីថ្លែងអំពីគុណតម្លៃ

ក) បង្ហាញនូវអ្វីដែល អង្គការសហគមន៍មូលដ្ឋាន ជឿទុកចិត្តថាជាការប្រតិបត្តិដែលនឹងនាំមកនូវភាពជោគជ័យ ការប្រតិបត្តិល្អ តម្លាភាព និងគណនេយ្យភាព។

ខ) តម្រង់ទិស ជម្រុញដល់សមាជិក និងគណៈកម្មការដឹកនាំ ឲ្យមានទំនុកចិត្ត ក្នុងការប្រតិបត្តិកាតព្វកិច្ចរបស់ខ្លួន។

«គោលការណ៍ណែនាំ ១.២៖ សមាជិក និងគណៈកម្មការត្រូវយល់ដឹង និងអនុវត្តទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ របស់អង្គការសហគមន៍មូលដ្ឋាន

សេចក្តីណែនាំ ១.២.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ ដែលត្រូវបានចូលរួមតាក់តែង យល់ព្រម និងលើកកម្ពស់ដោយសមាជិក និងគណៈកម្មការទាំងអស់

ក) គណៈកម្មការ ទីប្រឹក្សា សមាជិក និងដៃគូពាក់ព័ន្ធចូលរួមក្នុងការកំណត់ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ របស់អង្គការសហគមន៍មូលដ្ឋាន ហើយអនុម័តរួមគ្នា។

ខ) សមាជិកយល់ដឹង និងប្រើប្រាស់ ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ ដើម្បីដឹកនាំការសម្រេចចិត្ត និងសកម្មភាព។

គោលការណ៍ណែនាំ ១.៣៖ យ៉ាងហោចណាស់ អង្គការសហគមន៍មូលដ្ឋាន គួរតែមានការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមូលដ្ឋាន ឬ/និងមន្ទីរពាក់ព័ន្ធ

សេចក្តីណែនាំ ១.៣.១៖ អង្គការសហគមន៍មូលដ្ឋាន ត្រូវធានាថា ខ្លួនបំពេញតាមលក្ខខណ្ឌតម្រូវ ឬ/និង ច្បាប់ដែលពាក់ព័ន្ធនានា

ក) អង្គការសហគមន៍មូលដ្ឋាន គួរស្វែងរកការទទួលស្គាល់ពីថ្នាក់ក្រោមជាតិ ឬ/និងថ្នាក់ជាតិ និងធ្វើការផ្សព្វផ្សាយ និងចែករំលែក នូវលិខិតទទួលស្គាល់នោះ ជាសាធារណៈ រួមទាំងសមាគម អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត និងអ្នកទទួលផលដែលធ្វើការងារជាមួយ។

គោលការណ៍ណែនាំ ១.៤៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានគណៈកម្មការ ដែលមានដំណើរការ

សេចក្តីណែនាំ ១.៤.១៖ អង្គការសហគមន៍មូលដ្ឋាន ត្រូវកំណត់ឲ្យច្បាស់ ពីសមាសភាពគណៈកម្មការ

ក) គណៈកម្មការ គួរមានសមាជិកយ៉ាងតិចបំផុតបីនាក់ ហើយជាចំនួនសេស (ដើម្បីជួយសម្រួលដល់ការធ្វើសេចក្តីសម្រេចចិត្ត) និងធានាបាននូវសមភាពយេនឌ័រ (បុរស និងស្ត្រី)។

ខ) គណៈកម្មការត្រូវជ្រើសរើសចេញពីសមាជិកផ្ទាល់ដោយការបោះឆ្នោត។

គ) អាណត្តិរបស់គណៈកម្មការគួរមាន ២អណត្តិ (មួយអាណត្តិ៥ឆ្នាំ)។

### សេចក្តីណែនាំ ១.៤.២៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានឯកសារពន្យល់ពីមុខងាររបស់គណៈកម្មការច្បាស់លាស់

ក) ព័ត៌មានអំពីសមាសភាពគណៈកម្មការ (អាសយដ្ឋាន មុខងារ និងលេខទំនាក់ទំនង)។

ខ) ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ គឺផ្អែកលើសម្លេង៥០%បូក១ ឬ ២ភាគ៣ នៃសមាជិកអង្គប្រជុំ។

គ) ត្រូវមានកិច្ចប្រជុំជាមួយ គណៈកម្មការ ឬប្រជុំសមាជិកទាំងអស់ ដោយផ្អែកលើលក្ខន្តិកៈរបស់អង្គការសហគមន៍មូលដ្ឋាននីមួយៗ។ បើអាច គណៈកម្មការគួរជួបប្រជុំគ្នាយ៉ាងតិច ៤ ដងក្នុងមួយឆ្នាំ។

ឃ) តំណែង និងវិសាលភាពនៃសិទ្ធិអំណាចសម្រាប់ប្រធាន (ឬសមភាព) និងសមាជិកផ្សេងទៀត ដែលទទួលខុសត្រូវលើមុខងារប្រចាំថ្ងៃរបស់អង្គការសហគមន៍មូលដ្ឋាន។

ង) ការទទួលខុសត្រូវចម្បងរបស់គណៈកម្មការ ដែលគួរលើកឡើងឲ្យបានច្បាស់លាស់អំពីតួនាទីយ៉ាងហោចណាស់រួមមាន៖

- ជ្រើសរើសគណៈកម្មការ
- ចែករំលែកព័ត៌មាន
- បង្កើតគោលនយោបាយសំខាន់ៗ
- រៀបចំរបាយការណ៍វឌ្ឍនភាព
- ត្រួតពិនិត្យផែនការថវិកា និងផែនការការងារ
- កៀរគរធនធាននានា រួមទាំងថវិកា
- ការផ្តួចផ្តើម និងបង្កើនមុខរបរដល់សមាជិក
- សម្របសម្រួល និងដោះស្រាយបញ្ហានៅក្នុងសហគមន៍
- ពិនិត្យមើលនីតិវិធី សម្របសម្រួលក្នុងការធ្វើវិសោធនកម្មសម្រាប់បទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិសម្រាប់ការរំលាយ អង្គការសហគមន៍មូលដ្ឋាន

### សេចក្តីណែនាំ ១.៤.៣៖ អង្គការសហគមន៍មូលដ្ឋានគួរ

ក) កំណត់ឲ្យច្បាស់អំពីរចនាសម្ព័ន្ធរបស់សហគមន៍មូលដ្ឋាន រួមមាន គណៈកម្មការ លេខាធិការដ្ឋាន និងសមាជិក ។

ខ) ធ្វើតាមនីតិវិធីដែលមានចែងនៅក្នុងលក្ខន្តិកៈ បទបញ្ញាតិ បទបញ្ជាផ្ទៃក្នុង ឬគោលការណ៍នានា របស់សហគមន៍ខ្លួន នូវរាល់ការផ្លាស់ប្តូរសមាជិកនៅក្នុងរចនាសម្ព័ន្ធ ជាពិសេសគណៈកម្មការ។

## គោលការណ៍ណែនាំ ១.៥៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬគោលការណ៍ជាលាយលក្ខណ៍អក្សរយ៉ាងច្បាស់លាស់សម្រាប់ដឹកនាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

### សេចក្តីណែនាំ ១.៥.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬគោលការណ៍ដែលរួមបញ្ចូលនូវខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

ក) ឈ្មោះ ទស្សនវិស័យ បេសកកម្ម គុណតំលៃ និងគោលបំណងរបស់អង្គការសហគមន៍មូលដ្ឋាន។

ខ) អាសយដ្ឋានជាក់លាក់សម្រាប់ទំនាក់ទំនង ជាមួយអង្គការដៃគូ និងសហគមន៍ដែលធ្វើការងារជាមួយ។

គ) រចនាសម្ព័ន្ធ របស់អង្គការសហគមន៍មូលដ្ឋាន

ឃ) មហាសន្និបាតប្រចាំឆ្នាំ។ ចំនួនសមាជិកត្រូវបានតម្រូវឲ្យមានគ្រប់កូរ៉ុម៥០%+១ និងគិតពីសមភាពយេនឌ័រ (កូរ៉ុមគឺជាចំនួន ឬសម្លេងដែលអាចសម្រេចចិត្តលើដំណើរការកិច្ចប្រជុំជាផ្លូវការបាន)។

ង) សមាជិក សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក

ច) ការទទួលខុសត្រូវលើរបាយការណ៍ចុះបញ្ជីស្នាម និងរបាយការណ៍ហិរញ្ញវត្ថុ។

ឆ) អង្គការសហគមន៍មូលដ្ឋាន មិនមែនជាស្ថាប័ននយោបាយទេ ហើយនៅពេលដែលបិទ ឬរំលាយ ទ្រព្យសម្បត្តិ ឬធនធានដែលនៅសេសសល់នឹងត្រូវបែងចែក ដោយផ្អែកទៅតាមលក្ខន្តិកៈ ឬគោលការណ៍ ។

ជ) លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬគោលការណ៍របស់អង្គការសហគមន៍មូលដ្ឋាន ត្រូវតែបង្កើតឡើង ពិនិត្យមើលឡើងវិញ និងអនុម័តដោយក្រុមប្រឹក្សាយោបល់ ឬគណៈកម្មការសាមី។

## គោលការណ៍ណែនាំ ១.៦៖ អង្គការសហគមន៍មូលដ្ឋាន អាចរកប្រាក់ចំណូល ឬប្រាក់ចំណេញប្រភពហិរញ្ញវត្ថុផ្សេងៗ និងប្រើប្រាស់ធនធានទាំងនោះប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព

### សេចក្តីណែនាំ ១.៦.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវ

ក) មានភាពស្មោះត្រង់ តម្លាភាព សមភាព សមធម៌

ខ) បង្កើតគម្រោងកម្មវិធី បង្កើន ឬពង្រីកមុខរបរ ដើម្បីរកប្រាក់ចំណេញ ឬប្រាក់ចំណូលមកពង្រឹងអង្គការសហគមន៍មូលដ្ឋាន និងកម្មវិធីរបស់ខ្លួន ដើម្បីធានាបាននូវនិរន្តរភាពនៅក្នុងអង្គការសហគមន៍មូលដ្ឋាន។

គ) ស្វែងរកការឧបត្ថម្ភពីអង្គការដៃគូនានា រាជរដ្ឋាភិបាល វិភាគទានពីសប្បុរសជន ពីសមាជិករបស់ខ្លួន ឬសេវាកម្មស្របច្បាប់ផ្សេងៗ។

# ជំពូកទី ២

# ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ

## គោលការណ៍ណែនាំ ២.១៖ អង្គការសហគមន៍មូលដ្ឋាន ត្រូវមានទំនាក់ទំនង និងកិច្ចសហការ ទាំងខាងក្នុង និងខាងក្រៅ (ខាងក្នុងធ្វើអ្វីខ្លះ? និងខាងក្រៅធ្វើអ្វីខ្លះ ជាមួយអ្នកណា?)

### សេចក្តីណែនាំ ២.១.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានទំនាក់ទំនង និងកិច្ចសហការខាងក្នុងដែលមានប្រសិទ្ធភាព និងគួរធ្វើឡើងតាមរយៈវិធីដូចខាងក្រោម៖

ក) ព័ត៌មានស្តីពីការសម្រេចចិត្តចុងក្រោយ ដែលមានផលប៉ះពាល់ដល់សមាជិក និងជះឥទ្ធិពលដល់អង្គការសហគមន៍មូលដ្ឋាន និងកម្មវិធីរបស់ខ្លួន ត្រូវតែចែករំលែកជាមួយសមាជិកបន្ទាប់ពីកិច្ចប្រជុំ តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា ក្តារព័ត៌មាន បណ្តាញសង្គម ជាដើម។

ខ) គណៈកម្មការ គួររៀបចំកិច្ចប្រជុំជាមួយសមាជិកយ៉ាងហោចណាស់ បីខែម្តង ហើយកិច្ចប្រជុំក៏ត្រូវបានកត់ត្រាទុកជាឯកសារកាលប្បវត្តិ។ សូមមើល (ឧបសម្ព័ន្ធគម្រូ២ ការសម្របសម្រួល កិច្ចប្រជុំប្រកបដោយប្រសិទ្ធភាពសម្រាប់អង្គការសហគមន៍មូលដ្ឋាន) ជាជំនួយស្មារតី។

គ) អង្គការសហគមន៍មូលដ្ឋានចំណាយពេលវេលាដើម្បីឆ្លុះបញ្ចាំងទំនាក់ទំនងការងាររបស់សមាជិក និងកសាងបណ្តាញការធ្វើការងារដើម្បីលើកកម្ពស់សាមគ្គីភាព និងកិច្ចសហការទំនាក់ទំនងទាំងខាងក្នុង និងខាងក្រៅ។

ឃ) អង្គការសហគមន៍មូលដ្ឋានរៀបចំកិច្ចប្រជុំ ដូចជាការធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពប្រចាំឆ្នាំជាមួយដៃគូអភិវឌ្ឍន៍ សហគមន៍គោលដៅ និងភាគីពាក់ព័ន្ធផ្សេងទៀត។ នៅក្នុងកិច្ចប្រជុំនោះ អង្គការសហគមន៍មូលដ្ឋានគួរចែករំលែកព័ត៌មានដែលពាក់ព័ន្ធ រួមទាំងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ព័ត៌មានអំពីមូលនិធិ និងសកម្មភាពគម្រោង ឬកម្មវិធី។

### សេចក្តីណែនាំ ២.១.២៖ អង្គការសហគមន៍មូលដ្ឋានត្រូវទំនាក់ទំនង និងកិច្ចសហការល្អជាមួយអ្នកពាក់ព័ន្ធខាងក្រៅ

ក) អង្គការសហគមន៍មូលដ្ឋាន គួរចូលរួមប្រជុំទៀងទាត់ជាមួយស្ថាប័នផ្សេងៗ ទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ រួមមានផែនការ និងកម្មវិធីវិនិយោគឃុំ ឬសង្កាត់ ស្រុកឬខណ្ឌ។

ខ) ចូលជាសមាជិក ឬបណ្តាញនានា ដែលបង្កើតដោយរដ្ឋ ឬវិស័យឯកជន ឬស្ថាប័នផ្សេងៗ ដែលមានទិសដៅតែមួយ មានបេសកកម្មរួម និងផលប្រយោជន៍រួម។

គ) អង្គការសហគមន៍មូលដ្ឋានចងបណ្តាញថ្នាក់មូលដ្ឋាន និងថ្នាក់មូលដ្ឋានដូចគ្នា ថ្នាក់ខេត្ត ថ្នាក់ជាតិ និងអន្តរជាតិ។

## គោលការណ៍ណែនាំ ២.២៖ របាយការណ៍ប្រចាំឆ្នាំត្រូវធ្វើឡើង និងត្រូវមានសម្រាប់ទាំងខាងក្នុង និងខាងក្រៅ

### សេចក្តីណែនាំ ២.២.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានរបាយការណ៍ប្រចាំឆ្នាំ ដែលមានព័ត៌មានសំខាន់ៗដូចខាងក្រោម៖

ក) ព័ត៌មានមូលដ្ឋានអំពីអង្គការ ឧ. ឈ្មោះអង្គការ លេខចុះបញ្ជី(បើមាន) ឆ្នាំហិរញ្ញវត្ថុដែលទាក់ទងនឹងរបាយការណ៍ ទំនាក់ទំនងលម្អិត ឧ. អាសយដ្ឋាន លេខទូរសព្ទ និងទូរសារ។ ការពិពណ៌នាអំពីរចនាសម្ព័ន្ធអង្គការសហគមន៍មូលដ្ឋាន និងសមាជិក។

ខ) ការពិពណ៌នាអំពីទស្សនៈវិស័យ បេសកកម្ម និងគោលបំណងរបស់អង្គការ

គ) ឈ្មោះរបស់សមាជិកនៃគណៈកម្មការ ក្នុងអំឡុងពេលធ្វើរបាយការណ៍ និងរក្សាឯកសារទុកទៅតាមលក្ខន្តិកៈដែលបានកំណត់។

ឃ) សមិទ្ធិផលសំខាន់ៗទាំងបរិមាណ និងព័ត៌មានបែបគុណភាព ការផ្លាស់ប្តូរសំខាន់ៗ ព្រឹត្តិការណ៍សំខាន់ណាមួយ និងភាពវិវឌ្ឍណាមួយដែលអាចកើតមាននាពេលអនាគត។

ង) របាយការណ៍ហិរញ្ញវត្ថុសង្ខេប (ប្រាក់ចំណូល ការចំណាយ និងសមតុល្យដែលនៅសល់)។

ច) ត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទដោយគណៈកម្មការ

ឆ) របាយការណ៍ ឯកសារគំរោងកម្មវិធី និងសំណើរគួរត្រូវផ្តល់ជូនទៅមន្ទីរជំនាញពាក់ព័ន្ធ អាជ្ញាធរ បណ្តាញ អង្គការដៃគូផ្សេងៗ និងប្រជាពលរដ្ឋក្នុងសហគមន៍ និងចាំបាច់ត្រូវតែចែកជូនដល់សមាជិករបស់ខ្លួន។

ជ) របាយការណ៍ទាំងនេះគួរត្រូវបានរក្សាទុករយៈពេល ៥ ឆ្នាំ និងរបាយការណ៍ត្រួតពិនិត្យវាយតម្លៃហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធផ្សេងៗ (គួរមានទូដាក់ឯកសារនៅក្នុងអង្គការសហគមន៍មូលដ្ឋានយ៉ាងតិច១០ឆ្នាំ)។

# ជំពូកទី ៣
# សមាជិកភាព និងការគ្រប់គ្រងសមាជិក

**គោលការណ៍ណែនាំ ៣.១៖ អង្គការសហគមន៍មូលដ្ឋានមានការចូលរួមជាសមាជិកដោយស្ម័គ្រចិត្ត មិនរើសអើង មិនប្រកាន់និន្នាការ និងមិនបម្រើផលប្រយោជន៍គណបក្សនយោបាយ**

**សេចក្តីណែនាំ ៣.១.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង ដែលកំណត់យ៉ាងច្បាស់លាស់អំពីបែបបទនៃការចូលជាសមាជិកភាព ដែលមានចែងចំណុចមួយចំនួនដូចខាងក្រោមនេះ៖**

ក) សមាជិក មានការចូលរួមដោយស្ម័គ្រចិត្ត

ខ) លក្ខខ័ណ្ឌជ្រើសរើសសមាសភាព

គ) សមាជិកចូលរួមឈរឈ្មោះបោះឆ្នោតបែបប្រជាធិបតេយ្យ

ឃ) សមាជិកភាព និងសិទ្ធិ

ង) កាតព្វកិច្ច និងតួនាទីរបស់សមាជិក

ច) ការកំណត់តម្លៃសមាជិកភាព

ឆ) កំណត់នូវគោលការណ៍ដែលសមាជិកត្រូវទទួលបានអត្ថប្រយោជន៍ ពីការចូលជាសមាជិកភាព និងការបង់វិភាគទាន (សូមមើល គម្រូ៩៖ គោលការណ៍ប្រើប្រាស់ថវិកាសមាជិកភាពនៅក្នុងឧបសម្ព័ន្ធគម្រូ៣៖ គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ)។

ជ) សមាជិក ចូលរួមប្រជុំ និងធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ តាមរយៈការបោះឆ្នោត ដោយសម្លេង ៥០%+១ ឬមតិភាគច្រើន ជាពិសេសការធ្វើផែនការអភិវឌ្ឍន៍អង្គការសហគមន៍មូលដ្ឋាន និងចូលរួមថែរក្សានូវសម្បត្តិរួមក្នុងមូលដ្ឋាន។

ឈ) អង្គការសហគមន៍មូលដ្ឋានមានយុទ្ធសាស្ត្រកៀរគរធនធាន និងសមាជិកភាពជាពិសេសលើកកម្ពស់ការចូលរួមពី បុរស ស្ត្រី យុវជន កុមារ និងជនពិការ ចូលជាសមាជិក។

ញ) ការប្រជុំសមាជិក អង្គការសហគមន៍មូលដ្ឋាន

# ជំពូកទី ៤

# ការគ្រប់គ្រងហិរញ្ញវត្ថុ

## គោលការណ៍ណែនាំ ៤.១៖ គោលការណ៍ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ

### សេចក្តីណែនាំ ៤.១.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវបង្កើតគោលការណ៍ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ ហើយគួរអនុលោមតាមខ្លឹមសារសំខាន់ៗដូចមានចែងខាងក្រោម៖

ក) តួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញវត្ថុ

ខ) កំណត់រូបិយប័ណ្ណ (ក្រដាសប្រាក់រៀល ឬដុល្លា) និងកំណត់អត្រាប្តូរប្រាក់

គ) គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ (សូមមើលឧបសម្ព័ន្ធគម្រូ ៣ គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ)



- នីតិវិធីនៃប្រតិបត្តិការហិរញ្ញវត្ថុ
- ការរក្សាទុកឯកសារឲ្យមានសុវត្ថិភាព និងការចែករំលែកព័ត៌មានទៅសមាជិក
- នីតិវិធីលទ្ធកម្ម (សម្រង់តម្លៃ និងការដេញថ្លៃ)
- សិទ្ធិក្នុងការអនុម័ត និងការអនុម័តការចំណាយ
- ការគ្រប់គ្រងចំណូល និងចំណាយ

ឃ) គោលការណ៍សន្សំ ខ្ចី និងសងប្រាក់ និងគោលការណ៍បែងចែកភាគលាភ និងការប្រាក់ (សូមមើលគម្រូ២ និងគម្រូ៣ ក្នុងឧបសម្ព័ន្ធគម្រូ៣៖ គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ ) ជាជំនួយស្មារតី

ង) ការរៀបចំផែនការថវិកា

ច) របាយការណ៍ចំណូល និងចំណាយត្រូវតែកំណត់ពីប្រភពដែលផ្តល់ឲ្យបានច្បាស់លាស់។

ឆ) ការត្រួតពិនិត្យផ្ទៃក្នុងលើចំណូល និងចំណាយប្រចាំឆ្នាំ ដោយគណៈកម្មការផ្ទៃក្នុងឯករាជ្យ។

ជ) បើមានលទ្ធភាព គួរមានការធ្វើសវនកម្មដោយសវនករពីខាងក្រៅ (គួរកំណត់ឲ្យច្បាស់លាស់ថាចាប់ពីចំនួនប៉ុន្មាន រៀល ឬដុល្លា? តាមលទ្ធភាពជាក់ស្តែង) ។ គួរពិចារណាទៅលើចំណុចដែលជាកាតព្វកិច្ចចាំបាច់ ជាលទ្ធភាពជាក់ស្តែង និងជាជម្រើសនៅក្នុងការធ្វើសវនកម្ម។ គួរតែមានការកំណត់ និងសម្រេចចិត្តរួមគ្នានៅក្នុងអង្គការសហគមន៍មូលដ្ឋាន។

# ជំពូកទី ៥

# គណនេយ្យភាព និងតម្លាភាព

### គោលការណ៍ណែនាំ ៥.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវជម្រុញ និងលើកទឹកចិត្ត នូវការចូលរួមរបស់សមាជិក ឬប្រជាពលរដ្ឋនៅគ្រប់ដំណាក់កាលនៃដំណើរការបង្កើតគម្រោង ឬកម្មវិធី

#### សេចក្តីណែនាំ ៥.១.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមាននីតិវិធី និងដំណើរការនៃការបង្កើតគម្រោងកម្មវិធី



ក) រាល់ដំណាក់កាលនៃដំណើរការបង្កើតគម្រោង ឬកម្មវិធី គួរមានការចូលរួមពីសមាជិក ឬប្រជាពលរដ្ឋគោលដៅ។ ឧទាហរណ៍៖ ការវាយតម្លៃដំបូង ការរៀបចំផែនការ ការអនុវត្តន៍ និងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ខ) អង្គការសហគមន៍មូលដ្ឋានលើកទឹកចិត្តឲ្យសមាជិក ឬប្រជាពលរដ្ឋគោលដៅទទួលខុសត្រូវលើការអនុវត្តន៍គម្រោង ឬកម្មវិធី និងចូលរួមក្នុងការត្រួតពិនិត្យកម្មវិធី ព្រមទាំងផ្តល់ឱកាសសម្រាប់ពួកគេដើម្បីលើកឡើងនូវបញ្ហាផ្សេងៗ។

### គោលការណ៍ណែនាំ ៥.២ ៖ ការប្រកាសអំពីទំនាស់ផលប្រយោជន៍

#### សេចក្តីណែនាំ ៥.២.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវ

ក) មានគោលការណ៍ ឬបទបញ្ជាផ្ទៃក្នុងស្តីពីទំនាស់ផលប្រយោជន៍ ដែលត្រូវបង្កើតឡើង និងសម្រេចចិត្តដោយគណៈកម្មការ ឬសមាជិកក្រុម ដើម្បីការពារនូវផលប្រយោជន៍រួម និងបង្កើនទំនុកចិត្ត សាមគ្គីភាព ភាពស្មោះត្រង់ និងតម្លាភាព នៅក្នុងក្រុម និងសហគមន៍ផ្ទាល់។ សូមមើល ឧបសម្ព័ន្ធគម្រូ៩៖ គោលការណ៍បង្ការទំនាស់ផលប្រយោជន៍ ជាគម្រូជំនួយស្មារតី។

## គោលការណ៍ណែនាំ ៥.៣ ៖ យន្តការផ្តល់ព័ត៌មានត្រលប់ ឬបណ្តឹង

### សេចក្តីណែនាំ ៥.៣.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធដើម្បីបញ្ចេញព័ត៌មានត្រលប់ ឬបណ្តឹងតវ៉ា

ក) យន្តការប្តឹងតវ៉ានានាដូចជាកិច្ចប្រជុំចំហ ប្រអប់សំបុត្រ ឬលេខទូរសព្ទ (ដែលរក្សាការសំងាត់)។ល។ ត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ឱកាសសម្រាប់សមាជិកក្រុម និងអ្នកទទួលផលដើម្បីប្តឹងតវ៉ាក្នុងករណីចាំបាច់។ ឧបសម្ព័ន្ធគម្រូ៥៖ ទម្រង់ផ្តល់ព័ត៌មានត្រលប់ ឬបណ្តឹងតវ៉ា។

ខ) គណៈកម្មការ ត្រូវបង្កើតយន្តការដោះស្រាយនូវបញ្ហា ដែលកើតឡើងនៅក្នុងអង្គការសហគមន៍ក៏ដូចជានៅក្នុងសហគមន៍ផ្ទាល់។ ក្នុងករណីចាំបាច់គួរមានកិច្ចសហការជាមួយអាជ្ញាធរ មន្ទីរជំនាញពាក់ព័ន្ធ ឬអង្គការដៃគូ។

# ជំពូកទី ៦

# ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ

## គោលការណ៍ណែនាំ ៦.១៖ អង្គការសហគមន៍មូលដ្ឋានរៀបចំ តាក់តែង អនុវត្ត តាមដាន និងវាយតម្លៃលើផែនការយុទ្ធសាស្ត្រ កម្មវិធី ឬគម្រោង

### សេចក្តីណែនាំ ៦.១.១៖ អង្គការសហគមន៍មូលដ្ឋានគួរ៖

ក) សិក្សាស្រាវជ្រាវ និងវិភាគបញ្ហាជាក់ស្តែងនៅក្នុងអង្គការរបស់ខ្លួន និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដើម្បីឲ្យគេយល់ ក្នុងការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រ (រយៈពេលវែង ឬខ្លី)។



ខ) មាននីតិវិធី ក្របខ័ណ្ឌ និងផែនការសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ លើកម្មវិធី ឬគម្រោង (ឧទាហរណ៍៖ ផែនការប្រតិបត្តិការប្រចាំឆ្នាំ ដែលសមស្រប ផែនការសកម្មភាព បញ្ជីត្រួតពិនិត្យ ការសង្កេតលើកម្មវិធី ឬប្រតិបត្តិការ របាយការណ៍។ល។)

សូមមើល ឧបសម្ព័ន្ធគម្រូ៦៖ ទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យផែនការសកម្មភាព ជាគម្រូជំនួយស្មារតី។

គ) រៀបចំការវាយតម្លៃខាងក្នុងចំពោះកម្មវិធី ឬគម្រោងរបស់ខ្លួនដោយមានការចូលរួមពីសមាជិកក្រុមអ្នកទទួលផល និងភាគីពាក់ព័ន្ធផ្សេងទៀតជារៀងរាល់ឆ្នាំ ឬនៅពាក់កណ្តាលអាណត្តិនៃកម្មវិធី ឬគម្រោង ដើម្បីរៀនសូត្រពីអ្វីដែលបានធ្វើ និងកែលម្អផែនការ បើសិនជាមានឧបសគ្គ។

ឃ) បន្តលើកកម្ពស់កម្មវិធី ឬគម្រោងរបស់ខ្លួនដោយផ្អែកលើលទ្ធផលរកឃើញ និងអនុសាសន៍នៅក្នុងរបាយការណ៍វាយតម្លៃ។

# ជំពូកទី ៧

# យុទ្ធសាស្ត្រ និងការធានានិរន្តរភាព

## គោលការណ៍ណែនាំ ៧.១៖ ការរៀបចំផែនការ បង្កើតសេវាកម្ម ឬបង្កើនមុខរបរ

### សេចក្តីណែនាំ ៧.១.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានផែនការ និងសេវាកម្មច្បាស់លាស់

ក) អង្គការសហគមន៍មូលដ្ឋានធ្វើការសិក្សាពីលទ្ធភាព និងឱកាសក្នុងការផ្តល់សេវាកម្មអាជីវកម្មទីផ្សារ របស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីវាយតម្លៃសេវាកម្មផ្សេងៗក្នុងបរិបទសហគមន៍ខ្លួន ទាំងតម្រូវការរបស់អ្នកទទួលផលនានា។



ខ) ប្រើប្រាស់ព័ត៌មាន ឬលទ្ធផលពីការវាយតម្លៃដើម្បីរៀបចំផែនការជាក់លាក់ ដើម្បីពិនិត្យមើលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង សេវាកម្ម ការទំនាក់ទំនងរបស់អង្គការសហគមន៍មូលដ្ឋានជាមួយភាគីពាក់ព័ន្ធនានា របស់អង្គការសហគមន៍មូលដ្ឋានដើម្បីផ្លាស់ប្តូរការគ្រប់គ្រងឲ្យកាន់តែមានប្រសិទ្ធភាព។

គ) វិភាគបញ្ហា និងតម្រូវការនៅក្នុងមូលដ្ឋានហើយនិងបង្កើនសកម្មភាព ឬមុខរបរដើម្បីបង្កើនប្រាក់ចំណូលនៅក្នុងក្រុម តាមរយៈមុខរបរជាលក្ខណៈគ្រួសារ ឬមុខរបរខ្នាតតូចផ្សេងៗតាមលទ្ធភាព និងធនធានដែលមានស្រាប់។

ឃ) ស្វែងរកមូលនិធិ ឬការគាំទ្រពីខាងក្រៅ តាមរយៈម្ចាស់ជំនួយ អង្គការដៃគូ សប្បុរសជននានា និងថវិកាជាតិដែលគាំទ្រដោយសង្កាត់ ឬឃុំ ជាដើម។

ង) ផ្សារភ្ជាប់ផែនការសហគមន៍មូលដ្ឋានជាមួយនឹងផែនការវិនិយោគឃុំ ឬសង្កាត់ និងការកៀរគរធនធានសហគមន៍

## គោលការណ៍ណែនាំ ៧.២៖ ការត្រួតពិនិត្យ និងលើកកម្ពស់គុណភាព និងសុវត្ថិភាពសេវាកម្ម និងផលិតផលរបស់សហគមន៍

### សេចក្តីណែនាំ ៧.២.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវលើកកម្ពស់គុណភាពសេវាកម្ម និងផលិតផលខ្លួនជាប្រចាំ

ក) អង្គការសហគមន៍មូលដ្ឋានចាំបាច់ត្រូវមានប្រព័ន្ធគ្រប់គ្រង និងដំណើរការផ្តល់សេវាកម្ម និងផលិតផលប្រកបដោយសុវត្ថិភាព និងគុណភាពខ្ពស់ ព្រមទាំងសម្រេចឲ្យបាននូវគោលដៅ និងគោលបំណងរបស់អង្គការ រួមទាំងការវាយតម្លៃ ដើម្បីឲ្យកាន់តែមានភាពប្រសើរឡើង និងត្រៀមខ្លួនសម្រាប់បង្ការនូវ មហន្តរាយ និងភាពអាសន្ន និងលើកកម្ពស់សុវត្ថិភាពអតិថិជន ឬពលរដ្ឋជាប្រចាំ។

ខ) អង្គការសហគមន៍មូលដ្ឋានត្រូវធ្វើការត្រួតពិនិត្យផ្ទៃក្នុងលើចំណូល និងចំណាយប្រចាំឆ្នាំដោយគណៈកម្មការផ្ទៃក្នុងឯករាជ្យ ហើយបើមានលទ្ធភាព គួរមានការធ្វើសវនកម្មដោយសវនករពីខាងក្រៅ

គ) អង្គការសហគមន៍មូលដ្ឋានមានយុទ្ធសាស្រ្តដើម្បីធានាគុណភាព និងនិរន្តរភាព

# ជំពូកទី ៨
# ការពង្រឹងសមត្ថភាព និងការយល់ដឹង

## គោលការណ៍ណែនាំ ៨.១៖ ការយល់ដឹង និងសមត្ថភាព

### សេចក្តីណែនាំ ៨.១.១៖ អង្គការសហគមន៍មូលដ្ឋានត្រូវមានសមត្ថភាពគ្រប់គ្រងអង្គការ និងការយល់ដឹងអំពីទីផ្សារ

ក) គណៈកម្មការ និងសមាជិកអង្គការសហគមន៍មូលដ្ឋាន ត្រូវកំណត់ពីតម្រូវការកសាងសមត្ថភាពរបស់ខ្លួន មានឆន្ទៈ និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗដែលគាំទ្រដោយតួអង្គពាក់ព័ន្ធ។ ជាមូលដ្ឋាន អង្គការសហគមន៍មូលដ្ឋានត្រូវស្វែងយល់ពីសិទ្ធិ និងច្បាប់ ឬគោលការណ៍ផ្សេងៗដូចជាលទ្ធិប្រជាធិបតេយ្យ យេនឌ័រ អភិបាលកិច្ចល្អ ការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍកម្មវិធីរបស់ខ្លួន ក៏ដូចជាសហគមន៍ផ្ទាល់។

ខ) គណៈកម្មការ និងសមាជិក ត្រូវយល់ដឹងឲ្យច្បាស់នូវតួនាទី និងការទទួលខុសត្រូវហើយអនុវត្តតួនាទីនោះប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។

គ) សិក្សាស្វែងរកទីផ្សារ និងឱកាសទីផ្សារដែលទាក់ទងនឹងផលិតផលនិងសេវាកម្មរបស់ខ្លួន។

## គោលការណ៍ណែនាំ ៨.២៖ ការសម្របសម្រួល និងការគ្រប់គ្រងអង្គការសហគមន៍មូលដ្ឋាន

### សេចក្តីណែនាំ ៨.២.១៖ គណៈកម្មការរបស់អង្គការសហគមន៍មូលដ្ឋានត្រូវ

ក) ពង្រឹងសមត្ថភាពបន្ថែមលើជំនាញសម្របសម្រួលក្នុងកិច្ចប្រជុំផ្សេងៗរួមទាំងការធ្វើផែនការថវិកា និងផែនការសកម្មភាព ជាពិសេសជំនាញឯកទេសតាមវិស័យរបស់ខ្លួន។

ខ) មានផែនការពង្រឹងសមត្ថភាពបន្ថែម លើជំនាញដឹកនាំ និងគ្រប់គ្រងអង្គការសហគមន៍មូលដ្ឋាន និងកម្មវិធី។

គ) មានផែនការពង្រឹងសមត្ថភាពបន្ថែមដល់សមាជិកខ្លួនពីការគ្រប់គ្រង ការដឹកនាំ និងជំនាញផ្សេងៗ និងមានការតាមដានត្រួតពិនិត្យទៅលើផែនការនោះ។

ឃ) រក្សាទុករាល់ឯកសារសំខាន់ផ្សេងៗ និងផ្សព្វផ្សាយព័ត៌មានទៅសមាជិករបស់ខ្លួន។

# សទ្ទានុក្រម

| | |
|---|---|
| **ការប្រតិបត្តិល្អ** | កម្មវិធីមួយដែលបង្កើតនូវជំនាញចាំបាច់ ដើម្បីអភិវឌ្ឍនូវស្ថាប័នដែលមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង ដឹកនាំ និងគោលនយោបាយ និងដំណើការសមស្រប ដើម្បីធានានូវការប្រតិបត្តិដែលមានប្រសិទ្ធភាព និងសម្រេចបាននូវទស្សនវិស័យ បេសកកម្ម និងគោលដៅរបស់ខ្លួន។ |
| **កូរ៉ុម** | ចំនួនអប្បបរមា ឬតិចបំផុតនៃសមាជិកដែលត្រូវតែមានវត្តមាននៅក្នុងកិច្ចប្រជុំណាមួយ ដើម្បីឲ្យកិច្ចប្រជុំនោះ អាចដំណើរការជាផ្លូវការទៅបាន និងមានសុពលភាព។ ជាទូទៅ កូរ៉ុម សម្រាប់កិច្ចប្រជុំរបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន គឺត្រូវតែមានវត្តមានយ៉ាងហោចណាស់ ៥០%+១ នៃសមាជិក គណៈកម្មការ។ |
| **ក្រុមប្រឹក្សាយោបល់** | ជាក្រុមអ្នកស្ម័គ្រចិត្តដែលមានចំណេះដឹងសមស្រប និងបទពិសោធន៍ការងារដែលពាក់ព័ន្ធទៅនឹងការងារសហគមន៍មូលដ្ឋាន ដើម្បីផ្តល់ដំបូន្មានយុទ្ធសាស្ត្រដល់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន។ ក្រុមប្រឹក្សាយោបល់មិនមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត ឬទទួលខុសត្រូវចំពោះមុខច្បាប់ ដូចក្រុមប្រឹក្សាភិបាលទេ។ |
| **គណនេយ្យភាព** | ការទទួលខុសត្រូវចំពោះសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពរបស់ខ្លួនជាមួយនឹងអង្គការសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធផ្សេងៗ។ |
| **គណៈកម្មការ** | ជាក្រុមមនុស្សដែលត្រូវបានជ្រើសរើសឡើងដោយសមាជិកក្រុម សម្រាប់តួនាទី និងការទទួលខុសត្រូវជាក់លាក់របស់អង្គការសហគមន៍មូលដ្ឋាន។ |
| **គោលការណ៍ណែនាំ** | ដំបូន្មាន ឬអនុសាសន៍ដែលបង្ហាញពីវិធីសាស្ត្រ ដើម្បីបំពេញការងារអ្វីមួយ ឬគួរមានវិធានការបែបណាចំពោះកាលៈទេសៈណាមួយ ដើម្បីសម្រេចបាននូវគុណភាព និងប្រសិទ្ធភាព។ |

**គុណតម្លៃ** ជំនឿដែលដក់ជាប់នៅក្នុងខ្លួនរបស់បុគ្គលម្នាក់ៗ ឬក្រុមមនុស្ស។ ជាទូទៅ គុណតម្លៃត្រូវបានគេប្រើសម្រាប់ជួយបុគ្គលិកដើម្បីកំណត់អត្តសញ្ញាណ និងភ្ជាប់ជាមួយនឹងក្រុមគោលដៅ ដើម្បីរំលឹកបុគ្គលិកអំពីអាទិភាព និងគោលដៅរបស់ខ្លួន។

**គោលដៅ** ជាលទ្ធផលដែលអាចធ្វើការអង្កេត និងវាស់វែងបាន ហើយមានគោលបំណងមួយ ឬច្រើន ដែលនឹងត្រូវបានសម្រេចក្នុងរយៈពេលកំណត់ណាមួយ។ ការកំណត់គោលដៅ អាចមានច្រើនជាងមួយ ដែលផ្តោតទៅលើការផ្លាស់ប្តូរជាវិជ្ជមាន និងឆ្លើយតបទៅនឹងទស្សនវិស័យរបស់អង្គការ ត្រូវមានភាពច្បាស់លាស់ អាចវាស់វែងបាន និងអាចសម្រេចបាន។ គោលដៅនីមួយៗ ត្រូវបានបំពេញទៅតាមពេលវេលា និងធនធានខុសៗគ្នា។

**គោលបំណង** ជាលទ្ធផលជាក់លាក់ដែលស្ថាប័នចង់សម្រេចបានក្នុងរយៈពេលណាមួយ និងជាមួយធនធានដែលអាចប្រើប្រាស់បាន។ ជាទូទៅគោលបំណងមានលក្ខណៈជាក់លាក់ និងងាយស្រួលវាស់វែងជាងគោលដៅ។ គោលបំណងគឺជាលទ្ធផលនៃសកម្មភាពដោយផ្តោតលើលក្ខណៈប្រាំយ៉ាងគឺ ភាពជាក់លាក់ អាចវាស់វែងបាន អាចទទួលជោគជ័យ ពិតប្រាកដ និងមានពេលវេលាកំណត់។

**ដៃគូអភិវឌ្ឍន៍** ជាស្ថាប័ន ឬប្រទេសដែលជាម្ចាស់ជំនួយ ។ ម្ចាស់ជំនួយ គឺជាបុគ្គល ឬនរណាម្នាក់ ដែលមានទឹកចិត្តមនុស្សធម៌ផ្តល់ជាជំនួយដើម្បីការអភិវឌ្ឍ។ ដៃគូអភិវឌ្ឍន៍អាចជាបុគ្គល រាជរដ្ឋាភិបាល ស្ថាប័ន ឬអង្គការនានា។ ជាទូទៅនៅក្នុងការអភិវឌ្ឍជាសាកល ដៃគូអភិវឌ្ឍន៍ត្រូវបានគេប្រើរួមបញ្ចូលទាំងអស់រវាងអ្នកដែលផ្តល់ជំនួយ ឬមូលនិធិនានា គឺជាអ្នកផ្តល់ប្រាក់កម្ចីព្រមទាំងការផ្តល់ឲ្យ។

**តម្លាភាព** ភាពបើកចំហ និងឆន្ទៈទទួលយកការត្រួតពិនិត្យជាសាធារណៈដែលកាត់បន្ថយ សមត្ថភាពរបស់អង្គការមួយ ដែលពាក់ព័ន្ធ នឹងការលួចបន្លំ ឬធ្វើអ្វីដោយមិនស្មោះត្រង់។

**ទស្សនវិស័យ**

សេចក្តីប្រាថ្នា និងទិសដៅដែលអង្គការមួយចង់សម្រេចឲ្យបាននាពេលអនាគត ក្នុងរយៈពេលមធ្យម ឬរយៈពេលវែង និងជារូបភាពមួយដែលជម្រុញ ព្រមទាំងលើកទឹកចិត្តឲ្យអ្វីមួយអាចកើតមានឡើងនាពេលអនាគត។

**ទំនាស់ផលប្រយោជន៍**

ជាស្ថានភាពមួយ ដែលបុគ្គលម្នាក់ស្ថិតនៅក្នុងកាតព្វកិច្ចបំពេញការងារផ្លូវការរបស់ខ្លួន ដើម្បីទទួលផលប្រយោជន៍ផ្ទាល់ខ្លួនពីសកម្មភាព ឬសេចក្តីសម្រេចដែលធ្វើឡើងនៅក្នុងតួនាទី និងភារកិច្ចផ្លូវការរបស់ខ្លួន។ ទំនាស់ផលប្រយោជន៍អាចជាប់ទាក់ទងជាមួយនឹងប្រាក់កាក់ នយោបាយ គ្រួសារ និងផ្ទាល់ខ្លួនដែលមាន ឬអាចមានឥទ្ធិពលលើការបំពេញការងារផ្លូវការរបស់បុគ្គលណាម្នាក់។

**និរន្តរភាព**

ជាលទ្ធភាព ដើម្បីកំណត់សកម្មភាព និងបេសកកម្មរបស់អង្គការ ឬស្ថាប័នមួយដើម្បីអាចបន្តបេសកកម្មរបស់ខ្លួន ឲ្យបានដំណើរការទៅ មានរយៈពេលយូរនាពេលអនាគត។

**បណ្តឹងតវ៉ា**

ការបញ្ចេញមតិយោបល់នៃការព្រួយបារម្ភ ឬការមិនពេញចិត្តដោយបុគ្គល ឬក្រុមមួយដែលទាក់ទងទៅនឹងទង្វើ ឬសកម្មភាពដែលបានប្រព្រឹត្តិមិនត្រឹមត្រូវដែលអាចកើតមានឡើង នៅក្នុងដំណើរការប្រតិបត្តិ របស់អង្គការសហគមន៍មូលដ្ឋាន។

**បទបញ្ជាផ្ទៃក្នុង**

សំណុំនៃបទប្បញ្ញត្តិ ឬគោលការណ៍ជាក់លាក់ដែលបានអនុវត្តនៅក្នុងសកម្មភាពពិសេសរបស់អង្គការសហគមន៍មូលដ្ឋាន។ គោលការណ៍ ឬបទបញ្ជាដែលបញ្ជាក់ពីវិធីដែលត្រូវ ឬគួរធ្វើ និងបង្ហាញប្រាប់ពីអ្វីដែលសមាជិកត្រូវអនុញ្ញាត ឬមិនត្រូវអនុញ្ញាតឲ្យធ្វើ។

**បេសកកម្ម**

ជាសកម្មភាពមួយដែលអង្គការសហគមន៍មូលដ្ឋានត្រូវធ្វើដើម្បីសម្រេចនូវផលប្រយោជន៍របស់សហគមន៍។ ជាសកម្មភាពចម្បងៗដែលត្រូវសម្រេចឲ្យបានដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ គោលបំណង និងទស្សនវិស័យរបស់អង្គការសហគមន៍មូលដ្ឋាន។

| | |
|---|---|
| **ផែនការយុទ្ធសាស្ត្រ** | គឺជាឯកសារដែលទាក់ទងនឹងគោលបំណងរបស់អង្គការ សកម្មភាពចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងទាំងនោះ និងសមាសធាតុសំខាន់ៗដទៃទៀតក្នុងការបង្កើតផែនការ ដូចជា ទស្សនវិស័យ បេសកកម្ម គោលបំណង ភូមិសាស្ត្រ សេវាកម្ម សូចនាករ និងហិរញ្ញវត្ថុ។ |
| **ផែនការអភិវឌ្ឍន៍ និងវិនិយោគឃុំ សង្កាត់** | ជាសេចក្តីណែនាំសម្រាប់ការសម្រេចចិត្តក្នុងការងារអភិវឌ្ឍន៍ កសាងកម្មវិធីវិនិយោគ និងរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដោយមានការចូលរួមអនុវត្តពី គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីកៀរគរធនធានពីខាងក្នុង និងពីខាងក្រៅ ព្រមទាំងសម្រេចចិត្តប្រើប្រាស់ធនធានទាំងនោះសម្រាប់ដោះស្រាយបញ្ហា និងបម្រើផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់។ |
| **មូលនិធិ** | ទឹកប្រាក់ ឬថវិកាដែលបានរក្សាទុក ប្រមូលបាន ឬផ្តល់ជូនសម្រាប់គោលបំណងជួយដល់សកម្មភាពសង្គមជាក់លាក់។ |
| **យន្តការ** | ដំណើរការ ប្រព័ន្ធ វិធី ឬមធ្យោបាយដែលត្រូវបានគេគ្រោងទុកដើម្បីបង្កើត និងសម្រេចនូវលទ្ធផលជាក់លាក់មួយ។ |
| **យេនឌ័រ** | ផ្នត់គំនិត ឬការប្រព្រឹត្តិរបស់គ្រួសារ សហគមន៍ និងសង្គមដែលពាក់ព័ន្ធនឹងការបែងចែកការងារ ពលកម្ម ការអប់រំសិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទីរបស់ស្ត្រី និងបុរសនៅក្នុងសង្គម។ |
| **លក្ខន្តិកៈ** | ជាវិធានដែលត្រូវបានតាក់តែងឡើង សម្រាប់គ្រប់គ្រងកិច្ចការផ្ទៃក្នុងរបស់អង្គការ ឬស្ថាប័នមួយ។ ជាទូទៅ លក្ខន្តិកៈគឺកំណត់នូវឈ្មោះជាផ្លូវការ គោលបំណងរបស់អង្គការ ឬស្ថាប័ន លក្ខខណ្ឌតម្រូវសម្រាប់សមាជិកភាព តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការ ការតែងតាំង និងជ្រើសរើសសមាជិកគណៈកម្មការកំណត់នូវកិច្ចប្រជុំគួរត្រូវធ្វើឡើងដូចម្តេច និងត្រូវធ្វើឡើងញឹកញាប់ប៉ុណ្ណា។ |
| **សមធម៌** | ភាពត្រឹមត្រូវ ឬមិនលំអៀង។ ប្រយោជន៍ដែលទទួលបានប្រកបដោយគុណភាព គុណធម៌ ភាពត្រឹមត្រូវ និងមិនលំអៀង។ |

**សមភាព** គុណភាព ឬស្ថានភាពនៃភាពស្មើគ្នា។ ឧទាហរណ៍ ស្ថានភាពនៃការមានសិទ្ធិ ឬមានឋានៈដូចគ្នា នៅក្នុងសង្គម។

**សវនកម្ម** ជាការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យជាប្រព័ន្ធលើទិន្នន័យរបាយការណ៍ កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់អង្គការសម្រាប់គោលបំណងជាក់លាក់ណាមួយ។

**សហគមន៍** ដំណើរការរួបរួមគ្នា ដែលប្រជាពលរដ្ឋមានចំណាប់អារម្មណ៍រួមគ្នាលើបញ្ហាសង្គម បរិស្ថាន វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ចជាដើម ដើម្បីប្រកបមុខរបរចិញ្ចឹមជីវិត និងកែលម្អជីវភាពរស់នៅរួមគ្នា និងចូលរួមអភិវឌ្ឍសង្គម ។

**អង្គការសហគមន៍មូលដ្ឋាន** ជាក្រុមប្រជាពលរដ្ឋដែល បង្កើតឡើងរួមគ្នាដោយស្ម័គ្រចិត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ ក្នុងគោលបំណងរួមដើម្បីដឹកនាំ គ្រប់គ្រង បម្រើ និងការពារផលប្រយោជន៍នៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន ប្រកបដោយនិរន្តរភាព។

# ឧបសម្ព័ន្ធគម្រូ ១

# លក្ខន្តិកៈនៃអង្គការសហគមន៍មូលដ្ឋាន

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# អង្គការសហគមន៍មូលដ្ឋាន
## ដើម្បីអភិវឌ្ឍន៍ស្រុកយើង(អ.ស.យ)

# លក្ខន្តិកៈនៃអង្គការសហគមន៍មូលដ្ឋាន

*ផ្ទះលេខ៣៥ ផ្លូវលំ ភូមិ បូរីកម្មករ ឃុំ ដូនទាវ ស្រុក ឯកភ្នំ ខេត្ត បាត់ដំបង*

# មាតិកា

ជំពូកទី១៖ នាមករណ៍ អក្សរកាត់ និងស្លាកសញ្ញា ........ ៤៤
ជំពូកទី២៖ ទីស្នាក់ការ និងអាសយដ្ឋាន ........ ៤៤
ជំពូកទី៣៖ គោលបំណង និងគោលដៅ ........ ៤៤
ជំពូកទី៤៖ ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ ........ ៤៤
ជំពូកទី៥៖ លក្ខខណ្ឌនៃការចូលជាសមាជិក ........ ៤៥
ជំពូកទី៦៖ លក្ខខណ្ឌនៃការលាឈប់ និងការបញ្ចប់ជាសមាជិកភាព ........ ៤៦
ជំពូកទី៧៖ រចនាសម្ព័ន្ធនៃអង្គការសហគមន៍មូលដ្ឋាន ........ ៤៧
ជំពូកទី៨៖ មហាសន្និបាត ........ ៤៩
ជំពូកទី៩៖ គណៈកម្មការ ........ ៥១
ជំពូកទី១០៖ ដំណើរការប្រជុំរបស់គណៈកម្មការ ........ ៥២
ជំពូកទី១១៖ ក្រុមប្រឹក្សាយោបល់ ........ ៥៣
ជំពូកទី១២៖ លក្ខខណ្ឌនៃការបោះឆ្នោតជ្រើសរើសគណៈកម្មការ ........ ៥៤
ជំពូកទី១៣៖ យន្តការគណនេយ្យភាព ឬបណ្ដឹងតវ៉ា ........ ៥៧
ជំពូកទី១៤៖ ការដោះស្រាយវិវាទនៅក្នុងអង្គការសហគមន៍មូលដ្ឋាន ........ ៥៩
ជំពូកទី១៥៖ លក្ខខណ្ឌនៃការរំលាយអង្គការសហគមន៍មូលដ្ឋាន ........ ៦០
ជំពូកទី១៦៖ នីតិវិធីនៃការកែប្រែ ឬវិសោធនកម្មលក្ខន្តិកៈ ........ ៦០
ជំពូកទី១៧៖ អវសានប្បញ្ញត្តិ ........ ៦១

# ជំពូកទី ១
# នាមករណ៍ អក្សរកាត់ និងស្លាកសញ្ញា

## ប្រការ១

ឈ្មោះអង្គការសហគមន៍មូលដ្ឋាន៖ ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង***

អក្សរកាត់៖ ***អ.ស.យ***

## ប្រការ២

ស្លាកសញ្ញា៖

# ជំពូកទី ២
# ទីស្នាក់ការ និងអាសយដ្ឋាន

## ប្រការ៣

អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** មានទីតាំងស្ថិតនៅផ្ទះលេខ *៣៥ ផ្លូវលំ ភូមិ បុរីកម្មករ ឃុំ ដូនទាវ ស្រុក ឯកភ្នំ ខេត្ត បាត់ដំបង*។

# ជំពូកទី ៣
# គោលបំណង និងគោលដៅ

## ប្រការ៤

អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** មានគោលបំណងដូចខាងក្រោម៖

ពង្រឹងសិទ្ធិអំណាច ការចូលរួម និងលើកកំពស់ស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានឲ្យមានភាពកាន់តែ ប្រសើរឡើង ។

# ជំពូកទី ៤
# ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ

## ប្រការ៥

**ទស្សនវិស័យ**

អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** មានទស្សនវិស័យដូចខាងក្រោម៖

ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍មូលដ្ឋានទាំងមូល មានជីវភាពរស់នៅហូបចុកគ្រប់គ្រាន់ ថ្លៃថ្នូរ មានសន្តិសុខ សុវត្ថិភាព ការគោរពសិទ្ធិមនុស្ស យុត្តិធម៌ និងសុភមង្គល។

## ប្រការ៦

**បេសកកម្ម**

ដើម្បីសម្រេចនូវទស្សនវិស័យ និងគោលបំណងខាងលើ អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** មានបេសកកម្មដូចខាងក្រោម៖

- បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីបង្កើតមុខរបរថ្មីដែលទាក់ទងនឹងសិប្បកម្ម និងកសិឧស្សាហកម្មធុនស្រាលដូចជាៈការបង្កើតកសិដ្ឋានរួមដើម្បីចិញ្ចឹមសត្វ និងកសិកម្មខ្នាតតូចនៅតាមមូលដ្ឋាន។
- បង្កើតក្រុមសន្សំប្រាក់ និងធនាគារខ្នាតតូចនៅ ក្នុងសហគមន៍មូលដ្ឋាន
- បង្កើតបណ្តាញ និងពង្រឹងបណ្តាញសមាជិកស្ម័គ្រចិត្តរបស់សហគមន៍មូលដ្ឋាន

## ប្រការ៧

**គុណតម្លៃ**

អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** មានគុណតម្លៃដូចខាងក្រោម៖

- ការចូលរួម
- ភាពទទួលខុសត្រូវ
- ភាពស្មោះត្រង់
- តម្លាភាព និងយុត្តិធម៌

# ជំពូកទី ៥

# លក្ខខណ្ឌនៃការចូលជាសមាជិក

## ប្រការ៨

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងចូលជាសមាជិកអង្គការសហគមន៍មូលដ្ឋាន ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ
- មានមុខរបរ និងអាជីពចម្បងទាក់ទងនឹងវិស័យនានាដែលសហគមន៍មូលដ្ឋានរបស់ខ្លួនជាប់ពាក់ព័ន្ធ
- ស្ម័គ្រចិត្តសុំចូលជាសមាជិកសហគមន៍មូលដ្ឋានតាមរយៈការដាក់ពាក្យ

### ប្រការ៩

សមាជិកដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៨ ខាងលើមានសិទ្ធិ៖

- ចូលរួមប្រជុំមហាសន្និបាទ និងបោះឆ្នោតស្មើភាព ជាមួយនឹងសមាជិកដទៃទៀត ដោយពុំគិតពីកំរិតធនធាន និងទ្រព្យសម្បត្តិឡើយ
- បោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតក្នុងការជ្រើសរើសគណៈកម្មការរបស់អង្គការសហគមន៍មូលដ្ឋាន
- ទទួលព័ត៌មានពីសកម្មភាព និងស្ថានភាពអភិវឌ្ឍន៍របស់អង្គការសហគមន៍មូលដ្ឋាន ពីប្រធាន ក្រុមប្រឹក្សា ឬគណៈកម្មការ
- ស្នើសុំឲ្យមានកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការគាំទ្រពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកទាំងអស់
- ធ្វើសំណូមពរឲ្យដាក់បញ្ចូលក្នុងរបៀបវារៈ នៃមហាសន្និបាតនូវបញ្ហាទាំងឡាយ ដែលមានប្រយោជន៍សម្រាប់សហគមន៍មូលដ្ឋាន
- ប្រើប្រាស់ ឬជួលសេវាកម្ម និងទ្រព្យសម្បត្តិរបស់សហគមន៍មូលដ្ឋាន ដូចគ្នានឹងសមាជិកដទៃទៀតទាំងអស់
- ចូលរួមនៅក្នុងសកម្មភាពទាំងអស់របស់អង្គការសហគមន៍មូលដ្ឋាន។

## ជំពូកទី ៦

## លក្ខខណ្ឌនៃការលាឈប់ និងការបញ្ចប់ជាសមាជិកភាព

### ប្រការ១០

**ការបាត់បង់សមាជិកភាព**

- មរណៈភាព
- ការលាឈប់
- ចំណាកស្រុក ឬផ្លាស់ប្តូរទីលំនៅ
- មានភាពមិនស្មោះត្រង់ចំពោះអង្គការសហគមន៍មូលដ្ឋាន

### ប្រការ១១

សមាជិកអង្គការសហគមន៍មូលដ្ឋាន មានសិទ្ធិសុំលាឈប់ពីភាពជាសមាជិកបានដោយប្រការណាមួយ ប៉ុន្តែសមាជិកនោះត្រូវតែសងបំណុលមកអង្គការសហគមន៍មូលដ្ឋានវិញឲ្យបានរួចរាល់ជាមុនសិន (ករណីមានជំពាក់បំណុលអង្គការសហគមន៍មូលដ្ឋាន)។

### ប្រការ១២

សមាជិកដែលត្រូវបញ្ចប់ភាពជាសមាជិករបស់អង្គការសហគមន៍មូលដ្ឋាន ដោយសារសមាជិកនោះអសកម្ម ឬមិនគោរពតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គការសហគមន៍មូលដ្ឋាន ឬធ្វើឲ្យរាំងស្ទះដល់ដំណើរការអនុវត្តន៍មូលនិធិរបស់អង្គការសហគមន៍មូលដ្ឋាន ហើយសមាជិករូបនោះត្រូវតែសងបំណុលដល់អង្គការសហគមន៍មូលដ្ឋានវិញ (ករណីមានជំពាក់បំណុលអង្គការសហគមន៍មូលដ្ឋាន)។

## ជំពូកទី ៧

## រចនាសម្ព័ន្ធនៃអង្គការសហគមន៍មូលដ្ឋាន

### ប្រការ១៣

អង្គការសហគមន៍មូលដ្ឋានមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- មហាសន្និបាត
- ក្រុមប្រឹក្សាយោបល់
- គណៈកម្មការ

រចនាសម្ព័ន្ធរបស់អង្គការសហគមន៍មូលដ្ឋានមាន៖



# ជំពូកទី ៨
# មហាសន្និបាត

## ប្រការ១៤

មហាសន្និបាតនៃអង្គការសហគមន៍មូលដ្ឋាន រចនាសម្ព័ន្ធជាន់ខ្ពស់សម្រាប់ការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមអង្គការសហគមន៍មូលដ្ឋាន។ មហាសន្និបាតលើកដំបូងរបស់អង្គការសហគមន៍មូលដ្ឋាន ត្រូវប្រារព្ធធ្វើឡើងបន្ទាប់ពីក្រុមស្ថាបនិក បានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធទៅនឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតលើកដំបូងរបស់អង្គការសហគមន៍មូលដ្ឋាន ធ្វើឡើងដោយក្រុមប្រឹក្សាយោបល់នៃអង្គការសហគមន៍មូលដ្ឋាន ដោយមានការជួយសម្របសម្រួលពីគណៈកម្មការសហគមន៍មូលដ្ឋាន តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិក ដែលបានដាក់ពាក្យស្នើសុំចូលជាសមាជិក នៃអង្គការសហគមន៍មូលដ្ឋាន។

មហាសន្និបាតលើកដំបូងរបស់អង្គការសហគមន៍មូលដ្ឋាន អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ៗដូចខាងក្រោម៖

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន
- ឈ្មោះអង្គការសហគមន៍មូលដ្ឋាន
- លក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងរបស់អង្គការសហគមន៍មូលដ្ឋាន
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន

## ប្រការ១៥

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ឆ្នាំម្តង ដើម្បីបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់អង្គការសហគមន៍មូលដ្ឋាន។ ក្នុងករណីចាំបាច់អង្គការសហគមន៍មូលដ្ឋាន ត្រូវរៀបចំមហាសន្និបាតវិសាមញ្ញ តាមការស្នើសុំពីសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ចំនួនមួយភាគបី (១/៣) យ៉ាងតិច។

## ប្រការ១៦

គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន អាចអញ្ជើញអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ ឬសង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតនៃអង្គការសហគមន៍មូលដ្ឋាន ។

## ប្រការ១៧

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម៖

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅស្នាក់ការនៃអង្គការសហគមន៍មូលដ្ឋាន និងសាលាឃុំ ឬសង្កាត់
- កោះអញ្ជើញសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ឲ្យចូលរួមមហាសន្និបាតសាមញ្ញ ឲ្យបាន១០(ដប់)ថ្ងៃយ៉ាងតិចមុនថ្ងៃបើកមហាសន្និបាត និង៣(បី)ថ្ងៃ យ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបាន លុះត្រាតែមានវត្តមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិករបស់អង្គការសហគមន៍មូលដ្ឋាន
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ឬប្រធានអង្គប្រជុំ ដែលជ្រើសរើសឡើងដោយការអនុម័តក្នុងចំណោមសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ដែលមានវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្ដីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសម្លេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្ដីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ដែលមានវត្តមាន។

## ប្រការ១៨

មហាសន្និបាតអនុម័ត៖

- សេចក្ដីសម្រេចដូចមានចែងក្នុងប្រការ ១៤ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គការសហគមន៍មូលដ្ឋាន
- រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន

- ការសុំលាលែង ឬការបញ្ចប់ពីសមាជិកភាព ឬពីសមាជិកគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន
- គម្រោងចំណូល និងចំណាយរបស់អង្គការសហគមន៍មូលដ្ឋាន

## ជំពូកទី ៩

## គណៈកម្មការ

### ប្រការ១៩

គណៈកម្មការមានសមាជិកចំនួនចាប់ពីប្រាំ (៥) នាក់ឡើងទៅ ដែលរួមមាន សមាសភាពៈ ប្រធាន អនុប្រធាន ហេរញ្ញឹក និងសមាជិក។ ជាសមាជិកដែលពុំមានឈ្មោះនៅក្នុងក្រុមប្រឹក្សាយោបល់ ឬមន្ត្រីអាជ្ញាធរមូលដ្ឋាន។ សមាជិកដែលត្រូវជាឪពុកម្តាយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ប្តីប្រពន្ធ ជាមួយនឹងសមាជិកក្រុមប្រឹក្សាយោបល់ពុំអាចធ្វើជាសមាជិកនៃគណៈកម្មការបានទេ ។

### ប្រការ២០

គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញវត្ថុមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋានទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋានទាំងមូល។ អនុប្រធានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ជាជំនួយការឲ្យប្រធាន ។

### ប្រការ២១

គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន មានអាណត្តិប្រាំ (៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋានថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឲ្យចូលកាន់តំណែងជំនួស។ ក្នុងករណីដែលអង្គការសហគមន៍មូលដ្ឋាន មានដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងនៃអង្គការសហគមន៍មូលដ្ឋាន សមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ចំនួនមួយ

ភាគបី(១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋានជាថ្មី ។

### ប្រការ២២

ក្នុងករណីដែលសមាជិកគណៈកម្មការ នៃអង្គការសហគមន៍មូលដ្ឋានណាម្នាក់អវត្តមានដោយគ្មានមូលហេតុរយៈពេលប្រាំមួយ (៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ១០

## ដំណើរការប្រជុំរបស់គណៈកម្មការ

### ប្រការ២៣

គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ត្រូវកំណត់របៀបវារៈប្រជុំឲ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋានអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋានទាំងមូល ។

### ប្រការ២៤

ប្រធានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន អវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានអ្នកចូលរួមច្បាស់លាស់ ។

ប្រធានអង្គប្រជុំត្រូវធានាឲ្យគ្រប់កិច្ចប្រជុំនៃអង្គការសហគមន៍មូលដ្ឋាន ប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិតេយ្យ គោរពតាមលក្ខន្តិកៈ និងគ្មានការរំខាន។

### ប្រការ២៥

ការសម្រេចលើបញ្ហាណាមួយរបស់អង្គការសហគមន៍មូលដ្ឋាន ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ដោយមាន

សម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មការ ដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នា ប្រធានអង្គប្រជុំមានមតិអនុភាពក្នុងការសម្រេចៈ

- ផែនការគ្រប់គ្រងនៃអង្គការសហាគមន៍មូលដ្ឋាន
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងអង្គការសហាគន៍មូលដ្ឋាន
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុងដល់សមាជិកនៃអង្គការសហាគមន៍មូលដ្ឋាន

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការនៃអង្គការសហាគមន៍មូលដ្ឋាន ត្រូវចាត់ឲ្យធ្វើការជូនដំណឹងដល់សមាជិកនៃអង្គការសហាគមន៍មូលដ្ឋាន អំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការនៃអង្គការសហាគមន៍មូលដ្ឋាន ត្រូវបិទផ្សាយជាសាធារណៈនៅអង្គការសហាគមន៍មូលដ្ឋាន ឬសាលាឃុំ សង្កាត់ ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ បន្ទាប់ពីការប្រជុំ ។

## ជំពូកទី ១១
## ក្រុមប្រឹក្សាយោបល់

### ប្រការ២៦

ក្រុមអ្នកស្ម័គ្រចិត្តដែលមានចំណេះដឹងខ្ពស់ និងបទពិសោធន៍ការងារដែលពាក់ព័ន្ធទៅនឹងការងារសហាគមន៍មូលដ្ឋាន ដើម្បីផ្តល់ដំបូន្មានយុទ្ធសាស្ត្រដល់គណៈកម្មការនៃអង្គការសហាគមន៍មូលដ្ឋាន។

### ប្រការ២៧

ក្រុមប្រឹក្សាយោបល់ មានសមាជិកចំនួន ៣-៥នាក់ និងត្រូវបានជ្រើសតាំងសម្រាប់អាណត្តិបី(៣)ឆ្នាំ ហើយមិនអាចជ្រើសតាំងឲ្យហួសពីពីរ (២) អាណត្តិជាប់គ្នាបានឡើយ។ សមាជិកក្រុមប្រឹក្សាយោបល់មិនត្រូវបានអនុញ្ញាតិឲ្យមានសាច់ញាតិជាសមាជិកក្រុមប្រឹក្សាយោបល់ជាមួយគ្នាទេ។

### ប្រការ២៨

តួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់ក្រុមប្រឹក្សាយោបល់ ដូចជាៈ

- ផ្តល់យោបល់ល្អទៅដល់សមាជិកគណៈកម្មការ និងសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន
- លើកទឹកចិត្ត និងគាំទ្រដល់សកម្មភាព និងគម្រោងថ្មីៗរបស់អង្គការសហគមន៍មូលដ្ឋាន
- ជួយពង្រឹងសមត្ថភាពដល់សមាជិកគណៈកម្មការ និងសមាជិកអង្គការសហគមន៍មូលដ្ឋាន
- ជួយពង្រឹងអភិបាលកិច្ចល្អដល់អង្គការសហគមន៍មូលដ្ឋាន
- គួរមានរបបប្រជុំជាក់លាក់ យ៉ាងហោចណាស់ឲ្យបាន ៣ ទៅ៤ដងក្នុងមួយឆ្នាំ
- ជួយដោះស្រាយបញ្ហាប្រឈមនានានៅក្នុងការដឹកនាំ និងការគ្រប់គ្រងអង្គការសហគមន៍មូលដ្ឋាន
- ជួយរកប្រភពព័ត៌មាននៃការកៀរគរថវិកាសម្រាប់អង្គការសហគមន៍មូលដ្ឋាន
- ជួយពិនិត្យ និងផ្តល់យោបល់ទៅលើការកែសម្រួលលើលក្ខន្តិកៈ គោលការណ៍ បេសកកម្ម កម្មវិធី ផែនការយុទ្ធសាស្ត្រ ការធ្វើវិសោធនកម្ម និងបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ១២

## លក្ខខណ្ឌនៃការបោះឆ្នោតជ្រើសរើសគណៈកម្មការ

### ប្រការ២៩

ចំនួនសមាជិកគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន និងចំនួនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត។

### ប្រការ៣០

កិច្ចការដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត។ គណៈកម្មការរៀបចំការបោះឆ្នោត មានសមាសភាពពី ៣ (បី) ទៅ ៥ (ប្រាំ) នាក់ ដែលមានប្រធាន អនុប្រធាន ហេរញ្ញិក លេខាធិការ និងសមាជិកតាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

### ប្រការ៣១

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ៖

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

### ប្រការ៣២

បេក្ខជនដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន តាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជនដែលមានសម្លេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាពដោយលើកដៃ យកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកនៃអង្គការសហគមន៍មូលដ្ឋានដែលចូលរួម។

### ប្រការ៣៣

គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន មានសមាសភាពដូចខាងក្រោម៖

- ប្រធាន
- អនុប្រធាន
- ហេរញ្ញឹក
- លេខាធិការ
- សមាជិក

### ប្រការ៣៤

តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន៖

#### ក. ប្រធាន

- ផ្តល់នូវភាពជាអ្នកដឹកនាំដល់សមាជិក និងទទួលខុសត្រូវចំពោះការគ្រប់គ្រងនៃអង្គការសហគមន៍មូលដ្ឋាន
- ផ្តួចផ្តើមនូវសកម្មភាពផ្សេងៗ លើកទឹកចិត្តសមាជិក និងសហគមន៍

- រៀបចំការប្រជុំដើម្បីជូនដំណឹងដល់សមាជិកសហគមន៍ពីសកម្មភាពថ្មីៗ និងការរីកចម្រើន
- តាមដាន និងត្រួតពិនិត្យគ្រប់សកម្មភាពទាំងអស់ ដើម្បីធានាថាសកម្មភាពទាំងនោះស្រប ជាមួយនឹងគោលបំណង និងទិសដៅដែលបានកំណត់
- រាយការណ៍ជាទៀងទាត់ដល់អាជ្ញាធរមូលដ្ឋាន និងម្ចាស់ជំនួយ(ប្រសិនបើមាន)

## ខ. អនុប្រធាន

- ទទួលតួនាទីក្នុងនាមជាប្រធានស្តីទីក្នុងពេលដែលប្រធានអវត្តមាន ដោយសារជម្ងឺ ឬមានបេសកកម្ម។ល។
- ជួយប្រធានលើការងារគ្រប់គ្រងទូទៅរបស់អង្គការសហគមន៍មូលដ្ឋាន

## គ. ហេរញ្ញិក

- គ្រប់គ្រង និងត្រួតពិនិត្យសាច់ប្រាក់ និងសម្ភារៈ
- រក្សាទុកឯកសារចំណូលចំណាយ និងទ្រព្យសម្បត្តិផ្សេងៗ
- ផ្តល់របាយការណ៍សង្ខេបស្តីពីចំណូល និងចំណាយដល់គណៈកម្មការ និងសមាជិកសហគមន៍មូលដ្ឋានស្របទៅតាមកម្មវិធីដែលអង្គការសហគមន៍មូលដ្ឋានបានឯកភាព ទៅតាមគោលការណ៍ហិរញ្ញវត្ថុ
- ប្រកាសពីចំណូល និងការចំណាយដែលរកបានតាមរយៈកម្មវិធី និងព្រឹត្តិការណ៍ផ្សេងៗ

## ឃ. លេខាធិការ

- សរសេរកំណត់ហេតុ និងរក្សាទុកឯកសារផ្សេងៗរបស់អង្គការសហគមន៍មូលដ្ឋាន
- គ្រប់គ្រង និងកត់ត្រាទុករាល់ការឆ្លើយឆ្លង និងទស្សនកិច្ចរបស់អ្នកដែលមិនមែនជាសមាជិករបស់សហគមន៍មូលដ្ឋាន
- ពិនិត្យផ្ទៀងផ្ទាត់ដោយប្រុងប្រយ័ត្នរាល់ចំណូល និងការចំណាយជាមួយហិរញ្ញឹក
- សរសេររបាយការណ៍សកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋានសម្រាប់ក្រុមប្រឹក្សាឃុំយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ

## ង. សមាជិក

- រួមចំណែកជាធនធានផ្សេងៗ ដូចជាពេលវេលាផ្ទាល់ខ្លួន ជំនួយផ្នែកកំលាំងកាយ និងស្មារតី ព្រមទាំងគំនិតនានាដើម្បីបំរើផលប្រយោជន៍ដល់អង្គការសហគមន៍មូលដ្ឋាន
- ចូលរួមយ៉ាងសកម្មក្នុងការប្រជុំរបស់អង្គការសហគមន៍មូលដ្ឋាន តាមរយៈការបញ្ចេញនូវគំនិត និងទុកពេលឲ្យសមាជិកផ្សេងៗទៀតនិយាយ

- ផ្តល់ព័ត៌មានត្រលប់ពីបញ្ហាផ្សេងៗទាក់ទងនឹងសកម្មភាពនានារបស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីឲ្យគេអាចអភិវឌ្ឍន៍កាន់តែប្រសើរឡើងនៅពេលអនាគត
- យល់ច្បាស់ពីគោលបំណង បេសកកម្ម និងគោលការណ៍របស់អង្គការសហគមន៍មូលដ្ឋាន ព្រមទាំងតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការ ប្រធាន និងសមាជិក

## ជំពូកទី ១៣

## យន្តការគណនេយ្យភាព ឬបណ្តឹងតវ៉ា

### ប្រការ៣៥

យន្តការគណនេយ្យភាព ដើម្បីផ្តល់ដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ខ្លាំងពីសកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋាន ក្នុងការបញ្ចេញមតិ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាសម្រាប់ពួកគេ និងប្រាប់ឲ្យដឹងពីការរំលោភបំពានលើគោលការណ៍នានា និងនីតិវិធីរបស់អង្គការសហគមន៍មូលដ្ឋាន។

### ប្រការ៣៦

យន្តការគណនេយ្យភាព លើកកម្ពស់ និងពង្រឹងដំណើការប្រតិបត្តិល្អ ដើម្បីធានានូវគណនេយ្យភាព និងការចូលរួមយ៉ាងសកម្មរបស់សមាជិកនៃអង្គការសហគមន៍មូលដ្ឋាន តាមរយៈការដោះស្រាយបណ្តឹងតវ៉ា និងបញ្ហានានានៅក្នុងអង្គការសហគមន៍មូលដ្ឋានដោយការទទួលខុសត្រូវខ្ពស់។ យន្តការបណ្តឹងតវ៉ា ពង្រឹងប្រព័ន្ធគណនេយ្យភាព និងតម្លាភាពនៅក្នុងសហគមន៍មូលដ្ឋានតាមរយៈការទទួលពាក្យបណ្តឹងតវ៉ាពីភាគីអ្នកពាក់ព័ន្ធ និងធានាការប្រើប្រាស់យន្តការនេះប្រកបដោយសុវត្ថិភាព។

### ប្រការ៣៧

សមាជិក និងភាគីពាក់ព័ន្ធនៅក្នុងសកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋានដែលមានបញ្ហា អាចប្រើប្រាស់យន្តការដោះស្រាយបណ្តឹងនេះបាន។ យន្តការបណ្តឹងតវ៉ាត្រូវបានឆ្លើយតបដល់បុគ្គល ឬប្រជាពលរដ្ឋនៅក្នុងសហគមន៍ដែលមិនពេញចិត្តសកម្មភាព ឬទង្វើនានារបស់សមាជិកនៃសហគមន៍មូលដ្ឋាន ដោយដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ារបស់អង្គការសហគមន៍មូលដ្ឋាន។

## ប្រការ៣៨

គណៈកម្មការដោះស្រាយបណ្តឹងតវ៉ា មានសមាសភាពចំនួន ៣(បី) ទៅ ៥(ប្រាំ) រូប ដែលមានតួនាទីជាអ្នកទទួលពាក្យបណ្តឹង គ្រប់គ្រង ឆ្លើយតប និងដោះស្រាយរាល់ពាក្យបណ្តឹងតវ៉ាឲ្យបានទាន់ពេលវេលា។ សមាជិកគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាត្រូវជ្រើសរើសពីសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន។

## ប្រការ៣៩

បណ្តឹងតវ៉ានេះត្រូវបានដោះស្រាយ ដោយផ្អែកលើគោលការណ៍ការស្ម័គ្រចិត្តពីភាគីបណ្តឹងតវ៉ា និងភាគីពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងយូរ១សប្តាហ៍ ចាប់រាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។ ប៉ុន្តែបើសិនជាបណ្តឹងបញ្ហាតវ៉ាមានលក្ខណៈស្មុគស្មាញ ឬធ្ងន់ធ្ងរ ទាមទាររយៈពេលមួយកំណត់ មិនលើសពីមួយខែ ដើម្បីធ្វើការប្រមូលព័ត៌មានឲ្យបានត្រឹមត្រូវ គ្រប់ជ្រុងជ្រោយបណ្តឹងតវ៉ានោះនឹងត្រូវបានផ្តល់ព័ត៌មានដល់ដើមបណ្តឹង ពីការកំណត់រយៈពេលវេលាបន្ថែមសម្រាប់ដំណើរការដោះស្រាយបណ្តឹងតវ៉ា។ រយៈពេលត្រូវដោះស្រាយបណ្តឹងនីមួយៗនេះ មិនត្រូវលើសពីមួយខែក្រោយពីថ្ងៃដែលបានទទួលបណ្តឹង។

## ប្រការ៤០

ប្រសិនបើដើមបណ្តឹងតវ៉ា មិនសុខចិត្តចំពោះការសម្រេចចិត្តរបស់គណៈកម្មការ ដើមបណ្តឹងអាចធ្វើបណ្តឹងបន្តទៅកាន់ក្រុមប្រឹក្សាយោបល់ នៃអង្គការសហគមន៍មូលដ្ឋាន។ បណ្តឹងតវ៉ានេះ មិនឲ្យលើសពីរយៈពេល ១ខែ បន្ទាប់ពីការសម្រេច។ ដើមបណ្តឹងតវ៉ាត្រូវសរសេរជាលិខិត ឬនិយាយផ្ទាល់មកកាន់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ា។

## ប្រការ៤១

ក្នុងករណីមានការបន្តបណ្តឹងតវ៉ាទៅលើទៀត គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាត្រូវបង្កើតគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាឧទ្ធរណ៍មួយឡើង ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាយោបល់។

គណៈកម្មាការដោះស្រាយបណ្តឹងឧទ្ធរណ៍ នឹងធ្វើការដោះស្រាយបណ្តឹងនោះ ដោយធ្វើការសម្រេចចិត្តក្នុងរយៈពេល១ខែ បន្ទាប់ពីបានទទួលបណ្តឹងឧទ្ធរណ៍។ ការសម្រេចចិត្តនេះ ជាការសម្រេចចិត្តចុងក្រោយនៅក្នុងគណៈកម្មការដោះស្រាយបណ្តឹងតវ៉ា។ ករណីដើមបណ្តឹងតវ៉ាមិន

សុខចិត្តនឹងការសម្រេចនេះ ដើមបណ្តឹងអាចប្តឹងបន្តទៅអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ ឬស្ថាប័នដែលមានសមត្ថកិច្ច។

## ជំពូកទី ១៤

## ការដោះស្រាយវិវាទនៅក្នុងអង្គការសហគមន៍មូលដ្ឋាន

### ប្រការ៤២

ទំនាស់រវាងសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ជាមួយនឹងសមាជិកសហគមន៍នៅក្នុងភូមិ ឃុំ/សង្កាត់តែមួយ គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ជាអ្នកធ្វើការសម្រុះសម្រួលវិវាទនោះ។

ទំនាស់រវាងសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ជាមួយអ្នកផ្សេង ក្រៅពីសមាជិកសហគមន៍សាមីដែលរស់នៅក្នុងភូមិ ឃុំ ឬសង្កាត់តែមួយនោះ គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ជាអ្នកធ្វើការសម្រុះសម្រួលវិវាទនោះ។

ទំនាស់រវាងសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ជាមួយអ្នកសហគមន៍មកពីខាងក្រៅមូលដ្ឋានឃុំ/សង្កាត់សាមីនោះ គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ជាអ្នកធ្វើការសម្រុះសម្រួលវិវាទនោះ។

### ប្រការ៤៣

ចំពោះទំនាស់ រវាងសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន ជាមួយនឹងគណៈកម្មការ នៃអង្គការសហគមន៍មូលដ្ឋាន សមាជិកក្រុមប្រឹក្សាយោបល់នៃអង្គការសហគមន៍មូលដ្ឋាន ត្រូវធ្វើការសម្រុះសម្រួលវិវាទនោះ។

ករណីសមាជិកក្រុមប្រឹក្សាយោបល់នៃអង្គការសហគមន៍មូលដ្ឋាន មិនអាចសម្រុះសម្រួលវិវាទបាន ក្រុមប្រឹក្សាយោបល់នៃអង្គការសហគមន៍មូលដ្ឋាន អាចស្នើសុំទៅអាជ្ញាធរមូលដ្ឋានឃុំ ឬសង្កាត់ ឬស្រុក/ក្រុង/ខណ្ឌដែលនៅជិតបំផុត ជួយដោះស្រាយវិវាទ។

## ជំពូកទី ១៥

## លក្ខខណ្ឌនៃការរំលាយអង្គការសហគមន៍មូលដ្ឋាន

### ប្រការ៤៤

ការរំលាយអង្គការសហគមន៍មូលដ្ឋាន ដោយអង្គការសហគមន៍មូលដ្ឋានផ្ទាល់ អាស្រ័យដោយសម័យប្រជុំប្រាំមួយ(០៦)ខែ ឬមហាសន្និបាតប្រចាំឆ្នាំរបស់អង្គការសហគមន៍មូលដ្ឋាន ពិភាក្សា និងសម្រេច។

### ប្រការ៤៥

លក្ខខណ្ឌដែលអាចរំលាយអង្គការសហគមន៍មូលដ្ឋានះ

- ការឯកភាពគ្នារវាងភាគីទាំងអស់ជាលាយល័ក្ខអក្សរ
- ការព្រមព្រៀងគ្នាក្នុងគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន និងមានការឯកភាព ២ភាគ៣ នៃសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន
- សេចក្តីសម្រេចរបស់មហាសន្និបាតប្រចាំឆ្នាំ ដោយមូលហេតុគ្មានសកម្មភាពដឹកនាំ និងគ្រប់គ្រងសមស្របក្នុងរយៈពេល១ឆ្នាំ
- ការមិនអនុវត្ត ឬរំលោភធ្ងន់ធ្ងរលើលក្ខខណ្ឌដែលមានចែងក្នុងលក្ខន្តិកៈ ឬបទប្បញ្ញត្តិនានា ដែលមិនធានាដល់និរន្តរភាព នៃការអភិវឌ្ឍន៍របស់អង្គការសហគមន៍មូលដ្ឋាន

### ប្រការ៤៦

ប្រសិនបើអង្គការសហគមន៍មូលដ្ឋានត្រូវបានរំលាយ ទ្រព្យសម្បត្តិ និងមូលនិធិ របស់អង្គការសហគមន៍មូលដ្ឋានទាំងអស់ ត្រូវសម្រេចដោយមហាសន្និបាតប្រចាំឆ្នាំ។

## ជំពូកទី ១៦

## នីតិវិធីនៃការកែប្រែ ឬវិសោធនកម្មលក្ខន្តិកៈ

### ប្រការ៤៧

លក្ខន្តិកៈ និងបទប្បញ្ញត្តិរបស់អង្គការសហគមន៍មូលដ្ឋាន អាចកែប្រែបានដោយយោងទៅតាមការអភិវឌ្ឍន៍របស់សហគមន៍មូលដ្ឋាននៅថ្ងៃអនាគត។ ការកែប្រែនេះអាចប្រព្រឹត្តិទៅបានតាមរយៈសម័យប្រជុំប្រាំមួយ(០៦)ខែ ឬមហាសន្និបាតប្រចាំឆ្នាំរបស់អង្គការសហគមន៍មូលដ្ឋាន។

### ប្រការ៤៨

ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ និងបទប្បញ្ញត្តិរបស់អង្គការសហគមន៍មូលដ្ឋាន ចាំបាច់ត្រូវសម្រេចដោយមហាសន្និបាតប្រចាំឆ្នាំ។ ការលើកសំណើរកែប្រែលក្ខន្តិកៈរបស់ក្រុម ត្រូវធ្វើឡើងដោយមានសមាជិកយ៉ាងតិចណាស់ចំនួន ២ភាគ៣ (២/៣) នៃសមាជិកនៃអង្គការសហគមន៍មូលដ្ឋានទាំងអស់ ហើយសំណើរនេះត្រូវដាក់ជូនអង្គមហាសន្និបាតឲ្យបាន១ខែមុនពេលបើក

មហាសន្និបាត។ ការសម្រេចកែប្រែលក្ខន្តិកៈត្រូវធ្វើឡើងដោយសំឡេង ២ភាគ៣ នៃសមាជិកទាំងអស់ដែលបានចូលរួមមហាសន្និបាត។

## ជំពូកទី ១៧
## អវសានប្បញ្ញត្តិ

### ប្រការ៤៩

សមាជិកគ្រប់រូប នៅក្នុងអង្គការសហគមន៍មូលដ្ឋាន និងគណៈកម្មការ ត្រូវអនុវត្តនូវលក្ខន្តិកៈនេះឲ្យមានប្រសិទ្ធភាព។

គណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋានត្រូវទទួលបន្ទុកផ្សព្វផ្សាយលក្ខន្តិកៈនេះឲ្យបានទូលំទូលាយទាំងនៅក្នុង និងខាងក្រៅអង្គការសហគមន៍មូលដ្ឋានរបស់ខ្លួន។

### ប្រការ៥០

លក្ខន្តិកៈ និងបទប្បញ្ញត្តិនៃអង្គការសហគមន៍មូលដ្ឋាននេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហគមន៍មូលដ្ឋានដែលបានប្រព្រឹត្តិទៅកាលពីថ្ងៃទី *២៣* ខែ *មករា* ឆ្នាំ*២០១៦* មានសុពលភាព និងអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងប្រធានគណៈកម្មការនៃអង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** តទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី*១០* ខែ*កុម្ភៈ* ឆ្នាំ*២០១៦*

| | |
|---|---|
| ប្រធាន | ប្រធាន |
| *ក្រុមប្រឹក្សាយោបល់* | *គណៈកម្មការ* |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចូលជាសមាជិក

ខ្ញុំបាទឈ្មោះ *សុខ សុខុម* អាយុ *៣៨* ឆ្នាំ បន្ទុកគ្រួសារ ចំនួន *២នាក់* ប្រុស១ ស្រី១។ មានទីលំនៅ *៣៥ ផ្លូវលំ ភូមិ បុរីកម្មករ ឃុំ ដូនទាវ ស្រុក ឯកភ្នំ ខេត្ត បាត់ដំបង*។

**សូមគោរពជូន**

ប្រធានអង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង***

**កម្មវត្ថុ៖**

ស្នើសុំចូលជាសមាជិកអង្គការសហគមន៍មូលដ្ឋាន ភូមិ *បុរីកម្មករ ឃុំ ដូនទាវ ស្រុក ឯកភ្នំ ខេត្ត បាត់ដំបង*។

ដោយខ្ញុំបាទយល់ឃើញថា ក្នុងការជួយគ្នាទៅវិញទៅមកនៅក្នុងអង្គការសហគមន៍មូលដ្ឋាន ជាការល្អប្រសើរ។ ខ្ញុំបាទ មានការពេញចិត្តចូលរួមជាសមាជិកនៅក្នុងអង្គការសហគមន៍មូលដ្ឋាន។

ខ្ញុំបាទ សូមសន្យាថា មិនបង្ករការលំបាកដល់ដំណើរការរបស់អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** ឡើយ។

អត្ថន័យ និងខ្លឹមសារក្នុងកម្មវត្ថុខាងលើ សូមលោកប្រធានអង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** មេត្តាទទួលនូវការគោរពរាប់អានពី ខ្ញុំបាទ។

ថ្ងៃទី *២៣* ខែ *មករា* ឆ្នាំ *២០១៦*
ស្នាមមេដៃ សមាជិក
*សុខ សុខុម*

ថ្ងៃទី *២៣* ខែ *មករា* ឆ្នាំ *២០១៦*
ហត្ថលេខា
ប្រធានអង្គការសហគមន៍មូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំទទួលស្គាល់អង្គការសហគមន៍មូលដ្ឋាន.............

**សូមគោរពជូន**

**លោកមេឃុំ/ចៅសង្កាត់..................**

**តាមរយៈ ៖** លោកមេភូមិ...............................................................................

**កម្មវត្ថុ ៖** សំណើសុំទទួលស្គាល់អង្គការសហគមន៍មូលដ្ឋាននៅភូមិ.........ឃុំ/សង្កាត់..........
ស្រុក/ក្រុង/ខណ្ឌ............ខេត្ត/រាជធានី.................................................................

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូនដំណឹងដល់លោកជាមេឃុំមេត្តាជ្រាបថា ភូមិរបស់យើងខ្ញុំមាន.............ដែលបច្ចុប្បន្ននេះមានជីវភាពរស់នៅខ្សត់ខ្សោយ សុខភាពទ្រុឌទ្រោម ហើយនិង...................................។ ដោយមានការផ្តួចផ្តើមគំនិត និងការគាំទ្រពីមនុស្សសំខាន់ៗនៅក្នុងភូមិ............យើងខ្ញុំបានព្រមព្រៀងគ្នាបង្កើតអង្គការសមាគមន៍មូលដ្ឋានមួយ នៅថ្ងៃទី.....ខែ...ឆ្នាំ.................។

គោលបំណងរបស់អង្គការសហគមន៍មូលដ្ឋាននេះ គឺដើម្បីឲ្យសមាជិកជួយគ្នាទៅវិញទៅមក និងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍នៅមូលដ្ឋាន។

យើងខ្ញុំសូមជូនភ្ជាប់មកជាមួយនូវ លក្ខន្តិកៈ បញ្ជីឈ្មោះសមាជិកគណៈកម្មាធិការ និងបញ្ជីឈ្មោះសមាជិកបច្ចុប្បន្នរបស់អង្គការសហគមន៍មូលដ្ឋាននេះ ចំនួនមួយច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោកមេឃុំមេត្តាទទួលស្គាល់ដល់អង្គការសហគមន៍មូលដ្ឋាន យើងខ្ញុំដោយក្តីអនុគ្រោះ។

សូមលោកមេឃុំទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ធ្វើនៅ.........ថ្ងៃទី.........ខែ.........ឆ្នាំ.............

ហត្ថលេខា និងឈ្មោះតំណាងអង្គការសហគមន៍

បានឃើញ និងគោរពជូន

លោកមេឃុំ............ជ្រាបជាព័ត៌មាន។

ថ្ងៃទី..............ខែ............ឆ្នាំ.............

**ប្រធានភូមិ**

បានឃើញ និងឯកភាព

ថ្ងៃទី.................ខែ.........ឆ្នាំ.............

ហត្ថលេខា និងត្រា

**មេឃុំ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំចុះឈ្មោះបញ្ជីអង្គការសហគមន៍មូលដ្ឋាន

ខ្ញុំបាទ នាងខ្ញុំឈ្មោះ..................ភេទ...............ជនជាតិ............សញ្ជាតិ.............. កើតនៅថ្ងៃទី..........ខែ............ឆ្នាំ...........ទីកន្លែងកំណើតនៅភូមិ..............ឃុំ/សង្កាត់ ...................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី.........................។

អាសយដ្ឋានបច្ចុប្បន្នភូមិ.............ឃុំ/សង្កាត់..............ស្រុក/ខណ្ឌ.............ខេត្ត/រាជធានី..........។ មុខងារបច្ចុប្បន្នៈ ប្រធានគណៈកម្មការអង្គការសហគមន៍មូលដ្ឋានភូមិ.............................។

## សូមគោរពជូន
## លោក ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត........................

**តាមរយៈ** មេឃុំ/សង្កាត់.....................................................................................
ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទស្រុក/ក្រុង..................................................

**កម្មវត្ថុ** សំណើសុំចុះបញ្ជីទទួលស្គាល់អង្គការសហគមន៍មូលដ្ឋាន..........នៅភូមិ......
ឃុំ...សង្កាត់/............ខណ្ឌ/ស្រុក...................ខេត្ត/រាជធានី.......................។

យោងតាមកម្មវត្ថុខាងលើនេះ ខ្ញុំបាទ/នាងខ្ញុំ សូមអនុញ្ញាត ស្នើសុំចុះបញ្ជីទទួលស្គាល់អង្គការសហគមន៍មូលដ្ឋាន................ដើម្បីចូលរួមដល់ការអភិវឌ្ឍន៍ជីវភាពរស់នៅ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋនៅសហគមន៍មូលដ្ឋាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាន មេត្តាពិនិត្យ និងដំណើរការចុះឈ្មោះទទួលស្គាល់ សហគមន៍មូលដ្ឋាន ខ្ញុំបាទ/នាងខ្ញុំ ក្នុងបញ្ជីសហគមន៍មូលដ្ឋាននៅខេត្ត/រាជធានី .........................ដោយក្តីអនុគ្រោះ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

...............ថ្ងៃទី.............ខែ...............ឆ្នាំ.......

ប្រធានគណៈកម្មការអង្គការសហគមន៍

............................

***សូមជូនភ្ជាប់មកជាមួយនូវៈ***

- ច្បាប់ដើមនៃលក្ខន្តិកៈ ចំនួន ០២ ច្បាប់
- ប្រវត្តិរូបសង្ខេបសមាជិកគណៈកម្មការ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់

# ឧបសម្ព័ន្ធគម្រូ ២

# ការសម្របសម្រួលកិច្ចប្រជុំប្រកបដោយប្រសិទ្ធភាពសម្រាប់អង្គការសហគមន៍មូលដ្ឋាន

# ការសម្របសម្រួល
# កិច្ចប្រជុំប្រកបដោយប្រសិទ្ធភាព
# សម្រាប់អង្គការសហគមន៍មូលដ្ឋាន

## ១. ការរៀបចំកិច្ចប្រជុំ

ការប្រជុំគឺជាការជួបជុំរវាងសមាជិកគណៈកម្មការ និងសមាជិករបស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីធ្វើសេចក្តីសម្រេចចិត្ត ធ្វើផែនការសកម្មភាព និងចែករំលែកបទពិសោធន៍ និងព័ត៌មានពីគ្នាទៅវិញទៅមក។

កិច្ចប្រជុំគួរតែរៀបចំឡើងឲ្យបានទៀងទាត់ អាចប្រចាំខែ ឬត្រីមាស អាស្រ័យតាមការកំណត់នៅក្នុងលក្ខន្តិកៈរបស់អង្គការសហគមន៍មូលដ្ឋាន។

## ២. គោលបំណងនៃការរៀបចំកិច្ចប្រជុំ

កិច្ចប្រជុំមានសារៈសំខាន់ក្នុងការឆ្លុះបញ្ចាំងសកម្មភាព ឬរៀបចំផែនការរួម ពិនិត្យលើលទ្ធផលការងារ ដោះស្រាយបញ្ហារួមគ្នា និងបង្កើនភាពជឿទុកចិត្ត រវាងគ្នានឹងគ្នា ដើម្បីសម្រេចគោលបំណងរបស់អង្គការសហគមន៍មូលដ្ឋាន។

ដើម្បីឲ្យកិច្ចប្រជុំមួយដំណើរការទៅមានប្រសិទ្ធភាព ទាមទារសមាជិកក្រុមលះបង់ និងមានឆន្ទៈចូលរួមគ្រប់ "ដំណាក់កាល" នៃកិច្ចប្រជុំនិមួយៗ ពីព្រោះការគ្រប់គ្រងកិច្ចប្រជុំមួយបានល្អ វាត្រូវផ្សារភ្ជាប់ទៅនឹងការចូលរួមរបស់សមាជិកក្រុម។

## ៣. ការសម្របសម្រួលកិច្ចប្រជុំ

អ្នកសម្របសម្រួលកិច្ចប្រជុំ គឺជាអ្នកត្រូវទទួលខុសត្រូវចំពោះដំណើរការកិច្ចប្រជុំ និងសមាជិកនៅក្នុងអង្គប្រជុំ តាមរបៀបវារៈដែលបានកំណត់។

ចូរចងចាំថា៖ ការដឹកនាំកិច្ចប្រជុំ គឺជាជំនាញមួយ ដែលមិនមែនជាអ្វីដែលអ្នកបានចេះដឹងពីរបៀបធ្វើវាពីកំណើតនោះឡើយ។ វាដូចនឹងជំនាញផ្សេងទៀតដែរ អ្នកនឹងទទួលបានកាន់តែល្អប្រសើរ តាមរយៈការហ្វឹកហាត់អនុវត្ត ដែលនឹងធ្វើឲ្យអ្នកកាន់តែមានទំនុកចិត្តច្រើនឡើង។

នៅពេលដែលមាននរណាម្នាក់និយាយថា ការងារល្អ "នោះគឺជាកិច្ចប្រជុំល្អ" តើពួកគេចង់មានន័យដូចម្តេច? កិច្ចប្រជុំដែលល្អពិតប្រាកដ គឺកើតឡើងនៅពេលដែលមានការយកចិត្តទុកដាក់ទៅលើដំណាក់កាលទាំង៤នៃការគ្រប់គ្រងកិច្ចប្រជុំ។

## ៤. ដំណាក់កាលទាំង៤ នៃការសម្របសម្រួល និងគ្រប់គ្រងកិច្ចប្រជុំ

- ការរៀបចំផែនការសម្រាប់កិច្ចប្រជុំ របៀបវារៈ និងគោលបំណង
- ការរៀបចំកិច្ចប្រជុំ និងភស្តុភារ

- ការសម្របសម្រួលកិច្ចប្រជុំ (អ្នកដឹកនាំ/ការសម្របសម្រួល)
- ការតាមដានត្រួតពិនិត្យ បន្ទាប់ពីកិច្ចប្រជុំនេះបានបញ្ចប់)

## ជំហានទី១៖ រៀបចំផែនការនៃកិច្ចប្រជុំ

- កំណត់គោលដៅ
- កំណត់អ្នកចូលរួម
- កំណត់របៀបវារៈ

## ជំហានទី២៖ រៀបចំកិច្ចប្រជុំ

- ចាប់ផ្តើមនិងបញ្ចប់តាមពេលវេលាកំណត់
- ចុះឈ្មោះចូលរួមកិច្ចប្រជុំ
- ខិតខំឲ្យអស់ពីសមត្ថភាព ដើម្បីធ្វើឲ្យអ្នកគ្រប់គ្នាងាយស្រួលចូលរួម
- បង្កបរិយាកាសទំនាក់ទំនងសង្គម
- វគ្គនៃការប្រជុំទៀងទាត់

## ជំហានទី៣៖ ការសម្របសម្រួលកិច្ចប្រជុំ

- ការណែនាំ
- កំណត់ការព្រមព្រៀងទៅលើរបៀបវារៈនិងគុណតម្លៃរួម
- រក្សាលើការពិភាក្សាដោយមិនចាកប្រធានបទ
- ការគ្រប់គ្រងពេលវេលា
- សង្ខេបនូវអ្វីដែលអ្នកឮ
- លើកទឹកចិត្តឱ្យមានការចូលរួម

## ជំហានទី៤៖ ការតាមដានត្រួតពិនិត្យ

- លើកទឹកចិត្តឲ្យមានការចូលរួម
- ចូរប្រមូលមតិពីក្រុម
- ការតាមដានតាមទូរស័ព្ទ
- សង្ខេបកិច្ចប្រជុំនេះ

# បញ្ជីឈ្មោះសមាជិកចូលរួមប្រជុំ
# នៃអង្គការសហគមន៍មូលដ្ឋានអភិវឌ្ឍន៍ស្រុកយើង
# លើកទី១ ប្រចាំខែកក្កដា
# ស្តីពី
# ការបង្កើតមូលនិធិសម្រាប់សិស្សពូកែភូមិយើង

- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦
- ចាប់ផ្តើមពីម៉ោង ២រសៀល បញ្ចប់នៅម៉ោង ៥ល្ងាច
- ទីកន្លែងប្រជុំៈសាលាបុណ្យភូមិបុរីកម្មករ

| ល.រ | ឈ្មោះអ្នកចូលរួម | ភេទ | អាយុ | តួនាទី | មុខរបរ | ទូរសព្ទ | ហត្ថលេខា ឬ ស្នាមមេដៃ |
|---|---|---|---|---|---|---|---|
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |

ធ្វើនៅថ្ងៃទី ……………..ខែ…………..ឆ្នាំ២០…………

**រៀបចំដោយ**

ហត្ថលេខា…………………

ឈ្មោះ ………………………

តួនាទី……………………….

# កំណត់ហេតុសម្រាប់កិច្ចប្រជុំប្រចាំខែតក្កដា

| | |
|---|---|
| អ្នកសម្របសម្រួលកិច្ចប្រជុំ | ឈ្មោះ និងតួនាទី |
| អ្នកធ្វើកំណត់ហេតុ | ឈ្មោះ និងតួនាទី |
| អ្នកចូលរួម | ឈ្មោះ និងតួនាទី |
| អ្នកអវត្តមាន | ឈ្មោះ និងតួនាទី |
| កាលបរិច្ឆេទនៃកិច្ចប្រជុំ | ម៉ោងថ្ងៃខែឆ្នាំ |
| ទីកន្លែងនៃកិច្ចប្រជុំ | ផ្ទះលេខ..... |

## គោលបំណងនៃកិច្ចប្រជុំ

.....................................................................................................................................

..........................................................................................................................

## របៀបវារៈនៃកិច្ចប្រជុំ

.....................................................................................................................................

..........................................................................................................................

## លទ្ធផលនៃកិច្ចប្រជុំ

| ប្រធានបទ និងការពិភាក្សា | ចំណុចត្រូវដោះស្រាយ និងផែនការបន្ត | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| បិទកម្មវិធីប្រជុំ | | | |

ថ្ងៃទី......ខែ.........ឆ្នាំ២០...
បានឃើញនិងឯកភាពលើកំណត់ហេតុប្រជុំដោយ
ហត្ថលេខា...................
ឈ្មោះ ..........................
តួនាទី..........................

ធ្វើនៅថ្ងៃទី......ខែ.........ឆ្នាំ២០...
រៀបចំកំណត់ហេតុប្រជុំដោយ
ហត្ថលេខា...................
ឈ្មោះ ..........................
តួនាទី..........................

# គោលការណ៍គន្លឹះ

# សម្រាប់ការរៀបចំកិច្ចប្រជុំមួយប្រកបដោយប្រសិទ្ធភាព

នៅក្នុងការងារសង្គម កិច្ចការពាណិជ្ជកម្ម ការសិក្សា និងការស្រាវជ្រាវផ្សេងៗ រមែងត្រូវមានកិច្ចពិភាក្សាមួយរបស់ខ្លួន ដើម្បីស្រាវជ្រាវស្វែងរកយុទ្ធសាស្ត្រ ឬដំណោះស្រាយនានាសម្រាប់អនុវត្តឲ្យមានប្រសិទ្ធភាព។ ប៉ុន្តែការប្រជុំទាំងអស់មិនមែនសុទ្ធតែទទួលបានផ្លែផ្កាទាំងអស់នោះទេ ពោលគឺវាមានកត្តាជាច្រើនដូចជា ប្រជុំបានលទ្ធផលហើយ តែកង្វះប្រសិទ្ធភាពក្នុងការអនុវត្ត។ មានការប្រជុំខ្លះទៀត ដំណើរការមិនចប់ចុងចប់ដើម គ្មានអ្វីជាដុំកំភួន ដែលនាំតែខាតពេលឥតប្រយោជន៍។

ខាងក្រោមនេះជាគន្លឹះ ១០ ចំណុចដែលជួយការងាររបស់សហគមន៍មូលដ្ឋានក្នុងការរៀបចំកិច្ចប្រជុំមួយប្រកបដោយប្រសិទ្ធភាព៖

១. កំណត់អ្នកសម្របសម្រួលម្នាក់ដើម្បីឲ្យទទួលខុសត្រូវលើការដឹកនាំកិច្ចប្រជុំសម្រាប់សហគមន៍មូលដ្ឋានរបស់អ្នក។ អ្នកសម្របសម្រួលជាអ្នកដឹកនាំការប្រជុំ និងសម្រេចចិត្តថា ការប្រជុំចាប់ផ្តើម បញ្ចប់ ឬផ្លាស់ប្តូរនៅពេលណា។នេះជាមូលហេតុដែលការប្រជុំរបស់អ្នកត្រូវមានអ្នកសម្របសម្រួលម្នាក់ទទួលខុសត្រូវលើចំណុចទាំងនេះ។

២. បង្កើតគោលបំណងនៃការប្រជុំ នៅពេលប្រជុំ អ្នកសម្របសម្រួលត្រូវដឹង និងយល់ឲ្យបានច្បាស់ថា តើគោលបំណងនៃការប្រជុំធ្វើឡើងដើម្បីអ្វី? គោលបំណងនៃការប្រជុំរបស់អ្នកអាចធ្វើទៅបានលុះត្រាតែ អ្នកសម្របសម្រួលស្គាល់ពីអ្វីដែលជាការចង់បាន គំនិតយោបល់ ឬគោលបំណងរបស់សមាជិកក្រុមជាមុនសិន ដើម្បីជួយឲ្យសមាជិកក្រុមទាំងមូលអាចធ្វើដំណើរឆ្ពោះទៅរកគោលដៅនោះ។

៣. លើកឡើងពីលក្ខខណ្ឌនានាត្រៀមទុកមុនពេលប្រជុំសម្រាប់អ្នកសម្របសម្រួល មុននឹងប្រជុំត្រូវបង្ហាញ ឬពណ៌នាគោលបំណងពីអ្វីដែលសមាជិកនៅក្នុងសហគមន៍ម្នាក់ៗ ត្រូវត្រៀមមុនពេលមកប្រជុំ។ សមាជិកម្នាក់ៗត្រូវរៀបចំគំនិត ឬមតិយោបល់ដែលជាទស្សនៈរបស់ខ្លួនជាមុន ឲ្យបានល្អប្រសើរ។ ប្រការនេះជាការធានាឲ្យមានប្រសិទ្ធភាព និងទំនួលខុសត្រូវពីសមាជិកម្នាក់ៗ ដើម្បីឲ្យកិច្ចប្រជុំមួយធ្វើឡើងប្រកបដោយភាពជោគជ័យ។

៤. កំណត់ចំនួនអ្នកចូលរួម៖ មកដល់ចំណុចនេះអ្នកត្រូវយល់ថា ការប្រជុំដែលមានមនុស្សកាន់តែច្រើន ប្រសិទ្ធភាពនៃការប្រជុំនោះក៏កាន់តែតិចទៅតាមនោះដែរ។ សមាជិកខ្លះ មិនសូវ

យកចិត្តទុកដាក់ស្តាប់នោះឡើយ ឬក៏និយាយកាត់នៅកំឡុងពេលមានការពិភាក្សា ដែលនេះរំខានទៅដល់ការប្រជុំទាំងមូល។ ដំណោះស្រាយដ៏ល្អ គឺត្រូវអញ្ជើញសមាជិកសំខាន់ៗឲ្យមកចូលរួមក្នុងការប្រជុំ ហើយចែកចាយពីលទ្ធផលនៃការប្រជុំបន្តទៅសមាជិកដទៃទៀតដែលមិនបានចូលរួម។

៥. អនុញ្ញាតឲ្យសមាជិកម្នាក់ៗបញ្ចេញទស្សនៈបានគ្រប់ៗគ្នា តើអ្នកចង់ឲ្យការប្រជុំរបស់អ្នកទទួលបានផ្លែផ្កាដែរឬទេ? ចម្លើយនោះអ្នកពិតជាចង់។ ប៉ុន្តែ បើប្រធានក្រុមគិតតែនិយាយតែម្នាក់ឯង មិនផ្តល់ឱកាសឲ្យសមាជិកផ្សេងទៀតបញ្ចេញទស្សនៈរបស់ខ្លួនស្មើៗគ្នាទេនោះ មិនយូរមិនឆាប់កិច្ចប្រជុំដ៏គួរឲ្យធុញមួយនឹងកើតឡើងជាមិនខាន។ សូមផ្តល់ឱកាសឲ្យសមាជិកគ្រប់រូបបញ្ចេញទស្សនៈរបស់ពួកគេ ហើយបើការប្រជុំនោះចំណាយពេលយូរ ត្រូវអនុញ្ញាតឲ្យពួកគេបានសម្រាកបន្តិចមុននឹងចាប់ផ្តើមបន្តទៅទៀត។

៦. កុំភ្លេចគោលការណ៍បោះឆ្នោត៖ មើលទៅ ការប្រជុំរបស់អ្នកហាក់មានលក្ខណៈផ្លូវការដូចការប្រជុំសភាខ្លាំងណាស់ តែតាមការពិតទៅការជ្រើសរើសយកគោលការណ៍នេះ គឺពិតជារឿងត្រឹមត្រូវ។ មានមតិខ្លះនៅក្នុងការប្រជុំ អាចធ្វើឲ្យអ្នកសម្របសម្រួលពិបាកសម្រេច។ យ៉ាងណាមិញ ការបោះឆ្នោតលើជម្រើសដែលបានលើកឡើងនីមួយៗ នឹងអាចដោះស្រាយបញ្ហាទាល់ច្រកនេះបាន និងមើលទៅវាមិនមានលក្ខណៈផ្តាច់ការផង មុនជ្រើសរើស ឬផ្អឹបទុកគំនិតយោបល់របស់សមាជិកណាម្នាក់។

៧. ទុកស្លាយមួយឡែក ហើយប្រើក្តារខៀនជំនួសវិញ ស្លាយសម្រាប់ដាក់បញ្ចាំងនៅផ្ទាំងក្រណាត់ស ឬក្តារខៀន គួរទុកមួយឡែកសិន ព្រោះថានៅពេលប្រជុំ សមាជិកនីមួយៗនឹងមានគំនិត ឬគន្លឹះថ្មីៗជាច្រើនទៀតដែលនឹងត្រូវកត់ត្រា និងដាក់បង្ហាញសម្រាប់សរសេរពន្យល់ណែនាំ។ អ្នកសម្របសម្រួលត្រូវសរសេរចំណុចសំខាន់ ឬគូរជារូបភាព ពាក្យគន្លឹះជាដើម ធ្វើយ៉ាងណាឲ្យសមាជិកក្នុងក្រុមអាចយល់បានពីអ្វីដែលមាននៅលើក្តារខៀននោះ។

៨. កុំប្រជុំនៅថ្ងៃចន្ទដើមសប្តាហ៍៖ ហេតុអ្វីបានជាអ្នកមិនគួរប្រជុំនៅថ្ងៃចន្ទ? ជាការពិតថ្ងៃចន្ទគឺជាថ្ងៃដើមសប្តាហ៍ ហេតុដូច្នេះសមាជិកភាគច្រើនមិនបានត្រៀមទុកជាមុននូវអ្វីដែលត្រូវគ្រោងទុកសម្រាប់ការប្រជុំនោះឡើយ។ ការប្រជុំដែលមានស្តង់ដារ គឺជាការប្រជុំដែលសមាជិកក្រុមនីមួយៗបានត្រៀមទុកជាមុនយ៉ាងហោចណាស់ឲ្យបានមួយថ្ងៃមុនដែរ ហើយត្រូវផ្តល់ព័ត៌មានលម្អិត ពីអ្វីដែលនឹងលើកឡើងនៅពេលប្រជុំដូចជា បញ្ហាការងារ អ្វីដែលត្រូវធ្វើក្នុងសប្តាហ៍នេះ ឬ សប្តាហ៍ក្រោយជាដើម។

៩. បញ្ចប់ការប្រជុំស្របតាមពេលកំណត់៖ នៅពេលដែលការប្រជុំមួយដំណើរការលើសពីពេលវេលាដែលបានគ្រោងទុក វាលែងទៅជាការប្រជុំមួយដែលមានស្តង់ដារទៀតហើយ ពោលវានឹងអាចធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់សមាជិកក្នុងក្រុម។ នេះបញ្ជាក់ថា ប្រសិទ្ធភាពក្នុងពេលប្រជុំក៏បាត់បន្តិចទៅតាមនោះដែរ ហើយក្រោយមកការយកចិត្តទុកដាក់ស្តាប់របស់ពួកគេប្រហែលនឹងត្រូវសាបរលាប។ ជាការល្អ នៅពេលប្រជុំមួយ គួរតែចាត់ចែងអ្នកណាម្នាក់ ធ្វើជាអ្នកគ្រប់គ្រងពេលវេលាប្រជុំ សម្រាប់បញ្ជាក់ពីពេលដែលត្រូវប្រជុំ ឬពេលវេលាដែលនៅសេសសល់ក្នុងពេលប្រជុំនោះ។

១០. បង្កើតគម្រោងអនុវត្ត តើអ្នកចូលរួមត្រលប់ទៅវិញជាមួយអ្វីខ្លះ? ចម្លើយនោះគឺមិនមែនទៅដោយដៃទទេនោះទេ ពោលគឺត្រូវបញ្ជាក់ពីតួនាទីរបស់សមាជិកក្រុមដែលត្រូវធ្វើនៅជំហានបន្ទាប់តាមរយៈការបង្កើតគម្រោងអនុវត្តមួយឲ្យពួកគេ។ គម្រោងនេះ ត្រូវសរសេរលម្អិតពីវិធីសាស្រ្ត លក្ខខណ្ឌនានា និងទំនួលខុសត្រូវរបស់សមាជិកក្រុមឲ្យបានច្បាស់លាស់ដើម្បីយកទៅអនុវត្ត៕

# ឧបសម្ព័ន្ធគម្រូ ៣

# គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្គការសហគមន៍មូលដ្ឋាន

## *ដើម្បីអភិវឌ្ឍន៍ស្រុកយើង (អ.ស.យ)*

# គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ

ថ្ងៃទី *៥* ខែ *សីហា* ឆ្នាំ២០១៦

*ផ្ទះលេខ៣៥ ផ្លូវលំ ភូមិ បូរីកម្មករ ឃុំ ដូនទាវ ស្រុក ឯកភ្នំ ខេត្ត បាត់ដំបង*

# មាតិកា


១. សេចក្តីផ្តើម ........................................................................................................ ៨០

២. ការគ្រប់គ្រងហិរញ្ញវត្ថុ ........................................................................................ ៨០

២.១. គណៈកម្មការផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ........................................................ ៨០

២.២. តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ................... ៨០

២.៣. ប្រភពចំណូល ........................................................................................ ៨១

២.៤. ការគ្រប់គ្រងសាច់ប្រាក់ ............................................................................ ៨១

២.៥. ការដកប្រាក់ពីធនាគារ ............................................................................ ៨២

២.៦. ការចំណាយ និងការទូទាត់បញ្ជី .................................................................. ៨២

២.៧. កម្រិតនៃការអនុម័តលើការចំណាយ ............................................................ ៨២

# គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ

## ១. សេចក្តីផ្តើម

គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុនេះ បង្កើតឡើងជាត្រីវិស័យមួយដើម្បីជួយតម្រង់ទិស និងជួយពង្រឹងសមត្ថភាពបន្ថែមដល់អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** ក្នុងការគ្រប់គ្រងនិងអនុវត្ត ចំណូល និងចំណាយថវិកាជាក់ស្តែងរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាព មានគណនេយ្យភាព និងតម្លាភាពនៅក្នុងអង្គការសហមគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង។*** ជាពិសេសបង្កើននូវទំនុកចិត្តគ្នាទៅវិញទៅមកទាំងនៅក្នុងក្រុមការងារ និងអង្គការដៃគូនានា។

## ២. ការគ្រប់គ្រងហិរញ្ញវត្ថុ

ការគ្រប់គ្រងហិរញ្ញវត្ថុដែលប្រកបដោយប្រសិទ្ធភាព មានគណនេយ្យភាព និងតម្លាភាពនៅក្នុងអង្គការសហមគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** គឺមានគណៈកម្មការ ដែលមានតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួន ហើយសមាជិកទាំងអស់ត្រូវតែគោរព និងអនុវត្តនូវគោលការណ៍ ដូចមានចែងខាងក្រោមនេះ៖

### ២. ១. គណៈកម្មការផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ

១. ប្រធានគណៈកម្មការ

២. អនុប្រធាន

៣. បេឡា ឬហេរញ្ញឹក

### ២. ២. តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ

**ប្រធានគណៈកម្មការ**

- ត្រួតពិនិត្យ និងអនុម័ត រាល់ចំណូល និងចំណាយជាប្រចាំ
- រាល់ការអនុម័តលើការចំណាយត្រូវតែមានការឯកភាពពីសមាជិក និងគណៈកម្មការ ៥០%+១
- ប្រជុំចែករំលែកព័ត៌មានអំពីចំណូល និងចំណាយទៅសមាជិកទាំងអស់
- គណៈកម្មាការត្រូវតែចូលរួមដឹងឮទាំងអស់គ្នា លើចំណូល និងចំណាយ
- ប្រជុំគណៈកម្មការប្រចាំខែដោយធ្វើការបូកសរុបចំណូល និងចំណាយដោយភ្ជាប់វិក័យបត្រ
- រៀបចំផែនកាថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ

### អនុប្រធាន

- ធ្វើការជាមួយប្រធានគណៈកម្មការ និងសមាជិកក្នុងដំណើរការធ្វើផែនការសកម្មភាព
- ថែរក្សាទ្រព្យសម្បត្តិ និងសំភារៈ
- ត្រួតពិនិត្យសកម្មភាពជាប្រចាំ និងរាយការណ៍ដល់គណៈកម្មការ និងសមាជិកពីសមិទ្ធផល ឬបញ្ហាផ្សេងៗដែលកើតមានឡើង
- ជំនួសមុខ ឬតំណាងឲ្យប្រធានគណៈកម្មការនៅពេលដែលអវត្តមាន

### បេឡាឬហេរញ្ញិក

- កត់ត្រានៅក្នុងសៀវភៅតូច ឬសៀវភៅធំរាល់ចំណូល និងចំណាយ(គម្រូ១៖ ទម្រង់សៀវភៅ ឬបញ្ជីកត់ត្រាចំណូល និងចំណាយប្រចាំថ្ងៃ)
- រៀបចំរបាយការណ៍ចំណូល និងចំណាយ និងបញ្ជូនទៅគណៈកម្មការដោយភ្ជាប់វិក័យបត្រចំណាយ កំណត់ហេតុ និងបញ្ជីឈ្មោះ(បើមានពាក់ព័ន្ធ)
- គ្រប់គ្រង ពិនិត្យ និងផ្ទៀងផ្ទាត់មើលរាល់ការចំណាយដែលមានវិក័យបត្រភ្ជាប់ជាមួយ
- ផ្តល់របាយការណ៍សង្ខេបពីចំណូល និងចំណាយប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំទៅដល់គណៈកម្មការ និងសមាជិកជាប្រចាំនៅពេលប្រជុំ
- រក្សាទុកឯកសារចំណូល និងចំណាយឲ្យបានត្រឹមត្រូវ

## ២.៣. ប្រភពចំណូល

ចំណូលរបស់អង្គការសហគមន៍មូលដ្ឋាន ***ដើម្បីអភិវឌ្ឍន៍ស្រុកយើង*** គឺទទួលបានពី៖

- ប្រាក់សន្សំ
- បដិភាគឃុំ
- វិភាគទានពីសមាជិកក្រុម
- មូលនិធិ អង្គការដៃគូ
- វិភាគទានពីសប្បុរសជន
- សេវាកម្ម ឬចំណូលស្របច្បាប់ផ្សេងៗ

## ២.៤. ការគ្រប់គ្រងសាច់ប្រាក់

- អ.ស.យ បានកំណត់ក្រដាសប្រាក់ជា២ប្រភេទគឺ ***ប្រាក់រៀលខ្មែរ និងប្រាក់ដុល្លា***
- ចំណូលទាំងអស់ត្រូវតែដាក់នៅក្នុង***ធនាគារ អេស៊ីលីដា*** ដោយមានគណៈកម្មការ ***បីនាក់***ជាអ្នកចុះហត្ថលេខា(ប្រធាន អនុប្រធាន និងបេឡា)

- ការគ្រប់គ្រងសាច់ប្រាក់នៅក្នុងដៃ ឬនៅក្នុងទូដែកមិនឲ្យលើសពី ***១.០០០.០០០រៀល (មួយលានរៀល)*** សម្រាប់ចំណាយបន្តិចបន្តួចប្រចាំថ្ងៃ
- ប្រធានជាអ្នកកាន់កូនសោទូដែក និងបេឡាជាអ្នកកាន់លេខកូដសម្ងាត់
- សមាជិកក្រុមចង់ខ្ចីចងការប្រាក់គឺត្រូវតែគោរព និងអនុវត្តទៅតាមគោលការណ៍ សន្សំ ខ្ចី និងសងប្រាក់(គម្រូ៣៖ គោលការណ៍ សន្សំ ខ្ចី និងសងប្រាក់)
- ការបែងចែកភាគលាភ ឬការប្រាក់ត្រូវគោរពទៅតាម គោលការណ៍ (គម្រូ៤៖ គោលការណ៍ បែងចែកភាគលាភ) និង(គម្រូ៥៖ គោលការណ៍ ប្រើប្រាស់ថវិកាសមាជិកភាព)
- ចំណូល និងចំណាយប្រចាំឆ្នាំ ត្រូវមានការត្រួតពិនិត្យដោយក្រុម គណៈកម្មការនិង អង្គការដៃគូ

## ២.៥. ការដកប្រាក់ពីធនាគារ

អង្គការសហគមន៍មូលដ្ឋាន ***អភិវឌ្ឍន៍ស្រុកយើង*** គឺបានកំណត់ការដកប្រាក់ ពីធនាគារ ***អេស៊ីលីដា*** យកមកចំណាយសម្រាប់ផ្នែកផ្សេងៗ គឺត្រូវមានគណៈកម្មការ បីនាក់ជាអ្នកចុះហត្ថលេខា (ប្រធាន អនុប្រធាន និងបេឡា) ប៉ុន្តែយ៉ាងហោចណាស់មានពីរនាក់ក្នុងចំណោមបី បើសិនជាប្រធានអវត្តមាន។

## ២. ៦. ការចំណាយ និងការទូទាត់បញ្ជី

- រាល់ការចំណាយត្រូវតែបំពេញទម្រង់ស្នើសុំចំណាយឲ្យបានត្រឹមត្រូវ (គម្រូ៦៖ ទម្រង់ស្នើសុំចំណាយ)
- ការទូទាត់ ឬជម្រះបញ្ជីក្រោយពេលចំណាយមិនឲ្យលើសពី ***២ថ្ងៃ*** ដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធចំណាយទាំងអស់
- រាល់ការចំណាយ ឬទិញអ្វីមួយលើសពី ***៨០០.០០០រៀល (ប៉ែតសិបម៉ឺនរៀល)*** ក្នុងមួយឯកតាគឺត្រូវមានសម្រង់តម្លៃឲ្យបាន ***បីហាង***
- គណៈកម្មការត្រូវរៀបចំផែនការត្រួតពិនិត្យពីអង្គការដៃគូ លើចំណូលចំណាយប្រចាំឆ្នាំ

## ២. ៧. កម្រិតនៃការអនុម័តលើការចំណាយ

| ល.រ | បរិយាយ | ចំនួនទឹកប្រាក់ក្នុងការអនុម័ត |
|---|---|---|
| ១ | ប្រធានគណៈកម្មការអាចចំណាយមុនក្នុងករណីចាំបាច់ដោយមិនបានពិភាក្សាជាមួយសមាជិកជាមុនគឺមិនលើសពី | *១០០.០០០រៀល(ដប់ម៉ឺនរៀល)* |

| | | |
|---|---|---|
| ២ | ប្រធានគណៈកម្មការមានសិទ្ធិអនុម័ត ចាប់ពី | *៤៩០.១០០ដល់១.២០០.០០០ រៀល(សែសិបប្រាំបួនម៉ឺនមួយរយរៀល ដល់មួយលានពីរសែនរៀល)* |
| ៣ | អនុគណៈកម្មការ មានសិទ្ធិអនុម័ត ចាប់ពី | *១០០រៀលដល់៤៩០.០០០ រៀល(មួយរយរៀល ដល់សែសិបប្រាំបួនម៉ឺនរៀល)* |
| ៤ | គណៈកម្មការ និងសមាជិកត្រូវតែពិភាក្សាគ្នា ឬបោះឆ្នោតឯកភាពដោយយកសម្លេង(៥០%+ ១)ចាប់ពី | *១.២០០.១០០ រៀល (មួយលានពីរសែនមួយរយរៀលឡើងទៅ)* |

**គម្រូ១**

# ទម្រង់សៀវភៅ ឬបញ្ជី កត់ត្រាចំណូល និងចំណាយប្រចាំថ្ងៃ

## សម្រាប់ ខែ កុម្ភៈ ឆ្នាំ ២០១៦

| កាលបរិច្ឆេទ | បរិយាយ | | ចំណាយ | ចំណូល |
|---|---|---|---|---|
| *០១ កុម្ភៈ ២០១៦* | *ចំនួនទឹកប្រាក់សរុបយោងមកពីខែមុន (ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦)* | *៣៥០.០០០៛* | | |
| *០២ កុម្ភៈ ២០១៦* | *ទិញនំសម្រាប់ប្រជុំសមាជិក* | | *១២.០០០៛* | |
| *០៤ កុម្ភៈ ២០១៦* | *ចូលរួមជូសជុលល្វ* | | *២០.០០០៛* | |
| *០៩ កុម្ភៈ ២០១៦* | *លក់ស្រូវ* | | | *២២.០០០៛* |
| *២៣ កុម្ភៈ ២០១៦* | *សប្បុរសជនមកទស្សនាកម្មវិធី* | | | *៣២.០០០៛* |
| *២៦ កុម្ភៈ ២០១៦* | *ចូលបុណ្យសព* | | *៤០.០០០៛* | |
| | សរុបសមតុល្យ | *៣៣២.០០០៛* | | |

ធ្វើនៅថ្ងៃទី *០១ ខែមីនា ឆ្នាំ២០១៦*

| កត់ត្រាដោយ | ផ្ទៀងផ្ទាត់ដោយ | អនុម័តដោយ |
|---|---|---|
| ហត្ថលេខា.................... | ហត្ថលេខា.................... | ហត្ថលេខា......... |
| ឈ្មោះ *សំ បាលី* | ឈ្មោះ *គាត សុខា* | ឈ្មោះ *លី បូរ៉ា* |
| តួនាទី *បេឡា* | តួនាទី *អនុប្រធាន* | តួនាទី *ប្រធាន* |
| ថ្ងៃទី *០១ ខែមីនា ឆ្នាំ២០១៦* | ថ្ងៃទី *០១ ខែមីនា ឆ្នាំ២០១៦* | ថ្ងៃទី *០២ ខែមីនា ឆ្នាំ២០១៦* |

# ទម្រង់សៀវភៅ ឬបញ្ជី កត់ត្រាចំណូល និងចំណាយប្រចាំថ្ងៃ

## សម្រាប់ ខែ មីនា ឆ្នាំ ២០១៦

| កាលបរិច្ឆេទ | បរិយាយ | | ចំណាយ | ចំណូល |
|---|---|---|---|---|
| *០១ មីនា ២០១៦* | *ចំនួនទឹកប្រាក់សរុបយោងមកពីខែមុន (ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦)* | *៣៣២.០០០៛* | | |
| *០២ មីនា ២០១៦* | *ទិញអាហារសម្រន់សម្រាប់ប្រជុំសមាជិក* | | *១២.០០០៛* | |
| *០៤ មីនា ២០១៦* | *ធ្វើមហាសន្និបាតប្រចាំឆ្នាំ* | | *២២០.០០០៛* | |
| *០៩ មីនា ២០១៦* | *លក់ស្រូវ ឬសេវាកម្មវិធី............* | | | *៥០០.០០០៛* |
| *២៣ មីនា ២០១៦* | *សប្បុរសជនមកទស្សនាកម្មវិធី ឬបានពី......* | | | *១៥០.០០០៛* |
| *២៦ មីនា ២០១៦* | *ជួសជុលរោងប្រជុំ* | | *១០០.០០០៛* | |
| *៣១ មីនា ២០១៦* | *សរុបសមតុល្យ* | *៦៥០.០០០៛* | | |

ធ្វើនៅថ្ងៃទី *៣១ ខែមីនា ឆ្នាំ២០១៦*

| កត់ត្រាដោយ | ផ្ទៀងផ្ទាត់ដោយ | អនុម័តដោយ |
|---|---|---|
| ហត្ថលេខា.................... | ហត្ថលេខា.................... | ហត្ថលេខា........... |
| ឈ្មោះ *សំ បាលី* | ឈ្មោះ *គាត សុខា* | ឈ្មោះ *លី ប៉ូរ៉ា* |
| តួនាទី *បេឡា* | តួនាទី *អនុប្រធាន* | តួនាទី *ប្រធាន* |
| ថ្ងៃទី *៣១ ខែមីនា ឆ្នាំ២០១៦* | ថ្ងៃ *ទី៣១ ខែមីនា ឆ្នាំ២០១៦* | ថ្ងៃទី *៣១ ខែមីនា ឆ្នាំ២០១៦* |

គម្រូ២

# គោលការណ៍ សន្សំ ខ្ចី និងសងប្រាក់

## ១. គោលបំណង

អង្គការសហគមន៍មូលដ្ឋាន *ដើម្បីអភិវឌ្ឍន៍ស្រុកយើង(អ.ស.យ)* បានបង្កើត គោលការណ៍ សន្សំ ខ្ចីនិងសងប្រាក់នេះឡើង ដើម្បីជម្រុញ និងលើកទឹកចិត្តឲ្យសមាជិកដែលបានចូលរួមសន្សំទាំងអស់បានទទួលផលប្រយោជន៍ពីក្រុមសន្សំរបស់ខ្លួន។ លើសពីនេះទៅទៀតគោលការណ៍នេះវាជួយជម្រុញដល់ក្រុមគណៈកម្មការ និងសមាជិកក្រុមសន្សំបំពេញតួនាទីរបស់ខ្លួន ដើម្បីឲ្យក្រុម មានដំណើរការល្អប្រកបដោយតម្លាភាព គណនេយ្យភាព និងមានការជឿជាក់គ្នាទៅវិញទៅមក និងមាននិរន្តរភាពនៅក្នុងក្រុមរបស់ខ្លួន។ ដូច្នេះក្រុមគណៈកម្មការ និងសមាជិកក្រុមសន្សំត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

## ២. លក្ខខណ្ឌក្នុងការសន្សំប្រាក់

- ការចងក្រងក្រុមសន្សំប្រាក់គឺមានសមាជិកតិចបំផុត ***១០នាក់ និងច្រើនបំផុត២៥***នាក់ ក្នុងមួយក្រុម
- សមាជិកទាំងអស់អាចដាក់ប្រាក់សន្សំតិចបំផុត ***២០០០រៀល(ពីរពាន់រៀល)*** និងខ្ពស់បំផុត ***១០០០០០០រៀល(មួយលានរៀល) ក្នុងមួយខែម្តង***ដោយជួបប្រជុំគ្នារៀងរាល់ថ្ងៃ**ទី *២៨នៃខែនីមួយៗ***
- សមាជិកទទួលបានការប្រាក់ *១.៥% ក្នុងមួយ ខែ* នៃចំនួនប្រាក់សន្សំរបស់ខ្លួន
- ក្នុងករណីសមាជិកណាមួយមានការចាំបាច់ គឺអាចដកប្រាក់សន្សំរបស់ខ្លួនមុនកាលកំណត់បានតែមិនឲ្យលើសពី៥០% នៃប្រាក់ដើមដែលសន្សំ ចំណែកការប្រាក់គឺមិនអាចដកមុនកាលកំណត់បានទេ
- ក្នុងករណីសមាជិកណាមួយសន្សំប្រាក់មិនទៀងទាត់តាមចំនួនកំណត់ លើសពី ***២ដង***នឹងត្រូវផាកពិន័យជាទឹកប្រាក់ចំនួន ***៧០០០រៀល(ប្រាំពីរពាន់រៀល)*** ។
- ទឹកប្រាក់ដែលបានមកពីការផាកពិន័យនេះ ត្រូវបានដាក់នៅក្នុងហិបចំណូលរួមរបស់ក្រុម
- សមាជិកទាំងអស់ត្រូវរក្សាកូនសៀវភៅសន្សំប្រាក់ឲ្យបានត្រឹមត្រូវ គឺមិនឲ្យបាត់បង់ រហែក ឬកខ្វក់ឡើយ

- សមាជិកទាំងអស់ត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់រាល់មួយខែម្តង និងយកកូនសៀវភៅសន្សំ ប្រាក់មកជាមួយ ដើម្បីធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់ប្រាក់ដើមសន្សំ និងការប្រាក់របស់ខ្លួនជាមួយគណៈកម្មការ
- ក្នុងករណីសមាជិកណាមួយជាប់រវល់មិនបានចូលរួមប្រជុំ គឺត្រូវផ្ញើប្រាក់សន្សំ និងកូនសៀវភៅតាមសមាជិកដែលរស់នៅជិតគ្នាបាន។

## ៣. លក្ខខណ្ឌក្នុងការខ្ចី និងសងប្រាក់

សមាជិកទាំងអស់អាចដាក់ពាក្យស្នើសុំខ្ចីប្រាក់ពីក្រុមសន្សំរបស់ខ្លួនបាន ដើម្បីយកទៅដោះស្រាយទៅតាមតម្រូវការ ឬបញ្ហាចាំបាច់ដែលបានកើតឡើងចំពោះមុខ។ គណៈកម្មការ និងសមាជិកក្រុមត្រូវប្រជុំធ្វើការសម្រេចចិត្ត និងអនុម័តរួមគ្នាមុននឹងផ្តល់ប្រាក់កម្ចីនានា ដោយមានការពិចារណាលើទំហំទឹកប្រាក់ វិភាគលើមុខរបរ ជំនាញ និងសក្តានុពល សម្រាប់ការសងត្រលប់របស់អ្នកកម្ចីប្រាក់។ ការស្នើសុំខ្ចីប្រាក់នេះគឺត្រូវអនុវត្តទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- សមាជិកក្រុមទាំងអស់មិនអនុញ្ញាតឲ្យខ្ចីជំនួសគេបានឡើយ
- សមាជិកដែលសុំខ្ចីប្រាក់ ត្រូវបង់ការប្រាក់ឲ្យទៀងទាត់រៀងរាល់ខែទៅក្រុមសន្សំរបស់ខ្លួនក្នុងអត្រាការប្រាក់ *២%* ក្នុងមួយខែ(អត្រាការប្រាក់នេះគឺសម្រាប់តែសមាជិកក្រុមប៉ុណ្ណោះ)
- សមាជិកដែលសុំខ្ចីប្រាក់ ត្រូវសងត្រលប់នូវប្រាក់**កម្ចីដើមសរុប ឬសងរំលោះ** ទៅតាមពេលវេលាដែលបានកំណត់ និងឯកភាពគ្នានៅពេលដែលខ្ចី
- ក្នុងការខ្ចីប្រាក់គឺចាំបាច់មានអ្នកធានាយ៉ាងតិចណាស់មានបីនាក់
- ក្នុងករណីសមាជិកដែលសុំខ្ចីប្រាក់ មិនបានសងទៀងទាត់តាមពេលកំណត់ នឹងត្រូវផាកពិន័យជាទឹកប្រាក់ចំនួន***៧០០០រៀល(ប្រាំពីរពាន់រៀល)***
- ទឹកប្រាក់ដែលបានមកពីការផាកពិន័យនេះ ត្រូវបានដាក់នៅក្នុងហិបចំណូលរួមរបស់ក្រុម
- ករណីសមាជិកដែលសុំខ្ចីប្រាក់ មានលទ្ធភាពសងមុនកាលកំណត់ គឺគណៈកម្មការត្រូវគិតការប្រាក់ ត្រឹមតែថ្ងៃខែដែលបានសងនោះ
- សមាជិកដែលសុំខ្ចីប្រាក់អាចខ្ចីលើកទី២ បានលុះត្រាតែសងកម្ចីលើកទី១អស់
- អ្នកដែលខ្ចីប្រាក់ក្រៅពីសមាជិកក្រុមគឺបង់អត្រាការប្រាក់***៣%ក្នុងមួយខែ*** និងត្រូវមានអ្នកធានាយ៉ាងតិចបីនាក់ និងមានដាក់បញ្ចាំវត្ថុមានតម្លៃទៅតាមការវិភាគ និងការសម្រេចចិត្តរបស់គណៈកម្មការ

- ក្នុងករណីចាំបាច់ដែលកើតឡើង ដូចជាគ្រោះថ្នាក់ណាមួយដែលបណ្តាលឲ្យបាត់បង់ជីវិតទាំងប្តីប្រពន្ធ ឬភ្លើងឆេះផ្ទះអស់ ឬគ្រោះមហន្តរាយណាមួយដែលធ្វើឲ្យខូចខាតទ្រព្យសម្បត្តិធ្ងន់ធ្ងរ គណៈកម្មការ និងសមាជិកក្រុមទាំងអស់សម្រេចលប់ចោលការប្រាក់ចាប់ពីថ្ងៃដែលកើតហេតុនោះ ចំណែកឯប្រាក់កម្ចីដើមគឺសងត្រលប់ទៅតាមពេលវេលាដែលបានកំណត់ និងឯកភាពគ្នា។

ថ្ងៃទី ......... *ខែ*......... *ឆ្នាំ*..............

**អនុម័តដោយ**

ហត្ថលេខា....................

ឈ្មោះ....................

តួនាទី....................

ថ្ងៃទី ......... *ខែ*......... *ឆ្នាំ*..............

**គម្រូ៣**

# គោលការណ៍បែងចែកភាគលាភ និងការប្រាក់

ការបែងចែកភាគលាភ ឬការប្រាក់ត្រូវធ្វើឡើងមួយឆ្នាំ ***ពីរដង (នៅពេលចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌ)។*** ការបែងចែកនេះគណៈកម្មការ និងសមាជិកទាំងអស់ត្រូវធ្វើការពិភាក្សា និងឯកភាពគ្នានៅក្នុងការបែងចែកភាគលាភ ឬការប្រាក់ទៅតាមភាគរយដែលបានមកពីចំណូលការប្រាក់សន្សំ ឬឥណទាន ឬបានមកពីសេវាកម្ម ឬកម្មវិធីស្របច្បាប់ផ្សេងៗ ដែលត្រូវបានកំណត់ដូចគោលការណ៍ខាងក្រោម៖

| លរ | បរិយាយ | ចំនួនភាគរយ (%) |
|---|---|---|
| ១ | ថវិកាសម្រាប់បង្កើនទុនបន្ថែមដកយក | *៣០%* |
| ២ | ថវិកាសម្រាប់ប្រតិបត្តិការដកយក | *២៥%* |
| ៣ | ថវិកាសម្រាប់ទុនសង្គមដកយក | *១០%* |
| ៤ | ថវិកាសម្រាប់ទុនសង្គ្រោះដកយក | *៥%* |
| ៥ | ថវិកាសម្រាប់លើកទឹកចិត្តដល់សមាជិកក្រុមដកយក | *១០%* |
| ៦ | ថវិកាសម្រាប់លើកទឹកចិត្ត និងឧបត្ថម្ភដល់ក្រុមគណៈកម្មការដកយក | *២០%* |
| | សរុប | *១០០%* |
| | ចំណែកការប្រាក់គឺសមាជិកក្រុមសន្សំម្នាក់ៗត្រូវទទួលបានការប្រាក់តាមគោលការណ៍ដែលបានកំណត់ និងទៅតាមចំនួនទឹកប្រាក់ដើមសន្សំរបស់ខ្លួន | |

ថ្ងៃទី ......... ***ខែ......... ឆ្នាំ..............***

**អនុម័តដោយ**

ហត្ថលេខា....................

ឈ្មោះ ....................

តួនាទី ....................

ថ្ងៃទី ......... ***ខែ......... ឆ្នាំ..............***

គម្រូ៤

# គោលការណ៍ប្រើប្រាស់ថវិកាសមាជិកភាព

## ១. គោលបំណង

គោលការណ៍ប្រើប្រាស់ថវិកាសមាជិកភាពនេះ គឺដើម្បីធានាបាននូវតម្លាភាព និងគណនេយ្យភាព ជាពិសេសបង្កើននូវទំនុកចិត្ត និងការចូលរួមពីសមាជិកភាព ក្នុងការអនុវត្តសកម្មភាពទទួលបានជោគជ័យ និងមាននិរន្តរភាពសម្រាប់ការអភិវឌ្ឍ នៅក្នុងសហគមន៍មូលដ្ឋាន។

ដូច្នេះថវិកាដែលចំណូលបានពីសមាជិកភាព ត្រូវបានបែងចែកសម្រាប់ការចូលរួមសកម្មភាពសង្គម និងប្រតិបត្តិការដែលបានកំណត់ដូចខាងក្រោមនេះ៖

| ល.រ | បរិយាយសកម្មភាពដែលនឹងត្រូវឧបត្ថម្ភ | ចំនួនភាគរយ (%) |
|---|---|---|
| ១. | ចូលរួមជួយសកម្មភាពសង្គម | ១០% |
| ២. | ឧបត្ថម្ភគណៈកម្មការ | ១០% |
| ៣. | ប្រតិបត្តិការ និងផ្នែករដ្ឋបាល | ២០% |
| ៤. | លើកទឹកចិត្តដល់គណៈកម្មការ និងសមាជិកសម្រាប់ប្រចាំឆ្នាំ | ១៥% |
| ៥. | ទុនបម្រុង ឬទុនការពារហានិភ័យ | ២៥% |
| ៦. | ពង្រឹងសមត្ថភាព | ១៥% |
| ៧. | ផ្សេងៗ(ករណីចាំបាច់ដែលមិនបានគិតទុកជាមុន) | ៥% |
| | **សរុប** | ១០០% |

## ២. ការសម្រេចចិត្ត និងនីតិវិធី

ការអនុវត្តគោលការណ៍ខាងលើនេះ គណៈកម្មការត្រូវមានកិច្ចប្រជុំដើម្បីធ្វើសេចក្តីសម្រេចចិត្តរួមមួយ ក្នុងការចំណាយទៅតាមភាគរយដែលបានកំណត់ដោយផ្អែកលើចំនួន ឬសម្លេង **៥០%+១** នៃចំនួនគណៈកម្មការ និងចែករំលែកព័ត៌មានដល់សមាជិកទាំងអស់ឲ្យបានដឹងពីការចំណាយនោះ។ កិច្ចប្រជុំនោះត្រូវមានកំណត់ហេតុ និងមានបញ្ជីវត្តមានទុកជាឯកសារ នៅ

ការិយាល័យ ឬកន្លែងសមរម្យដែលអាចមានភាពងាយស្រួលក្នុងការយកមកមើលបាន នៅពេលចាំបាច់ ឬត្រូវការ។

រាល់ចំណូល និងចំណាយនៃថវិកាសមាជិកភាពនេះ គណៈកម្មការត្រូវរៀបចំជារបាយការណ៍រាល់ខែ និងធ្វើបច្ចុប្បន្នភាពទៅសមាជិកទាំងអស់នៅពេលប្រជុំ គណៈកម្មការ និងសមាជិក។

ថ្ងៃទី ......... *ខែ*......... *ឆ្នាំ*..............

**អនុម័តដោយ**

ហត្ថលេខា....................

ឈ្មោះ ....................

តួនាទី ....................

ថ្ងៃទី ......... *ខែ*......... *ឆ្នាំ*..............

## គម្រូ៥

# ទម្រង់ស្នើសុំចំណាយ

- ឈ្មោះអ្នកស្នើសុំ *គាត សុខា* ភេទ *ប្រុស* អាយុ *៤១ ឆ្នាំ* តួនាទី *អនុប្រធាន នៃ អ.ស.យ*
- កាលបរិច្ឆេទស្នើសុំ *ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦*
- គោលបំណងនៃការស្នើសុំ៖ *ទិញអាហារសម្រន់សម្រាប់ប្រជុំប្រចាំត្រីមាសរបស់ គណៈកម្មការ*
- កាលបរិច្ឆេទធ្វើសកម្មភាព៖ *ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៦ នៅម៉ោង ១៖ ០០រសៀលដល់ ៥៖០០*
- ទីកន្លែង៖ *ប្រជុំនៅផ្ទះប្រធានអង្គការ អ.ស.យ*

| ល.រ | បរិយាយមុខទំនិញ | តម្លៃមួយឯកតាគិតជា<br>រៀល ឬដុល្លា | ចំនួន | សរុប<br>រៀល ឬដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | *ផ្លែឈើ* | *១០.០០០៛* | *២គីឡូ* | *២០.០០០៛* | |
| ២ | *ទឹកសុទ្ធ* | *៤.០០០៛* | *២យួរ* | *៨.០០០៛* | |
| ៣ | *នំចម្រុះមុខ* | *២.៥០០៛* | *២០ កញ្ចប់* | *៥០.០០០៛* | |
| | | | | | |
| សរុបសរសេរជាអក្សរ: *ប្រាំពីរម៉ឺនប្រាំបីពាន់រៀលគត់* | | | | ៧៨.០០០៛ | |

| ស្នើសុំដោយ | ផ្ទៀងផ្ទាត់ដោយ | អនុម័តដោយ |
|---|---|---|
| ហត្ថលេខា.................... | ហត្ថលេខា................. | ហត្ថលេខា.................... |
| ឈ្មោះ *គាត សុខា* | ឈ្មោះ *សំ បាលី* | ឈ្មោះ *លី បូរ៉ា* |
| តួនាទី *អនុប្រធាន* | តួនាទី *បេឡា* | តួនាទី *ប្រធាន* |
| ថ្ងៃទី *១៦ ខែកុម្ភៈ ឆ្នាំ២០១៦* | ថ្ងៃទី *១៦ ខែកុម្ភៈ ឆ្នាំ២០១៦* | ថ្ងៃទី *១៦ ខែកុម្ភៈ ឆ្នាំ២០១៦* |

# ឧបសម្ព័ន្ធគម្រូ ៤

# គោលការណ៍បង្ហារទំនាស់ផលប្រយោជន៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្គការសហគមន៍មូលដ្ឋាន

## *ដើម្បីអភិវឌ្ឍន៍ស្រុកយើង(អ.ស.យ)*

# គោលការណ៍បង្ការទំនាស់ផលប្រយោជន៍

ថ្ងៃទី ៥ខែ *សីហា* ឆ្នាំ២០១៦

*ផ្ទះលេខ៣៥ ផ្លូវលំ ភូមិ បូរីកម្មករ ឃុំ ដូនទាវ ស្រុក ឯកភ្នំ ខេត្ត បាត់ដំបង*

# មាតិកា

១. គោលបំណង ........................................ ៩៦
២. គោលការណ៍ និងនីតិវិធី ........................................ ៩៦
៣. ទម្រង់ប្រកាសអំពីទំនាស់ផលប្រយោជន៍ ........................................ ៩៦

# គោលការណ៍បង្ការទំនាស់ផលប្រយោជន៍

## ១. គោលបំណង

គណៈកម្មការ និងសមាជិកក្រុមនៃអង្គការសហគមន៍មូលដ្ឋានបានបង្កើតគោលការណ៍បង្ការទំនាស់ផលប្រយោជន៍នេះឡើងដើម្បីបង្ការ ឬទប់ស្កាត់ទំនាស់ផលប្រយោជន៍ផ្សេងៗ ជាពិសេសដើម្បីការពារនូវផលប្រយោជន៍រួម និងបង្កើនទំនុកចិត្តសាមគ្គីភាព ភាពស្មោះត្រង់ និងតម្លាភាព នៅក្នុងក្រុម និងសហគមន៍ផ្ទាល់។

## ២. គោលការណ៍ និងនីតិវិធី

គណៈកម្មការ និងសមាជិកក្រុមទាំងអស់ត្រូវគោរព និងអនុវត្តនូវគោលការណ៍ទប់ស្កាត់ទំនាស់ផលប្រយោជន៍ដូចបានចែងខាងក្រោមនេះ៖

- គណៈកម្មការ និងសមាជិកអង្គការសហគមន៍មូលដ្ឋានមិនអនុញ្ញាតឲ្យទទួលយកនូវកម្រៃជើងសារពីអ្នកផ្គត់ផ្គង់ ឬចំណូលស្របច្បាប់ផ្សេងៗរបស់ក្រុមទៅជាផលប្រយោជន៍បុគ្គល ឬដោយគ្មានការយល់ព្រម និងឯកភាពពីគណៈកម្មការឡើយ។
- នៅក្នុងដំណើរការប្រជុំធ្វើសេចក្តីសម្រេចចិត្តអ្វីមួយ គណៈកម្មការដែលពាក់ព័ន្ធជាមួយសាច់ញាតិមិនអនុញ្ញាតឲ្យចូលរួមនៅក្នុងកិច្ចប្រជុំនោះទេ។
- អង្គការសហគមន៍មូលដ្ឋានមានសិទ្ធិទទួលយក មូលនិធិពីអង្គការដៃគូ ឬសប្បុរសជន ឬចំណូលពីសេវាកម្មស្របច្បាប់ផ្សេងៗ ដោយដាក់ទៅជាចំណូលរួម និងប្រើប្រាស់ថវិកាទាំងនោះដោយអនុលោមតាមគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ ដែលបានកំណត់។
- អង្គការសហគមន៍មូលដ្ឋានត្រូវគោរពនូវគោលការណ៍បែងចែកភាគលាភ ដូចមានចែងនៅក្នុងគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុដោយមានការលើកកម្ពស់យេនឌ័រ។
- មិនមាននិន្នាការនយោបាយ និងប្រកាន់បក្សពួក ឬសាច់ញាតិនិយម។

## ៣. ទម្រង់ប្រកាសអំពីទំនាស់ផលប្រយោជន៍

គណៈកម្មការ និងសមាជិកទាំងអស់ត្រូវចុះហត្ថលេខាលើទម្រង់ប្រកាសអំពីទំនាស់ផលប្រយោជន៍ដូចមានភ្ជាប់នៅទំព័រខាងក្រោម។

**អនុម័តដោយ**

ហត្ថលេខា....................

ឈ្មោះ ....................

តួនាទី ....................

ថ្ងៃទី ......... ខែ......... ឆ្នាំ...............

# ទម្រង់ប្រកាសអំពីទំនាស់ផលប្រយោជន៍

ថ្ងៃទី..........ខែ.............ឆ្នាំ.............

១. ឈ្មោះ ...........................អាយុ..........ឆ្នាំ ភេទ.........
២. តួនាទី.........................

សូមអ្នកគូសសញ្ញាធិក(☑)នេះនៅក្នុងប្រអប់ណាមួយក្នុងចំណោមពីរប្រអប់ខាងក្រោម ដែលវា ពិតជាត្រូវទៅនឹងស្ថានភាពនាពេលបច្ចុប្បន្នរបស់អ្នក៖

១.☐ បន្ទាប់ពីការអាននូវគោលការណ៍បង្ការទំនាស់ផលប្រយោជន៍ដូចបានថែងខាងលើ ខ្ញុំបាទ ឬនាងខ្ញុំ សូមប្រកាសនិងធានាអះអាងថា ពិតជាមិនមានការពាក់ព័ន្ធអ្វីទាំងអស់នូវរួមទាំងតួនាទី និងមុខរបរប្រចាំថ្ងៃផងដែរ។

ខ្ញុំបាទ ឬនាងខ្ញុំ សូមសន្យាថានឹងគោរពទៅតាមគោលការណ៍នេះទាំងស្រុង ហើយក្រែងមិនប្រាកដ ខ្ញុំបាទ ឬនាងខ្ញុំសូមចុះហត្ថលេខា និងមានស្នាមមេដៃទុកជាភស្តុតាងដូចខាងក្រោមនេះ។

២.☐ បន្ទាប់ពីការអាននូវគោលការណ៍បង្ការទំនាស់ផលប្រយោជន៍ដូចបានថែងខាងលើ ខ្ញុំបាទ ឬនាងខ្ញុំ សូមប្រកាសថាពិតជាមានការពាក់ព័ន្ធទំនាស់ផលប្រយោជន៍មួយចំនួនដូចជា៖

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ហត្ថលេខា ឬ ស្នាមមេដៃ

......................................

ថ្ងៃទី..........ខែ..........ឆ្នាំ..........

# ឧបសម្ព័ន្ធគម្រូ ៥

# ទម្រង់ផ្តល់ព័ត៌មានត្រលប់ ឬបណ្តឹងតវ៉ា

# ទម្រង់ផ្តល់ព័ត៌មានត្រលប់

## ១. គោលបំណងនៃការប្រើប្រាស់ទម្រង់

អង្គការ**សហគមន៍មូលដ្ឋានសូម**ផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធទាំងអស់រួមមាន ប្រជាពលរដ្ឋដែលទទួលផលនៅក្នុងសហគមន៍ អាជ្ញាធរ អង្គការដៃគូ និងសមាជិករបស់អង្គការខ្លួន មានសិទ្ធិបញ្ចេញមតិយោបល់ ឬព័ត៌មានត្រលប់ក្នុងន័យស្ថាបនាកែលម្អដល់សមាជិក និងគណៈកម្មការរបស់អង្គការ**សហគមន៍មូលដ្ឋាន** ដើម្បីឲ្យការគ្រប់គ្រងកាន់តែមានភាពប្រសើរឡើង។

ជាពិសេស អ្នកដែលមានបំណងចង់បញ្ចេញមតិយោបល់ ឬចង់សំដែងអារម្មណ៍នូវភាពមិនពេញចិត្តចំពោះទង្វើណាមួយ ដែលស្តែងចេញដោយគណៈកម្មការ ឬសមាជិកនៃអង្គការសហគមន៍មូលដ្ឋានដែលខ្លួនបានជួប។ ដូច្នេះអង្គការសហគមន៍មូលដ្ឋានសូមលើកទឹកចិត្តដល់អ្នកដែលចង់បញ្ចេញមតិយោបល់ ឬចង់សំដែងអារម្មណ៍នោះបំពេញព័ត៌មាននៅក្នុងទម្រង់ដូចខាងក្រោម៖

## ២. ការផ្តល់ព័ត៌មានត្រលប់

១. កាលបរិច្ឆេទផ្តល់ព័ត៌មាន ថ្ងៃទី ....... ខែ ...........ឆ្នាំ ២០.....

២. លេខទូរសព្ទ ឬ អ៊ីម៉ែល(បើសិនមាន) .........................

ខ្ញុំបាទ / **នាងខ្ញុំ**/ យើងខ្ញុំឈ្មោះ .......................... អាយុ ៣២ ឆ្នាំ ភេទ ស្រី ជា៖

- ☐ សមាជិកក្រុមសន្សំ ឬ
- ☐ ប្រជាពលរដ្ឋ ឬ
- ☐ អាជ្ញាធរមូលដ្ឋាន ឬ
- ☐ អង្គការដៃគូ

នៅភូមិ ................. ឃុំ ............... ស្រុក ........................ខេត្ត/ក្រុង....................

សូម **ផ្តល់យោបល់ កែលម្អខ្លះៗ** ជាមួយ លោក/**អ្នកស្រី** .................. ដែលជា .................នៅក្នុង **អង្គការសហគមន៍មូលដ្ឋាន** នៅផ្ទះ................ ភូមិ ................. ឃុំ ............... ស្រុក ...................... ខេត្ត ...............

សូមសង្ខេបរឿងរ៉ាវនិងបញ្ជាក់កាលបរិច្ឆេទដែលបានកើតឡើងដូចខាងក្រោម៖

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

អាស្រ័យដូចបានជម្រាបជូនខាងលើសូមគណៈកម្មការមេត្តាពិចារណា និងជួយសម្របសម្រួលធ្វើការកែលម្អនូវករណីនេះទៅតាមនីតិវិធី ឬបទបញ្ជាផ្ទៃក្នុងរបស់អង្គការសហគមន៍មូលដ្ឋានឲ្យកាន់តែប្រសើរឡើងដោយអនុគ្រោះ។

សូមទទួលនូវការគោរពយ៉ាងជ្រាលជ្រៅអំពីខ្ញុំបាទ / **នាងខ្ញុំ**។

ធ្វើនៅថ្ងៃទី …… ខែ…… ឆ្នាំ ……

ហត្ថលេខា ឬស្នាមមេដៃ

…………………………..

ឈ្មោះ ………………….

តួនាទី………………

# ឧបសម្ព័ន្ធគម្រូ ៦

# ទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យ
# ផែនការសកម្មភាព

# ទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យ ផែនការសកម្មភាព

## ឧទាហរណ៍៖ តារាងផែនការសកម្មភាពរយៈពេល *៣ ឆ្នាំ ( ខែ មករា ២០១៦ ដល់ ខែ ធ្នូ ឆ្នាំ ២០១៨)*

### ១. គោលបំណងនៃទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យ

ទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យនេះជាប្រព័ន្ធមួយដើម្បីជួយដល់គណៈកម្មការ ឬអ្នកគ្រប់គ្រងអង្គការសហគមន៍មូលដ្ឋាន មានភាពងាយស្រួលក្នុងការគ្រប់គ្រងសកម្មភាពរបស់ខ្លួន និងដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តផែនការ។ មិនត្រឹមតែប៉ុណ្ណោះវាក៏ជួយដល់ក្រុមគណៈកម្មការ និងសមាជិកទាំងអស់អាចមានឱកាសធ្វើការកែលម្អនូវចំណុចដែលខ្វះខាតណាមួយដែលបានកំណត់នៅក្នុងផែនការសកម្មភាពបានទាន់ពេលវេលា។

ដើម្បីឲ្យការគ្រប់គ្រង និងដឹកនាំអង្គការសហគមន៍មូលដ្ឋានកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល គណៈកម្មការ និងសមាជិក អាចប្រើប្រាស់គម្រូទម្រង់បញ្ជីតាមដាន និងត្រួតពិនិត្យសកម្មភាពដូចខាងក្រោម ដោយគ្រាន់តែធិកឬគូសសញ្ញា(✓) នេះនៅក្នុងតារាងឧទាហរណ៍៖

| បរិយាយសកម្មភាព | | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៦ | | | | | | | | | | | | ២០១៧ | | | ២០១៨ | | |
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ |
| ១ | បណ្ដុះបណ្ដាលជំនាញសម្របសម្រួលដល់គណៈកម្មការ និង | | | x | | | | x | | | | x | | x | x | | | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សមាជិកក្រុម | | | | | | | | | | | | | | | | | | |
| ១.១ | - ប្រជុំប្រចាំខែរបស់គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ១.២ | - ប្រជុំប្រចាំត្រីមាសរបស់គណៈកម្មការ | | | x | | | x | | | x | | | x | | x | x | | x | x |
| ២ | ប្រជុំប្រចាំខែរបស់សមាជិកក្រុមសន្សំ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ២.១ | ចូលរួមប្រជុំប្រចាំត្រីមាសជាមួយបណ្តាញ ឬអាជ្ញាធរ | | | | x | | | x | | | x | | | x | | | x | | |
| ៣ | ធ្វើមហាសន្និបាតបូកសរុបលទ្ធផលប្រចាំឆ្នាំ | | | | | | | | | | | | x | | | x | | | X |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

**រៀបចំ និងត្រួតពិនិត្យដោយ**

ហត្ថលេខា…………………

ឈ្មោះ *គាត សុខា*

តួនាទី *អនុប្រធាន*

ថ្ងៃទី *២៩ ខែ មករា ឆ្នាំ២០១៦*

**បានឃើញ និងឯកភាពដោយ**

ហត្ថលេខា…………………

ឈ្មោះ លី ប៉ូវ៉ា

តួនាទី ប្រធាន

ថ្ងៃទី២៩ ខែ មករា ឆ្នាំ២០១៦

# បញ្ជីតាមដាន និងត្រួតពិនិត្យផែនការសកម្មភាព

## ប្រចាំខែ *ឧសភា ឆ្នាំ ២០១៦*

*** កំណត់សំគាល់៖**

- ផែនការសកម្មភាពប្រចាំខែខាងក្រោមនេះគឺដកស្រង់ចេញពីផែនការសកម្មភាពមេ ឬផែនការរយៈពេលពឆ្នាំខាងលើ
- សង្ខេបលទ្ធផលនៃការត្រួតពិនិត្យផែនការសកម្មភាពនូវអ្វីដែលបានធ្វើ និងមិនទាន់បានធ្វើ រួមទាំងដាក់ផែនការធ្វើបន្ត ដាក់នៅក្នុងប្រអប់ដូចខាងក្រោម៖

| ល.រ | បរិយាយសកម្មភាព | អ្នកទទួលខុសត្រូវ និងតួនាទី | មិនទាន់បានចាប់ផ្តើម | កំពុងដំណើរការ | បានធ្វើរួចហើយ | កាលបរិច្ឆេទ | | អនុសាសន៍ ឬ យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ពេលចាប់ផ្តើម | ពេលបញ្ចប់ | |
| ១ | - *បណ្តុះបណ្តាលជំនាញសម្របសម្រួលដល់គណៈកម្មការ* | ប្រធាន | | | ✓ | - *២០/០៣/២០១៦និង*<br>- *១២/០៧/២០១៦* | *២១/០៣/២០១៦និង*<br>*១៤/០៧/២០១៦* | |
| ១.១ | - *ប្រជុំប្រចាំខែរបស់គណៈកម្មការ*<br>- *រៀបចំកំណត់ហេតុប្រជុំ* | អនុប្រធាន | | | ✓ | ១០/០៥/២០១៦ | ១០/០៥/២០១៦ | |
| ១.២ | - ប្រជុំប្រចាំត្រីមាសរបស់គណៈកម្មការ<br>- រៀបចំកំណត់ហេតុប្រជុំ | - ប្រធាន | ✓ | | | ១០/០៨/២០១៦ | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | ប្រជុំប្រចាំខែរបស់សមាជិកក្រុមសន្សំ | - ប្រធានក្រុមសន្សំ | | | ✓ | ១៥/០៥/២០១៦ | ១៥/០៥/២០១៦ | |
| ២.១ | ចូលរួមប្រជុំប្រចាំត្រីមាស ជាមួយបណ្តាញ ឬអាជ្ញាធរ | - ប្រធាន | | | ✓ | ២៥/០៤/២០១៦ | ២៦/០៤/២០១៦ | |
| ៣ | ធ្វើមហាសន្និបាតបូកសរុបលទ្ធផលប្រចាំឆ្នាំ | - ប្រធាន | | | ✓ | ១៦/០២/២០១៦ | ១៦/០២/២០១៦ | |

**សង្ខេបរបាយការណ៍លទ្ធផល ត្រួតពិនិត្យ និងវាយតម្លៃនៃការសង្កេតៈ**

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

| | |
|---|---|
| **ត្រួតពិនិត្យ និងសង្ខេបរបាយការណ៍ដោយ** | **ផ្ទៀងផ្ទាត់ និងអនុម័តដោយ** |
| ហត្ថលេខា………………… | ហត្ថលេខា………………… |
| ឈ្មោះ *គាត សុខា* | ឈ្មោះ *លី ប៉ូវ៉* |
| តួនាទី *អនុប្រធាន* | តួនាទី *ប្រធាន* |
| ថ្ងៃទី *៣០ ខែ ឧសភា ឆ្នាំ២០១៦* | ថ្ងៃទី *០២ ខែ មថុនាឆ្នាំ២០១* |

# ឧបសម្ព័ន្ធគម្រូ ៧

# ករណីសិក្សាពីជោគជ័យរបស់អង្គការសហគមន៍មូលដ្ឋានដែលមានដំណើរការល្អ

# ករណីសិក្សា " ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងសហគមន៍"

**សហគមន៍នេសាទស្រុកកំពង់ត្រឡាចលើ** បានបង្កើតឡើងនៅឆ្នាំ២០០១ ហើយបានបោះឆ្នោតជ្រើសរើសគណៈកម្មការក្នុងមហាសន្និបាតចំនួនពីរលើកគឺនៅឆ្នាំ២០០៣ និងឆ្នាំ២០០៨ ។



អ្នកស្រី **កែវ ស្រីឡូត** ប្រធានសហគមន៍ស្ត្រីដើម្បីអភិវឌ្ឍន៍

នៅក្នុងដំណើរការបោះឆ្នោត ជ្រើសរើសគណៈកម្មការនោះ មានការចូលរួមពីគ្រប់កម្រិតទាំងអស់រួមមានប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន ប្រធានភូមិ ឃុំ មន្ទីរជំនាញជលផល។ល។

សហគមន៍នេសាទនេះបានចុះបញ្ជីទទួលស្គាល់ដោយមន្ទីរកសិកម្មខេត្ត និងមានរចនាសម្ព័ន្ធច្បាស់លាស់រួមមាន ប្រធាន អនុប្រធាន លេខាបេឡា ក្រុមល្បាត និងសមាជិក រួមទាំងមានអ្នកស្រី កែវ ស្រីឡូតផងដែរ ដែលបានចូលជាសមាជិកសហគមន៍នេសាទនេះនៅឆ្នាំ២០០៣។

នៅក្នុងឆ្នាំ២០០៧ សហគមន៍នេសាទនេះបានបង្កើតក្រុមសន្សំពីរក្រុម ដែលមានឈ្មោះថា "**ក្រុមស្មោះត្រង់**" និង "**ក្រុមស្ត្រីដើម្បីអភិវឌ្ឍន៍**" ដែលមានសមាជិក ២៣នាក់ ក្នុងមួយក្រុម រួមទាំងអ្នកស្រីជាសមាជិកមួយរូបផងដែរ។ ក្រុមសន្សំឈ្មោះ"ក្រុមស្ត្រីដើម្បីអភិវឌ្ឍន៍" មានរចនាសម្ព័ន្ធដោយការចាត់តាំងរួមមាន ប្រធាន អនុប្រធាន និងបេឡា ហើយសមាជិកភាគច្រើនជាស្ត្រី ។ នៅក្នុងការសន្សំគឺសមាជិកបានកំណត់ដាក់ប្រាក់សន្សំ៥០០០រៀលក្នុងមួយខែ។

ក្នុងអំឡុងឆ្នាំ២០០៨ "ក្រុមស្ត្រីដើម្បីអភិវឌ្ឍន៍" នេះ មិនសូវមានដំណើរការល្អទេ គណៈកម្មការបានសម្រេចចិត្តរំសាយចោល ដោយមិនបានរកការពិគ្រោះយោបល់ជាមួយអ្នកណាឡើយ សូម្បីតែសមាជិករបស់ខ្លួនក៏មិនបានដឹងពីមូលហេតុដែរ។

ដោយមានការសោកស្តាយ និងមានគោលបំណងចង់ជួយដល់ប្រជាពលរដ្ឋដែលនៅក្នុងសហគមន៍របស់ខ្លួនឲ្យកាន់តែប្រសើរឡើងតាមរយៈ៖

- កាត់បន្ថយការខ្ចីចងការប្រាក់ពីស្ថាប័នឯកជនដែលមានអត្រាការប្រាក់ខ្ពស់
- កាត់បន្ថយលំហូរសាច់ប្រាក់នៅក្នុងភូមិ ចេញទៅខាងក្រៅ
- ខ្ចីលុយ នៅក្នុងក្រុមខ្លួនឯងមានភាពងាយស្រួលហើយទទួលបានការប្រាក់មកខ្លួនឯងវិញ
- បង្កើនការទំនាក់ទំនងរវាងក្រុមរបស់ខ្លួន និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និទ្ធ

## *ការដឹកនាំនិងគ្រប់គ្រង*

អ្នកស្រីកែវ ស្រីឡូត បានប្តេជ្ញាចិត្តចាប់ផ្តើមកសាងក្រុមសន្សំនេះសារជាថ្មីនៅក្នុងឆ្នាំដដែល (២០០៨) ដោយដាក់ឈ្មោះថា "សហគមន៍ស្ត្រីដើម្បីអភិវឌ្ឍន៍" ដែលមានសមាជិក២១នាក់ និងបានបោះឆ្នោតរើសគណៈកម្មការចំនួន៧នាក់ រួមទាំងស្ត្រីផង ដែលមានរចនាសម្ព័ន្ធ ក្រុមប្រឹក្សាពិគ្រោះយោបល់ ប្រធាន អនុប្រធាន បេឡា លេខា ជំនួយការ អ្នកគ្រប់គ្រងហានិភ័យ និងជំនួយការទូទៅ។

សហគមន៍ស្ត្រីដើម្បីអភិវឌ្ឍន៍នេះមានការដឹកនាំ និងគ្រប់គ្រងដោយបានអនុវត្តតាមគោលការណ៍ និងឯកសារ ដែលមានពីមុនមកស្រាប់ ដូចជាលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុ គឺចុះបញ្ជីនៅក្នុងសៀវភៅធំ និងរៀបចំរបាយការណ៍នៅក្នុងកុំព្យូទ័រ រាល់ចំណូលចំណាយ និងមានគោលការណ៍ខ្ចី និងសងប្រាក់។ មានការទំនាក់ទំនងល្អជាមួយសមាជិក អាជ្ញាធរ ភូមិ ឃុំ និងមន្ទីរជំនាញពាក់ព័ន្ធនឹងប្រជាពលរដ្ឋទាំងខាងក្នុងភូមិ និងក្រៅភូមិ។ គណៈកម្មការមានការប្រជុំជាមួយសមាជិកជារៀងរាល់ខែ និងចូលរួមប្រជុំជាមួយអាជ្ញាធរ ភូមិ ឃុំ និងលើកផែនការ និងបញ្ហាទៅក្នុងអង្គប្រជុំ ផ្សព្វផ្សាយ និងកៀរគរយុវជនឲ្យចូលរួមចែករំលែកបទពិសោធន៍ទាំងនៅខាងក្នុង និងក្រៅភូមិផងដែរ។





អ្នកស្រីមានអារម្មណ៍សប្បាយចិត្តជាខ្លាំងនូវភាពរីកចម្រើន និងសមិទ្ធិផលដែលនឹកស្មានមិនដល់នៅក្នុងក្រុម របស់អ្នកស្រីក៏ដូចជាអង្គការមហាជនមូលដ្ឋានទាំងមូលដូចជា៖



- គណៈកម្មការ និងសមាជិកមានចំណេះដឹង និងយល់ច្បាស់ពីសិទ្ធិ បម្រែបម្រួលអាកាសធាតុ និងការបន្សាំខ្លួន អភិបាលកិច្ចល្អ យេនឌ័រ និងការគ្រប់គ្រងធនធានធម្មជាតិ
- សមាជិកជាស្ត្រី និងយុវជនបានចូលរួមយ៉ាងសកម្ម
- គណៈកម្មការមានការសហការគ្នាបានល្អគ្រប់កម្រិតទាំងសមាជិកក្រុម រហូតដល់ថ្នាក់ខេត្ត
- គណៈកម្មការមានតម្លាភាព និងសុចរិតភាព
- គណៈកម្មការមានការចូលរួមប្រជុំទៀងទាត់ជាមួយក្រុមប្រឹក្សាឃុំ និងបានលើកបញ្ហាឲ្យពួកគាត់ជួយដោះស្រាយ

- គណៈកម្មការមានឆន្ទៈ និងការលះបង់ខ្ពស់ក្នុងការពារផលប្រយោជន៍រួម
- សមាជិកក្រុមមានភាពក្លាហានលើកពីបញ្ហារបស់ខ្លួនយកមកដោះស្រាយ
- សមាជិកក្រុមសន្សំបានកើនឡើងដល់១៧០នាក់ និងមានចំនួនទឹកប្រាក់សរុបជិត៩០០រយលានរៀល) ៣៩១.២០០.០០០៛ (រួមទាំងចំណូលពី**សប្បុរសជន និងអង្គការដៃគូមាន (FACT)** ជាដើម
- ជួយបាន**៩៦គ្រួសារ** ដែលមិនមែនជាសមាជិក។ វាបានជួយពួកគាត់ក្នុងការកាត់បន្ថយការទៅចងការប្រាក់ពីឯកជន
- បង្កើតបានរោងអាជីវកម្មខ្នាតតូច មួយកន្លែង
- ចូលរួមជួយជាមួយអង្គការសហគមន៍នេសាទកំពង់ត្រឡាចលើ និងសង់រោងសម្រាប់ប្រជុំបានមួយកន្លែង
- ជួយឧបត្ថម្ភដល់សិស្សសាលាដែលរៀនពូកែ និងជួយបង្កើតការងារឲ្យយុវជន (ឧ. ជួយផ្សព្វផ្សាយ ចែកខិតបណ្ណ ជ្រើសរើសយុវជនជាបុគ្គលិកជាដើម
- មានភ្ញៀវមកទស្សនកិច្ចទាំងខាងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងអាស៊ានទាំង១០ផងដែរ បង្កើតបានក្រុមសន្សំប្អូនក្រុមថែមទៀតចាប់តាំងពីឆ្នាំ២០១១ រហូតដល់២០១៣



រោងអាជីវកម្មខ្នាតតូច

ថ្វីត្បិតតែមានការរីកចម្រើនក៏ដោយ ក៏អ្នកស្រីមានការព្រួយបារម្ភមួយចំនួនផងដែរ ដូចជាសមត្ថភាពនៅមានកំរិត ទាំងសមាជិកក្រុម និងគណៈកម្មការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ(ទុនក្រុមសន្សំបានកើនឡើងជាខ្លាំង) និងចំណេះដឹងទូទៅក៏ដូចជា ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាដើម។

## *កត្តាដែលនាំឲ្យជោគជ័យ*

ជារួមអ្វីដែលធ្វើឲ្យក្រុមអ្នកស្រីទទួលបានជោគជ័យ គឺការចូលរួមទាំងសមាជិកក្រុមគ្រួសារ និងអ្នកពាក់ព័ន្ធ មានទំនាក់ទំនងល្អទាំងខាងក្នុង និងខាងក្រៅរួមមានអាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ មន្ទីរជំនាញ ប៉ូលីស អង្គការដៃគូ ដូចជាអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល សមាគមភ្នំនាងកង្រី ជាដើម។ ជាមួយតម្លាភាព និងគណនេយ្យភាពទាំងថវិកា និងព័ត៌មាន មានការជឿជាក់ពីសមាជិក និងអ្នកពាក់ព័ន្ធ និងបានអនុវត្តន៍ទៅតាមច្បាប់និងគោលការណ៍ដូចជា៖

- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង(ការទទួលខុសត្រូវរបស់គណៈកម្មការ គោលការណ៍ខ្ចី និងសងការប្រាក់...។ល។
- ផែនទីសហគមន៍ និងផែនការគ្រប់គ្រងសហគមន៍
- កិច្ចព្រមព្រៀង និងបញ្ជីឈ្មោះសមាជិក

- គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងប្រើប្រព័ន្ធកុំព្យូទ័រ
- កូនសៀវភៅសន្សំប្រាក់
- គោលការណ៍យេនឌ័រ
- គោលការណ៍ប្រឆាំងអំពើពុករលួយ
- គោលការណ៍ប្រើប្រាស់សំភារៈ

អ្នកស្រីមានមហិច្ឆតាចង់ក្លាយខ្លួនជាស្ថាប័នឯករាជ្យទៅថ្ងៃអនាគត ហើយក៏មាន សំណូមពរដល់អង្គការ **គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា** និងអង្គការដៃគូនានាជួយពង្រឹងសមត្ថភាពដល់ពួកគាត់អំពីរបៀបគ្រប់គ្រងសហគមន៍ និងគ្រប់គ្រងហិរញ្ញវត្ថុផងដែរ។

# ឧបសម្ព័ន្ធគម្រូ ៨

# ករណីសិក្សា

# អង្គការសហគមន៍មូលដ្ឋានដែលមិនសូវមានដំណើរការល្អ

# ការដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទមួយនៅស្រុកជលគិរី

សហគមន៍នេសាទមួយនៅក្នុងឃុំកោះថ្កូវ ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង។ សហគមន៍នេសាទនេះបានបង្កើតឡើងនៅឆ្នាំ២០០១ និងមិនទាន់បានចុះបញ្ជីស្របច្បាប់នៅឡើយទេ តែមានការទទួលស្គាល់ និងដឹងឮដោយមន្ទីរជលផលខេត្ត ។ សហគមន៍នេសាទនេះបានបោះឆ្នោតជ្រើសរើសគណៈកម្មការលើកទីមួយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១១ មានគណៈកម្មការចំនួន១១នាក់ តែក្រោយមកគណៈកម្មការបីនាក់បានលាឈប់ បច្ចុប្បន្នគណៈកម្មការមាន ចំនួន ៨នាក់(ស្ត្រី២នាក់)។

ដោយគណៈកម្មការមិនសូវមានដំណើរការល្អ សហគមន៍នេសាទបានបោះឆ្នោតជ្រើសរើសគណៈកម្មការសាជាថ្មីនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១២ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងភូមិ ទាំងអស់២៦០គ្រួសារ មានអាជ្ញាធរ ឃុំ មន្ទីរជំនាញជលផល និងអង្គការដៃគូជាដើម។ សហគមន៍នេសាទមានរចនាសម្ព័ន្ធ *ប្រធាន អនុប្រធាន(ជាបងប្អូនបង្កើត)* បេឡា និងសមាជិក។ គណៈកម្មការទាំងអស់មិនមានប្រាក់ខែឧបត្ថម្ភទេ ក្រៅពីថវិកាដែលទទួលបានដំតិចតួចស្តួចស្តើងពីសេវាកម្មតែប៉ុណ្ណោះ ដូចជានៅពេលដែលចេញទៅល្បាត ឬចុះចាប់បទល្មើសម្តងៗបាន៥០០០រៀល។

គណៈកម្មការមានការទទួលខុសត្រូវរួមគ្នាគឺ ចេញល្បាតទាំងយប់ ទាំងថ្ងៃ ចូលរួមសកម្មភាពជាមួយអាជ្ញាធរ មន្ទីរជលផលខេត្ត ប្រជុំជាមួយប្រជាពលរដ្ឋដើម្បីផ្សព្វផ្សាយព័ត៌មានច្បាប់ ចូលរួមជាមួយប៉ូលីស ជួយការពារនៅតំបន់ផ្សេងៗទៀតក្រៅពីភូមិរបស់ខ្លួន។

សហគមន៍នេសាទនេះបង្កើតឡើងក្នុងឆន្ទៈការពារធនធានធម្មជាតិ (ការពារតំបន់អភិរក្សត្រី ឬឡូត៍នេសាទ) ទុកឲ្យកូនចៅជំនាន់ក្រោយ។ ក្រៅពីតំបន់អភិរក្សនេះគឺ មានតំបន់ផ្សេងៗទៀតដែលសម្រាប់ទុកឲ្យប្រជាពលរដ្ឋអាចរកត្រីបាន ។

សហគមន៍នេសាទមានប្រភពចំណូលបានមកពីសមាជិកភាព នៅពេលដែលគេចេញទៅនេសាទក្នុងម្នាក់បង់២០០០រៀល ក្រៅពីសមាជិកគឺបង់៥០០០រៀល ឬបង់តម្លៃតាមសម្ភារៈនេសាទ ហើយក៏មានជំនួយពីសប្បុរសជននៅសហរដ្ឋអាមេរិកបានជួយ ចំនួន៣លើកគឺ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ លើកទី២ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ និងលើកទី៣នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៤ សរុបចំនួន**៦លានរៀល។** ថវិកានេះគឺទុកដើម្បីជួយដល់គណៈកម្មការ ក្នុងការធ្វើការងារ និងជួយប្រជាពលរដ្ឋក្នុងភូមិ តាមរយៈការខ្ចីចងការប្រាក់ទាំងសមាជិក និងប្រជាពលរដ្ឋក្នុងអត្រាការប្រាក់២%ក្នុងមួយខែ។

បើគិតតាំងពីឆ្នាំ២០០៩ រហូតដល់២០១៣ ចំណូលមានការកើនឡើងសរុបប្រហែល **៧ លានរៀលកន្លះ** ប៉ុន្តែបានធ្លាក់ចុះជាង២លានរៀលនៅឆ្នាំ២០១៤ និង២០១៥។ ចំណូលទាំងនោះគណៈកម្មការបានចូលរួមឧបត្ថម្ភនៅក្នុងសង្គមដូចជា ការសាងសង់រោងបុណ្យ សង់បង្គន់មួយនៅក្នុងរោងបុណ្យ សង់បង្គន់មួយទៀតនៅក្នុងសាលារៀន បានជួយទិញចានឆ្នាំងសម្រាប់ប្រជាពលរដ្ឋក្នុងភូមិខ្ចីប្រើប្រាស់នៅពេលមានបុណ្យទាន ជួយឧបត្ថម្ភកាត់សម្លៀកបំពាក់ឲ្យប្រជាការពារភូមិបាន១៥នាក់ ឬ១៥កំផ្លេ និងបានជួយចូលរួមបុណ្យសពផងដែរ។

ក្រៅពីចូលរួមជួយសកម្មភាពសង្គម គណៈកម្មការបានទិញកាណូតមួយដើម្បីទុកចុះល្បាត និងជួយដល់ប្រជាពលរដ្ឋនៅពេលឈឺ ឬស្រ្តីឆ្លងទន្លេដើម្បីទៅមន្ទីរពេទ្យបានទាន់ពេល។ ការទិញកាណូតមានការប្រជុំពិគ្រោះយោបល់ជាមួយ ប្រជាពលរដ្ឋ អាជ្ញាធរ មេភូមិ មេឃុំ មន្ទីរជំនាញ និងអង្គការដៃគូ។

ការគ្រប់គ្រងហិរញ្ញវត្ថុ គឺមិនមានឯកសារណាមួយ ឬគោលការណ៍ច្បាស់លាស់ទេ ដូចជាការអនុវត្តជាក់ស្តែង ក្នុងការខ្ចីចងការប្រាក់ គឺគណៈកម្មការប្រជុំសម្រេចចិត្តឯកភាពគ្នាផ្ទាល់មាត់តែប៉ុណ្ណោះ នៅពេលឲ្យនរណាម្នាក់ខ្ចី ដោយកំណត់មិនឲ្យលើសពី៣ខែទេ។ ប៉ុន្តែជាក់ស្តែង អ្នកដែលខ្ចីចងការប្រាក់នោះមិនបានអនុវត្តតាមកាលកំណត់នោះទេទាំងសមាជិក និងប្រជាពលរដ្ឋ (ឧ. អ្នកខ្លះខ្ចីរហូតដល់ទៅ៥ទៅ៦ខែ មិនទាន់សងទាំងការទាំងដើមផងដែរ)។ សហគមន៍នេសាទនេះមិនទាន់មានគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងគោលការណ៍សំខាន់ផ្សេងៗសម្រាប់ការអនុវត្តរបស់ខ្លួននៅឡើយទេ ប៉ុន្តែបានអនុវត្តតាមគោលការណ៍របស់អង្គការដៃគូ ។

ដោយមិនមានគោលការណ៍ជាក់លាក់ណាមួយ និងរួមទាំងសមត្ថភាពនៅមានកំរិតផងនោះ វាជាកត្តាដែលនាំឲ្យសហគមន៍នេសាទនេះ បានជួបប្រទះផលលំបាកជាខ្លាំងក្នុងការចុះបំពេញការងារ ដូចជាខ្វះថវិកា សំភារៈ និងមធ្យោបាយធ្វើដំណើរនៅពេលចេញល្បាត និងខ្វះការចូលរួមពីសមាជិកក្រុម ប្រជាពលរដ្ឋ អាជ្ញាធរ និងមន្ទីរពាក់ព័ន្ធនៅមានកំរិតជាដើម។ កត្តាទាំងអស់នេះបានធ្វើឲ្យសមាជិកគណៈកម្មការខ្លះ មានអារម្មណ៍បាក់ទឹកចិត្ត និងចង់បោះបង់ការងាររបស់ខ្លួនទៀតផង។

# ឧបសម្ព័ន្ធគម្រូ ៩

# បញ្ជីអ្នកចូលរួមពាក់ព័ន្ធបង្កើត
# គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់
# អង្គការសហគមន៍មូលដ្ឋាន

# បញ្ជីរាយនាមក្រុមការងារបច្ចេកទេសដែលគាំទ្រ និងចូលរួមបង្កើត គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

| ល.រ | ឈ្មោះស្ថាប័ននៃសមាជិកក្រុមការងារបច្ចេកទេស | | ខេត្ត និង ក្រុង |
|---|---|---|---|
| ១ | អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា | Cooperation Committee for Cambodia (CCC) | ភ្នំពេញ |
| ២ | អង្គការជីវិតថ្លៃថ្នូរ | Life With Dignity (LWD) | ភ្នំពេញ |
| ៣ | អង្គការ ជនពិការកម្ពុជា | Cambodian Disability People's Organization (CDPO) | ភ្នំពេញ |
| ៤ | អង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការ | Disability Development Services Program (DDSP) | ខេត្តពោធិ៍សាត់ |
| ៥ | អង្គការហ្វ៊រមស៊ីដ | Forum Syd | ភ្នំពេញ |
| ៦ | សហគមន៍កសិកម្មត្រពាំងក្រញូង | *(គ្មានឈ្មោះជាភាសាបរទេស)* | ខេត្តតាកែវ |
| ៧ | សហគមន៍កសិកម្មត្រពាំងធំ | *(គ្មានឈ្មោះជាភាសាបរទេស)* | ខេត្តតាកែវ |
| ៨ | អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន | Environmental Protection And Development (PDAO) | ខេត្តតាកែវ |
| ៩ | អង្គការស្រែខ្មែរ | Srer Khmer | ភ្នំពេញ |
| ១០ | អង្គការទ្រទ្រង់កសិករជនបទ | Support Organization for Rural Farmers (SORF) | ខេត្តពោធិ៍សាត់ |
| ១១ | សហគមន៍ក្រុមជនជាតិដើមភាគតិច | Por ethnic group | បវេល ខេត្តបាត់ដំបង |
| ១២ | អង្គការជំនួយរបស់ព្រះវិហារដាណឺម៉ាក | DanChurchAid (DCA) | ភ្នំពេញ |
| ១៣ | អង្គការបន្ទាយស្រី | Banteay Srei | ភ្នំពេញ |
| ១៤ | អង្គការគាំទ្រសហគមន៍ | Indigenous Community Support Organization (ICSO) | ភ្នំពេញ |

| | | | |
|---|---|---|---|
| | ជនជាតិដើមភាគតិច | | |
| ១៥ | សហគមន៍នេសាទ | *(គ្មានឈ្មោះជាភាសាបរទេស)* | ខេត្តពោធិ៍សាត់ |
| ១៦ | សហគមន៍បរវិល | *(គ្មានឈ្មោះជាភាសាបរទេស)* | បរវិល ខេត្តបាត់ដំបង |
| ១៧ | បណ្តាញសមាជិកសកម្ម សិទ្ធិជនជាតិដើមភាគតិច | Indiginous Rights Active Member (IRAM) | ស្នួល ខេត្តក្រចេះ |
| ១៨ | សហគមន៍នេសាទ | *(គ្មានឈ្មោះជាភាសាបរទេស)* | ខេត្ត សៀមរាប |
| ១៩ | សម្ព័នភាពដើម្បីអភិរក្សធនធានជលផល | Fisheries Action Coalition Team (FACT) | ភ្នំពេញ |
| ២០ | សហគមន៍នេសាទ | *(គ្មានឈ្មោះជាភាសាបរទេស)* | ឆ្នុកទ្រូ(ផាត់សាដាយ) ខេត្តកំពង់ឆ្នាំង |
| ២១ | សហគមន៍នេសាទ | *(គ្មានឈ្មោះជាភាសាបរទេស)* | ខេត្ត សៀមរាប |
| ២២ | សមាគមសហព័ន្ធមនុស្សចាស់ | *(គ្មានឈ្មោះជាភាសាបរទេស)* | បាណន់ ខេត្តបាត់ដំបង |

*(សម្រង់ពីបញ្ជីវត្តមាន)*

# បញ្ជីរាយនាមស្ថាប័នរាជរដ្ឋាភិបាលដែលគាំទ្រ និងចូលរួមក្នុងដំណើរការបង្កើតគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

| ល.រ | ឈ្មោះស្ថាប័ន | ខេត្ត និង ក្រុង |
|---|---|---|
| ១ | ក្រសួងមហាផ្ទៃ | ភ្នំពេញ |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ភ្នំពេញ |
| ៣ | ក្រសួងអភិវឌ្ឍន៍ជនបទ | ភ្នំពេញ |
| ៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ភ្នំពេញ |
| ៥ | ក្រសួងអប់រំ យុវជន និងកីឡា | ភ្នំពេញ |
| ៦ | ក្រសួងសុខាភិបាល | ភ្នំពេញ |

*(សម្រង់ពីបញ្ជីវត្តមាន)*

# បញ្ជីរាយនាមដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិដែលចូលរួមក្នុងដំណើរការបង្កើតគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

| លរ | ឈ្មោះអង្គការដៃគូអភិវឌ្ឍន៍ | | ខេត្ត និង ក្រុង |
|---|---|---|---|
| ១ | ស្ថានទូតអូស្ត្រាលីប្រចាំការនៅកម្ពុជា | Development Cooperation, Australian Embassy | ភ្នំពេញ |
| ២ | អង្គការជំនួយរបស់ព្រះវិហារ ដាណឺម៉ាក | DanChurchAid (DCA) | ភ្នំពេញ |
| ៣ | អង្គការ Save the Children | Save the Children (SC) | ភ្នំពេញ |
| ៤ | ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ | United Nations Resident Coordinator (UNRC) Office | ភ្នំពេញ |
| ៥ | អង្គការហ្វូរ៉ុមស៊ីដ | Forum Syd | ភ្នំពេញ |

*(សម្រង់ពីបញ្ជីវត្តមាន)*

# បញ្ជីរាយនាមអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រ និងចូលរួមក្នុងដំណើរការបង្កើតគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

| ល.រ | ឈ្មោះអង្គការមិនមែនរដ្ឋាភិបាល | | ខេត្ត និង ក្រុង |
|---|---|---|---|
| ១ | អង្គការក្រុមទ្រទ្រង់ភូមិ | Village Support Group (VSG) | ខេត្តបាត់ដំបង |
| ២ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព | People Center for Development and Peace (PDP) | ខេត្តបាត់ដំបង |
| ៣ | អង្គការមនុស្សចាស់ | Help Age Cambodia | ខេត្តបាត់ដំបង |
| ៤ | អង្គការក្រុមអភិវឌ្ឍន៍ភូមិ | Krom Akphiwat Phum (KAWP) | ខេត្តបាត់ដំបង |
| ៥ | អង្គការកែប្រែសហគមន៍ | Community Translation Organization (CTO) | សំរោង ខេត្តឧត្តរមានជ័យ |
| ៦ | សម្ព័នភាពដើម្បីអភិរក្សធនធានជលផល | Fisheries Action Coalition Team (FACT) | ភ្នំពេញ |
| ៧ | អង្គការ ស៊ី.ភី.អេ | CPA | ថ្មពួក ខេត្តបន្ទាយមានជ័យ |
| ៨ | អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បី អភិវឌ្ឍន៍សង្គម | Buddhism for Social Development Action (BSDA) | ខេត្តកំពង់ចាម |
| ៩ | អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ | Phnom Srey Organization for Development (PSOD) | ខេត្តកំពង់ចាម |
| ១០ | សមាគមន៍ថែរក្សាបរិស្ថាន និងវប្បធម៌ | Culture and Environment Preservation Association (CEPA) | ខេត្តស្ទឹងត្រែង |
| ១១ | អង្គការភូមិខ្ញុំ | My Village (MVi) | ខេត្តស្ទឹងត្រែង |
| ១២ | អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង | Urban Poor Women Development (UPWD) | ភ្នំពេញ |
| ១៣ | អង្គការអនុផលព្រៃឈើ | Non-Timber Forest Products (NTFP) | ខេត្តរតនៈគីរី |

| | | | |
|---|---|---|---|
| ១៤ | មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា | Children and Women Development Center in Cambodia (CWDCC) | ខេត្តកំពត |
| ១៥ | អង្គការទ្រទ្រង់ស្ត្រីខ្មែរ | Cambodian Organization for Women Support (COWS) | ខេត្ត កំពង់ធំ |
| ១៦ | សហគមន៍កសាងសមត្ថភាពដើម្បីអភិវឌ្ឍន៍ | Community Capacity for Development (CCD) | ខេត្តកំពង់ឆ្នាំង |
| ១៧ | សមាគមភ្នំនាងកង្រី | Phnom Neang Kangrei Association(PNKA) | ខេត្តកំពង់ឆ្នាំង |
| ១៨ | អង្គការជំនួយជនបទ | Rural Aid Organization (RAO) | ខេត្តស្វាយរៀង |
| ១៩ | អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន | Environmental Protection And Development (PDAO) | ខេត្តតាកែវ |
| ២០ | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ | Cambodian Women's Crisis Center (CWCC) | ភ្នំពេញ |
| ២១ | អង្គការសង្គ្រោះសត្វព្រៃ | Save Cambodia's Wildlife (SCW) | ភ្នំពេញ |
| ២២ | អង្គការមិត្តសម្លាញ់ | Mithsamlanh | ភ្នំពេញ |
| ២៣ | អង្គការគ្រួសារយើង | Krousaryoeung | ភ្នំពេញ |
| ២៤ | អង្គការគាំទ្រសហគមន៍ ជនជាតិដើមភាគតិច | Indigenous Community Support Organization (ICSO) | ភ្នំពេញ |
| ២៥ | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា | The NGO Forum on Cambodia | ភ្នំពេញ |
| ២៦ | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា | Legal Aid of Cambodia (LAC) | ភ្នំពេញ |
| ២៧ | អង្គការអភិវឌ្ឍន៍សំលេង សហគមន៍ | Building Community Voices (BCV) | ភ្នំពេញ |
| ២៨ | អង្គការសកម្មភាពដើម្បីសុខមាលភាពស្ត្រីកម្ពុជា | Kampuchea Women's Welfare Action ( KWWA) | ខេត្តក្រចេះ |
| ២៩ | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ | Community Economic Development (CED) | ខេត្តក្រចេះ |

| | | | |
|---|---|---|---|
| ៣០ | អង្គការពន្លឺនៃក្តីសង្ឃឹម | Ponleu Ney Kdey Sangkhim ( PNKS) | ខេត្តព្រៃវែង |
| ៣១ | អង្គការអភិវឌ្ឍន៍ភូមិយើង | Organization to Develop Our Village (ODOV) | ខេត្តព្រៃវែង |
| ៣២ | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន | Youth Resource Development Program (YRDP) | ភ្នំពេញ |
| ៣៣ | អង្គការអូខិនដិន កម្ពុជា | Ockenden Cambodia | បន្ទាយមានជ័យ |
| ៣៤ | សមាគមន៍អាដហុក | Cambodian Human Rights and Development Association (ADHOC) | ខេត្តក្រចេះ |
| ៣៥ | អង្គការអតីតយុទ្ធជនអន្តរជាតិកម្ពុជា | Veterans International Cambodia (VIC) | ភ្នំពេញ |

*(សម្រង់ពីបញ្ជីវត្តមាន)*

# បញ្ជីរាយនាមសហគមន៍ដែលគាំទ្រ និងចូលរួមបង្កើតគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

| ល.រ | ឈ្មោះអង្គការសហគមន៍មូលដ្ឋាន | ស្រុក និង ខេត្ត |
|---|---|---|
| ១ | សហគមន៍ | គោកឃ្មុំ ខេត្តបាត់ដំបង |
| ២ | សហគមន៍ | រកា ខេត្តបាត់ដំបង |
| ៣ | សហគមន៍ | ភ្នំសំពៅ ខេត្តបាត់ដំបង |
| ៤ | សហគមន៍ | ព្រៃកហ្លួង ខេត្តបាត់ដំបង |
| ៥ | សហគមន៍ | អូរតាគី ខេត្តបាត់ដំបង |
| ៦ | សហគមន៍ | ល្វា ខេត្តបាត់ដំបង |
| ៧ | សហគមន៍សហព័ន្ធមនុស្សចាស់ | បាយដំរាំ ខេត្តបាត់ដំបង |
| ៨ | សហគមន៍ | ក្បាលត្រាច ខេត្តពោធិ៍សាត់ |
| ៩ | សហគមន៍ | អន្សាចំបក់ ខេត្តពោធិ៍សាត់ |
| ១០ | សហគមន៍ | ក្រគរ ខេត្តពោធិ៍សាត់ |
| ១១ | សហគមន៍ព្រៃឈើ | សំរោង ខេត្តឧត្តរមានជ័យ |
| ១២ | សហគមន៍ | បន្ទាយអំពិល ខេត្តឧត្តរមានជ័យ |
| ១៣ | សហគមន៍TPCBO | ខេត្តឧត្តរមានជ័យ |
| ១៤ | សហគមន៍ | ខេត្តឧត្តរមានជ័យ |
| ១៥ | សហគមន៍BTACBO | ខេត្តឧត្តរមានជ័យ |
| ១៦ | សហគមន៍ព្រៃឈើ | ថ្មពួក ខេត្តបន្ទាយមានជ័យ |
| ១៧ | សហគមន៍ | មង្គលបូរី ខេត្តបន្ទាយមានជ័យ |
| ១៨ | សហគមន៍ | សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ |
| ១៩ | សហគមន៍ | ខេត្តបន្ទាយមានជ័យ |

| | | |
|---|---|---|
| ២០ | សហគមន៍ | ខេត្តបន្ទាយមានជ័យ |
| ២១ | សហគមន៍ | ស្រីស្នំ ខេត្តសៀមរាប |
| ២២ | សហគមន៍ | ស្រីស្នំ ខេត្តសៀមរាប |
| ២៣ | សហគមន៍ | សូទ្រនិគម ខេត្តសៀមរាប |
| ២៤ | សហគមន៍ព្រៃឈើ ប្រាសាទបល្ល័ង្គ | ប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ |
| ២៥ | សហគមន៍ | អូររាំងឪ ខេត្តកំពង់ចាម |
| ២៦ | សហគមន៍ | ខេត្តកំពង់ចាម |
| ២៧ | សហគមន៍ | ស្នួល ខេត្តក្រចេះ |
| ២៨ | សហគមន៍ | ស្នួល ខេត្ត ក្រចេះ |
| ២៩ | សហគមន៍ | សំបូរ ខេត្តក្រចេះ |
| ៣០ | សហគមន៍ | សំបូរ ខេត្តក្រចេះ |
| ៣១ | សហគមន៍ | សំបូរ ខេត្តក្រចេះ |
| ៣២ | សហគមន៍ | សំបូរ ខេត្តក្រចេះ |
| ៣៣ | សហគមន៍ | ខេត្តក្រចេះ |
| ៣៤ | សហគមន៍នេសាទ | ត្រពាំងសង្កែ ខេត្តកំពត |
| ៣៥ | សហគមន៍នេសាទ | ត្រពាំងសង្កែ ខេត្តកំពត |
| ៣៦ | សហគមន៍ព្រៃឈើភ្នំទ័ពជាង | ស្រែអំបិល ខេត្តកោះកុង |
| ៣៧ | សហគមន៍តំបន់ ការពារធម្មជាតិ ព្រាំងចំការក្រោម | ស្រែអំបិល ខេត្តកោះកុង |
| ៣៨ | សហគមន៍តំបន់ ការពារធម្មជាតិ អណ្តូងទឹក | អណ្តូងទឹក ខេត្តកោះកុង |
| ៣៩ | សហគមន៍តំបន់ ការពារធម្មជាតិ | អណ្តូងទឹក ខេត្តកោះកុង |

| | | |
|---|---|---|
| ៩០ | សហគមន៍នេសាទតំបន់ឆ្នេរថ្មស | ថ្មស ខេត្តកោះកុង |
| ៩១ | សហគមន៍នេសាទ | ថ្មស ខេត្តកោះកុង |
| ៩២ | សហគមន៍ | ថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង |
| ៩៣ | សហគមន៍ | សេសាន ខេត្តស្ទឹងត្រែង |
| ៩៤ | សហគមន៍ | សាមគ្គី ខេត្តស្ទឹងត្រែង |
| ៩៥ | សហគមន៍ | សៀមបូក ខេត្តស្ទឹងត្រែង |
| ៩៦ | សហគមន៍ព្រៃឈើ | ប៊ូស្រា ខេត្តមណ្ឌលគីរី |
| ៩៧ | សហគមន៍ព្រៃឈើ | ប៊ូស្រា ខេត្តមណ្ឌលគីរី |
| ៩៨ | សហគមន៍ព្រៃឈើ | ដាក់ដាំ ខេត្តមណ្ឌលគីរី |
| ៩៩ | សហគមន៍ | ដាក់ដាំ ខេត្តមណ្ឌលគីរី |
| ៥០ | សហគមន៍នេសាទកំពង់ត្រឡាចលើ | ស្រុករលាផ្អៀ ខេត្តកំពង់ឆ្នាំង |
| ៥១ | សហគមន៍ | កំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង |
| ៥២ | សហគមន៍ស្ត្រីដើម្បីអភិវឌ្ឍន៍ | កំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង |
| ៥៣ | សហគមន៍កសិកម្ម | ខេត្តព្រៃវែង |
| ៥៤ | សហគមន៍កសិកម្ម | ខេត្តព្រៃវែង |
| ៥៥ | សហគមន៍កសិកម្ម (សកម្មភាពដើម្បីសន្តិភាព) | ខេត្តស្វាយរៀង |
| ៥៦ | សហគមន៍ក្រុមសន្សំ | ខេត្តស្វាយរៀង |
| ៥៧ | សហគមន៍កសិកម្ម | ខេត្តព្រះវិហារ |
| ៥៨ | សហគមន៍កសិកម្មត្រពាំងស្រង៉ែ | ត្រពាំងស្រង៉ែ ខេត្តតាកែវ |
| ៥៩ | សហគមន៍កសិកម្មត្រពាំងក្រញូង | ត្រពាំងក្រញូង ខេត្តតាកែវ |
| ៦០ | សហគមន៍ឆេក្វ | ខណ្ឌឬស្សីកែវ ភ្នំពេញ |

| | | |
|---|---|---|
| ៦១ | សហគមន៍ក្រោលគោ | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៦២ | សហគមន៍ទំនប់ II | ទំនប់ ភ្នំពេញថ្មី |
| ៦៣ | សហគមន៍ | ទំនប់ ភ្នំពេញថ្មី |
| ៦៤ | សហគមន៍សន្តិភាព | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៦៥ | សហគមន៍ស្ត្រីឃ្លាំងសាំង | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៦៦ | សហគមន៍ស្ត្រី | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៦៧ | សហគមន៍ | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៦៨ | សហគមន៍បូរីដើមស្រល់ | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៦៩ | សហគមន៍កៅពីរ | ត្រពាំងស្វាយ ភ្នំពេញថ្មី |
| ៧០ | សហគមន៍ | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៧១ | សហគមន៍បូរីមិត្តភាព | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៧២ | សហគមន៍ | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៧៣ | សហគមន៍រួមមិត្ត | ខណ្ឌឬស្សីកែវ ភ្នំពេញ |
| ៧៤ | សហគមន៍កសិករ | ជ្រេស ភ្នំពេញថ្មី |
| ៧៥ | សហគមន៍កសិករ | ជ្រេស ភ្នំពេញថ្មី |
| ៧៦ | សហគមន៍ | ខណ្ឌឬស្សីកែវ ភ្នំពេញ |

*(សម្រង់ពីបញ្ជីវត្តមាន)*

*(សហគមន៍ដែលមកពីស្រុក និងខេត្តតែមួយ ប៉ុន្តែជាសហគមន៍ផ្សេងគ្នា)*



**ទស្សនវិស័យ៖** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា

**បេសកកម្ម៖** ក្នុងនាមជាអង្គការសមាជិកភាពគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាធ្វើការក្នុងភាពជាដៃគូដើម្បីអភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពនៃអង្គការសង្គមស៊ីវិលនៅកម្ពុជា

**គោលដៅ៖** សង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំ និងមានសមត្ថភាពឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍនៅកម្ពុជា

**គុណតម្លៃ៖**

- សុចរិតភាព
- ភាពឆ្លើយតប
- កិច្ចសហប្រតិបត្តិការ
- គុណភាព
- បរិយាបន្ន



ផ្ទះលេខ ៩-១១, ផ្លូវលេខ ៤៧៦, សង្កាត់ទួលទំពូង១, ខណ្ឌចំការមន ភ្នំពេញ, កម្ពុជា ប្រអប់សំបុត្រ ៨៥៥
លេខទូរស័ព្ទ : +៨៥៥ ២៣ ២១៤ ១៥២
ទូរសារ +៨៥៥ ២៣២ ២១៦ ០០៩
អ៊ីម៉ែល : info@ccc-cambodia.org
វេបសាយ : www.ccc-cambodia.org
ហ្វេសប៊ុក : www.facebook.com/CCCsince1990
យូធូប : www.youtube.com/CCCambodia